# ធនាគារជាតិនៃកម្ពុជា

## ព្រឹត្តិបត្រប្រចាំត្រីមាស



## លេខ ៣៩

## ត្រីមាសទី៤ ឆ្នាំ២០១២

ចេញផ្សាយតាមប្រកាសលេខ ធ៦-០១១-១២៣ ប្រ.ក ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១១

បោះពុម្ពផ្សាយដោយ

# ធនាគារជាតិ នៃ កម្ពុជា


| | | |
|---|---|---|
| អាសយដ្ឋាន | : | ២២-២៤ មហាវិថីព្រះនរោត្តម<br>ភ្នំពេញ កម្ពុជា |
| ប្រអប់សំបុត្រ | : | ២៥ |
| ទូរស័ព្ទ | : | (៨៥៥) ២៣ ៧២២ ៥៦៣ |
| ទូរសារ | : | (៨៥៥) ២៣ ៤២៦ ១១៧ |
| គេហទំព័រ | : | www.nbc.org.kh |


*********

Published by

# National Bank of Cambodia


| | | |
|---|---|---|
| Address | : | 22-24 Preah Norodom Blvd.<br>Phnom Penh, Cambodia |
| P.O.BOX | : | 25 |
| Phone | : | (855) 23 722 563 |
| FAX | : | (855) 23 426 117 |
| Website | : | www.nbc.org.kh |



| គណៈកម្មការព្រឹត្តិបត្រ | | Review Commission | |
|---|---|---|---|
| - ឯកឧត្តម ថា យ៉ាវ | ប្រធាន | H.E. Tha Yao | Chairman |
| - ឯកឧត្តម ស៊ុំ សន្និសិទ្ធ | និពន្ធនាយក | H.E. Dr.Sum Sannisith | Chief Editor |

# អារម្ភកថា



## ឯកឧត្តម ជា ចាន់តូ
## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

*ប្រិយមិត្តអ្នកអានជាទីមេត្រី !*

ស្ថានភាពសេដ្ឋកិច្ចពិភពលោកមានស្ថិរភាពជាបង្គួរដោយសារការងើបឡើងវិញបន្តិចម្តងៗនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក រួមជាមួយនឹងការខិតខំយ៉ាងសកម្មក្នុងការរកដំណោះស្រាយចំពោះវិបត្តិបំណុលនៅតំបន់អឺរ៉ុប ខណៈសម្ពាធអតិផរណាសកលបានថយចុះបន្តិច ។ ទន្ទឹមនោះ ប្រព័ន្ធហិរញ្ញវត្ថុសកលក៏បានធូរស្បើយមួយកម្រិតផងដែរ ប៉ុន្តែនៅប្រឈមនឹងភាពមិនប្រាកដប្រជានៅឡើយ ។

ទោះបីសកម្មភាពសេដ្ឋកិច្ចនាដើមឆ្នាំ២០១២មានល្បឿនយឺតប៉ុន្តែមានការរំពឹងទុកនូវលទ្ធផលប្រសើរជាងនេះនាចុងឆ្នាំ។ តាមការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០១២មានកម្រិតត្រឹម ៣,៣% ធៀបនឹង ៣,៨% នៅឆ្នាំ២០១១ ។ ស្ថានភាពសេដ្ឋកិច្ចនៅសហគមន៍អឺរ៉ុបអាចមាននិន្នាការធ្លាក់ចុះក្នុងកម្រិតទាបមួយ ខណៈដែលប្រទេសជឿនលឿនដទៃទៀតនៅក្រៅតំបន់អឺរ៉ុប រួមទាំងប្រទេសជប៉ុនផងដែរប្រឈមនឹងកំណើនទាបនៅឡើយ ។ ការព្យាករកំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិកក្នុងឆ្នាំ២០១២មានកំណើន ២,២% (១,៨% ឆ្នាំ២០១១) និងអាឡឺម៉ង់ 0,៩% (៣,១% ឆ្នាំ២០១១)។ ចំណែកឯ សេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីបានថយចុះ ៦,៧% ក្នុងឆ្នាំ២០១២ (៧,៨% ឆ្នាំ២០១១) ក្នុងនោះ សេដ្ឋកិច្ចប្រទេសចិនត្រូវបានរំពឹងថានឹងមានកំណើន ៧,៨% (៩,២% ឆ្នាំ២០១១) និងឥណ្ឌា ៤,៩% (៦,៨% ឆ្នាំ២០១១) ។

ចំពោះប្រទេសកម្ពុជាវិញ រាជរដ្ឋាភិបាលបានព្យាករថា នៅឆ្នាំ២០១២ សេដ្ឋកិច្ចកម្ពុជាមានមូលដ្ឋានកំណើនរឹងមាំនិងមានកំណើនប្រហាក់ប្រហែលឆ្នាំមុនគឺ ៧% (៧,១%ឆ្នាំ២០១១) ។ លទ្ធផលដ៏ល្អនេះ ទទួលបានពីការអនុវត្តគោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុសមស្រប ទន់ភ្លន់ប្រកបដោយប្រសិទ្ធភាពនិងការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការជួយស្តារស្ថានភាពវិស័យកសិកម្មទាន់ពេលវេលា ។ វិស័យឧស្សាហកម្មត្រូវបានរំពឹងថានឹងកើនឡើង១០,៦%និងបន្តរួមចំណែកជាចម្បងនៅក្នុងកំណើនសេដ្ឋកិច្ច ខណៈដែលវិស័យសេវាកម្មមានកំណើន៦,៤%និងវិស័យកសិកម្ម៣,៩%។ការនាំចេញសម្លៀកបំពាក់និងវាយនភ័ណ្ឌត្រូវបានរំពឹងថានឹងបន្ថយល្បឿនបន្តិចក្នុងអត្រាកំណើនប្រមាណ ១០% ដោយសារសកម្មភាពសេដ្ឋកិច្ចនៃប្រទេសដៃគូនាំចូលនៅទន់ខ្សោយ ។

ក្នុងនាមអាជ្ញាធររូបិយវត្ថុនិងត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាបានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន និងបានរួមចំណែកពង្រឹងស្ថិរភាព

ប្រព័ន្ធហិរញ្ញវត្ថុនិងម៉ាក្រូសេដ្ឋកិច្ច សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។

ក្នុងបរិការនេះ ធនាគារជាតិនៃកម្ពុជាបន្តរក្សាបានកម្រិតអតិផរណាទាបនិងស្ថិរភាពអត្រាប្តូរប្រាក់បានយ៉ាងប្រសើរ ដែលជាអំណោយផលសម្រាប់សកម្មភាពសេដ្ឋកិច្ច ។ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងអន្តរការិយកម្មធនាគារនិងស្ថានភាពហិរញ្ញវត្ថុនៃប្រព័ន្ធធនាគារឲ្យមានលក្ខណៈល្អប្រសើរ និងមិនទទួលរងនូវផលប៉ះពាល់ពីវិបត្តិបំណុលនៅតំបន់អឺរ៉ុបឡើយ ។ អនុបាតសាធនភាពនិងសន្ទនីយភាពក្នុងប្រព័ន្ធធនាគារមានកម្រិតខ្ពស់ស្របពេលដែលអនុបាតឥណទានមិនដំណើរការបានថយចុះគួរឲ្យកត់សម្គាល់។ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ធនាគាជាតិនៃកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ជាពិសេស ការពង្រឹងក្របខ័ណ្ឌត្រួតពិនិត្យនិងបញ្ញត្តិកម្ម រួមទាំងបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើផងដែរ ។ ការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ គឺជាផ្នែកដ៏សំខាន់មួយនៃយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរយៈកាលវែងរបស់រាជរដ្ឋាភិបាល។

ដោយឡែកហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុក៏ត្រូវបានពង្រឹងជាបន្តបន្ទាប់ តាមរយៈការអភិវឌ្ឍប្រព័ន្ធទូទាត់និងផាត់ទាត់ដែលមានលក្ខណៈមជ្ឈការប្រព័ន្ធចែករំលែកព័ត៌មាន ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ។ ជាងនេះទៅទៀត ការងារមួយដ៏សំខាន់ចំពោះមុខ គឺការពង្រឹងការប្រើប្រាស់ប្រាក់រៀលដែលបច្ចុប្បន្នធនាគារជាតិនៃកម្ពុជាកំពុងសិក្សារៀបចំវិធីសាស្ត្រគោលនយោបាយនិងយន្តការសហប្រតិបត្តិការសំដៅឈានទៅសម្រេចបាននូវគោលដៅរយៈកាលវែងរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើបដិដុល្លារូបនីយកម្មដោយប្រុងប្រយ័ត្ន ។

ជារួម សមិទ្ធផលដែលធនាគារជាតិនៃកម្ពុជាសម្រេចបានទាំងនេះ គឺដោយសារការខិតខំប្រកបដោយការប្តេជ្ញាចិត្តរបស់មន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់និងការគាំទ្រប្រកបដោយប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ជាពិសេស រាជរដ្ឋាភិបាល និងកិច្ចសហការពីសំណាក់ដៃគូអភិវឌ្ឍន៍ទាំងឡាយ ។

ជាទីបញ្ចប់ ធនាគារជាតិនៃកម្ពុជាបន្តកិច្ចខិតខំប្រឹងប្រែងបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃតាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន និងរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ ព្រមទាំងក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចូលរួមចំណែកនិងសហការយ៉ាងជិតស្និទ្ធជាមួយធនាគារជាតិនៃកម្ពុជាក្នុងការសម្រេចបាននូវភារកិច្ចជាបន្តបន្ទាប់ ។ ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជូនដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមប្រកបតែសេចក្តីសុខ ទទួលបានជោគជ័យគ្រប់ភារកិច្ចនិងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**

# មាតិកា

ទំព័រ


- **អារម្ភកថា** ........................................................................................................ i-ii

- ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជានិងលោកជំទាវ **ខៀវ ស៊ីណា** បានដឹកនាំគណៈប្រតិភូធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមគោរព **ព្រះបរមសព ព្រះករុណា ព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ**......................... ១

- សុន្ទរកថា **ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិ នៃ កម្ពុជា** ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា.................................................................. ៤

- សុន្ទរកថា ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា.................................................................................. ១២

- សុន្ទរកថា ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា.................................................................................. ២១

- សុន្ទរកថារបស់ឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសម្ពោធជាផ្លូវការ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០........... ២៩

- សុន្ទរកថារបស់ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាអនុប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងពិធីសម្ពោធជាផ្លូវការ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០............................................ ៣៥

- សុន្ទរកថារបស់ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា ក្នុងឱកាសបើកកិច្ចប្រជុំគណៈកម្មការប្រតិបត្តិលើកទី៦១ និងមហាសន្និបាតលើកទី១៨ របស់សមាគមឥណទានកសិកម្មជនបទអាស៊ីប៉ាស៊ីហ្វិក(APRACA)................................................ ៤៣

- សេចក្តីប្រកាសព័ត៌មាន........................................................................................ ៥០
- ប្រកាស ស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ .............................. ៥១
- ប្រកាស ស្តីពីតម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ....... ៦៧
- ប្រកាស ស្តីពីអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ.................................................................... ៧១
- ផលប៉ះពាល់នៃវិបត្តិបំណុលនៃតំបន់អឺរ៉ូមកលើអាស៊ី................................................... ៧៤
- តារាងអត្រាប្តូរប្រាក់ប្រចាំខែ ........................................................................... ៨៤
- តារាងអត្រាការប្រាក់លើប្រាក់បញ្ញើ ........................................................................ ៨៥
- តារាងអត្រាការប្រាក់លើប្រាក់កម្ចី ........................................................................ ៨៧
- បញ្ជីឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ........................................................... ៨៩
- ប្រព័ន្ធធនាគារកម្ពុជា .......................................................................................... ១១៨
- រូបថតសកម្មភាពថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា..................................................... ១២០-១៣៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..៨១..០១២..០៦១..៣៩៩.៨..

## សូមក្រាបបង្គំទូលថ្វាយ
## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

បពិត្រ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ទូលព្រះបង្គំយើងខ្ញុំជាថ្នាក់ដឹកនាំមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេស និងក្នុងនាមទូលព្រះបង្គំខ្ញុំផ្ទាល់និងភរិយា មានក្តីក្តុកក្តួលរន្ធត់ចិត្តឥតឧបមា ដោយ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជ បិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ព្រះអង្គទ្រង់បានយាងចូលទីវង្គត នាថ្ងៃទី ១៥រោច ខែភទ្របទ ឆ្នាំរោង ចត្វាស័ក ព.ស២៥៥៦ ត្រូវនឹងថ្ងៃទី១៥ ខែតុលា គ.ស២០១២ វេលាម៉ោង ០១:២០ នាទី រំលងអធ្រាត្រ ម៉ោងនៅរាជធានីភ្នំពេញ ក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា ដោយព្រះជរាពាធ នៅមន្ទីរពេទ្យទីក្រុងប៉េងកាំង នៃសាធារណរដ្ឋប្រជាមានិតចិន ។

ក្នុងឱកាសប្រកបដោយក្តីខ្សឹកខ្សួលរំជួលចិត្តដ៏សែនក្រៀមក្រំនេះ ទូលព្រះបង្គំយើងខ្ញុំសូមព្រះបរមរាជានុញ្ញាតសម្តែងថ្វាយនូវសមានទុក្ខដ៏មហាជ្រាលជ្រៅបំផុត ព្រមទាំងក្តីសង្វេគដ៏មហាធំធេង និងពោរពេញដោយក្តីសោកស្តាយស្រណោះអាឡោះអាល័យជាអនេកប្បការ ចំពោះអង្គព្រះមហាវីរក្សត្រ ព្រះវររាជបិតា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គទ្រង់លាចាកលោក ចាកពីទូលព្រះបង្គំយើងខ្ញុំ ដែលជានិច្ចកាលបានដង្ហែយ៉ាងស្មោះស្ម័គ្រប្រកបដោយភក្តីភាពយ៉ាងជ្រាលជ្រៅ តាមព្រះវីរគំរូមនុស្សធម៌ដ៏ថ្លៃថ្លារបស់អង្គសម្តេចឪ ។

បពិត្រ **ព្រះករុណា** ជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈ

ការបាត់បង់ព្រះរាជវត្តមានដ៏ឧត្តុង្គឧត្តមនៃ អង្គសម្តេចព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យជាតិខ្មែរ គឺជាការបាត់បង់នូវតួអង្គព្រះអតីតអង្គព្រះមហាក្សត្រខ្មែរដ៏មហាឆ្នើមគ្មានគូប្រដូចមួយព្រះអង្គ ដែលជានិច្ចកាលទ្រង់បំពេញព្រះរាជបូជនិយកិច្ចដើម្បីឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ប្រកបដោយព្រះបញ្ញាញាណភ្លឺថ្លាវាងវៃគ្រប់កាលៈទេសៈ ។ ថ្វីបើព្រះរូបព្រះកាយរបស់ព្រះអង្គបែកកាយរំលាយក្ខន្ធយាងទៅកាន់បរលោកហើយក្តី ប៉ុន្តែព្រះរាជលំអាន ព្រះវីរគំរូដ៏ល្អឆ្នើមរបស់អង្គសម្តេចឪជាអម្ចាស់ ទ្រង់ស្ថិតនៅជានិច្ចក្នុងដួងចិត្តរបស់ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ជាកូនចៅ ចៅទួតរបស់ព្រះអង្គ ពិតជាមិនអាចមានថ្ងៃបំភ្លេចបានឡើយ ។

ក្នុងសមានទុក្ខដ៏សែនក្រៀមក្រំនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលំអោនកាយឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ សូមបីបាច់ថែរក្សាដួងព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ សូមព្រះអង្គទ្រង់យាងចាប់បដិសន្ធិក្នុងព្រះបរមសុគតិភព គ្រប់ៗព្រះជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ប្រោសព្រះរាជមេត្តាទទួលនូវកតញ្ញូតាធម៌ដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ។

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២

**តំណាងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា**

**ទេសាភិបាល**

**ជា ចាន់តូ**



ឯកឧត្តម ជា ចាន់តូ  ទេសាភិបាលធនាគារជាតិនៃកម្ពុជា និង លោកជំទាវ ខៀវ ស៊ីណា បានដឹកនាំគណៈប្រតិភូធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមគោរពព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ







ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា

ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ នៅធនាគារជាតិនៃកម្ពុជា

**សូមគោរព :**

- **គណៈអធិបតី**
- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា**

មកដល់ពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជាយើង ដែលបានប្រព្រឹត្តទៅរយៈពេលមួយថ្ងៃកន្លះនេះ បានឈានដល់ពេលដែលត្រូវបញ្ចប់ហើយ ។ ជារួម ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះសន្និបាតយើងថា បានប្រព្រឹត្តទៅយ៉ាងសកម្ម និងដោយរលូនរហូតដល់ទីបញ្ចប់ប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយនិងស្និទ្ធស្នាលបំផុត ។ ខ្ញុំជឿជាក់ថា សមាជិក-សមាជិកានៃអង្គសន្និបាតយើងពេលនេះ ពិតជាក្តាប់បាននូវខ្លឹមសារសំខាន់ៗនៃអង្គសន្និបាត និងបទ-អន្តរាគមន៍នានា ជាពិសេស បង្ហាញពីទិសដៅការងារដែលថ្នាក់ដឹកនាំបានលើកឡើងតាមផ្នែកសម្រាប់យកទៅអនុវត្តបន្តនាពេលអនាគត ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

ទន្ទឹមនឹងនេះខ្ញុំក៏សូមអបអរសាទរចំពោះមន្ត្រីបុគ្គលិកយើងដែលបានខិតខំបំពេញការងាររយៈពេល៣០ឆ្នាំ និងមន្ត្រីដែលមានស្នាដៃល្អបានទទួលសញ្ញាមាសអនុស្សាវរីយ៍ពីធនាគារជាតិនៃកម្ពុជានៅពេលនេះ។ ខ្ញុំសូមថ្លែងអំណរព្រះគុណចំពោះឯកឧត្តម លោក លោកស្រី ដែលបានផ្តល់បទអន្តរាគមន៍និងអនុសាសន៍ល្អៗជូនអង្គសន្និបាតយើង ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះសមាជិក-សមាជិកាទាំងអស់ ដែលបានចូលរួមក្នុងអង្គសន្និបាតនេះតាំងពីដើមរហូតដល់ចប់និងបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមស្តាប់ខ្លឹមសារសំខាន់ៗនៃបទអន្តរាគមន៍អនុសាសន៍ល្អៗរបស់ថ្នាក់ដឹកនាំ និងទិសដៅការងាររបស់ធនាគារជាតិនៃកម្ពុជាសម្រាប់យកទៅអនុវត្តបន្ត។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ខ្ញុំបានកត់សម្គាល់ឃើញថា ក្នុងរយៈពេលមួយថ្ងៃកន្លះនេះ អង្គសន្និបាតយើងបានស្តាប់ខ្លឹមសារសំខាន់នៃរបាយការណ៍ដោយលោកស្រី ស្រី ស៊ីយុត ដែលបានឆ្លុះបញ្ចាំងពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងការដឹកនាំគោលនយោបាយរូបិយវត្ថុ ដើម្បីរក្សាស្ថិរភាពថ្លៃ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការងារគណនេយ្យ ការងារប្រតិបត្តិការជាមួយសាខារាជធានី-ខេត្ត ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការងារសវនកម្ម និងអធិការកិច្ច និងការងារអគ្គលេខាធិការដ្ឋាន ការងារអគ្គបេឡាជាដើម ។ នៅឆ្នាំ២០១១ ប្រព័ន្ធធនាគារនៅកម្ពុជាមានសុខភាពល្អ

និងការរក្សាស្ថិរភាពថ្លៃនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាពស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ទោះបីជាបញ្ហាអតុល្យភាពពិភពលោកមិនទាន់ដោះស្រាយចេញក៏ដោយ ក៏កំណើនសេដ្ឋកិច្ចពិភពលោកកំពុងវិវត្តជាវិជ្ជមាន សេដ្ឋកិច្ចអាស៊ីមានមូលដ្ឋានកំណើនរឹងមាំ។ ចំពោះកំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងកើនក្នុងកម្រិតពី ៦,៩%។ កំណើននេះ ទ្រទ្រង់ដោយភាពអំណោយផលពីវិស័យកសិកម្ម ទេសចរណ៍ កាត់ដេរ និងវិនិយោគផ្ទាល់បរទេស ។

ដើម្បីបន្តចូលរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងគាំទ្រចីរភាពនៃកំណើននេះ ខ្ញុំសូមលើកឡើងនូវមតិខ្លះៗ ដើម្បីឱ្យមន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាលនិងនៅសាខារាជធានី-ខេត្ត ជ្រាបពីអ្វីដែលធនាគារជាតិនៃកម្ពុជាត្រូវធ្វើនាពេលអនាគត ដូចតទៅ ៖

**១/- ការងារពង្រឹងសុខភាពប្រព័ន្ធធនាគារ** : ឯកឧត្តម ប៉ាល់ ប៊ុយបុណ្ណាង បានជម្រាបជូនអង្គសន្និបាតរួចហើយ ។ ស្ថិរភាពនៃប្រព័ន្ធធនាគារ គឺជាការងារអាទិភាពរបស់យើងត្រូវពង្រឹង ជាចាំបាច់និងជាប់ជាប្រចាំ ក្នុងខណៈពេលដែលទីផ្សារមូលបត្រនិងទីផ្សារទុនត្រូវបានបង្កើតឡើងនៅពេលថ្មីៗនេះ ។ ការងារនេះ តម្រូវឱ្យមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករយើងពង្រឹងការត្រួតពិនិត្យដល់ទីកន្លែងនិងលើឯកសារជាប់ជាប្រចាំ ដើម្បីជួយពង្រឹងសុខ-ភាពប្រព័ន្ធធនាគារ ជំនឿទុកចិត្តវិនិយោគិន និងការពារផលប្រយោជន៍សាធារណជន សំដៅអភិវឌ្ឍប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាព ។

ការងារផ្តល់អាជ្ញាប័ណ្ណថ្មីដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានរឹតបន្តឹង ស្របតាមគោលការណ៍អភិបាលកិច្ចល្អ និងស្ថានភាពសេដ្ឋកិច្ចកម្ពុជា ។ នេះគឺជាវិធានការប្រុងប្រយ័ត្ន មួយទៀតរបស់អាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិករ ។ ការងារផ្តល់អាជ្ញាប័ណ្ណត្រូវធ្វើឡើងស្ថិតនៅ លើគោលការណ៍សំរិតសំរាំង និងពិចារណាលើបញ្ហាប្រឈមនិងហានិភ័យចំពោះប្រព័ន្ធធនាគារ ។

ដើម្បីអនុវត្តការងារនេះបានសម្រេច យើងត្រូវបន្តលើកកម្ពស់សមត្ថភាពមន្ត្រីត្រួតពិនិត្យ និងបញ្ញត្តិកររៀបចំវិធីសាស្ត្រនៃការត្រួតពិនិត្យដោយផ្អែកលើហានិភ័យ (Risk based) ទស្សនៈ អនាគត (Forward-looking) និងការត្រួតពិនិត្យគួបសរុប(Consolidated)បន្ថែមលើយន្តការត្រួតពិនិត្យបច្ចុប្បន្នដែលផ្អែកលើមូលដ្ឋានច្បាប់ ។ យើងក៏ត្រូវជំរុញឱ្យបង្កើតការិយាល័យឥណទាន និងបន្តកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិឱ្យស្របតាមគោលការណ៍គ្រឹះរបស់គណៈកម្មាធិការទីក្រុង បាសែលផងដែរ ។

**២/- ការងារពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ** : ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុទាំងផ្នែកបណ្តាញសេវា និងផលិតផលនេះ បានផ្តល់សញ្ញាណពីរ គឺ

១/-ជួយរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម និង

២/-បានបង្ហាញពីសញ្ញាណថ្មីសម្រាប់អាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិករត្រូវបង្កើនការយកចិត្តទុកដាក់គ្រប់គ្រងហានិភ័យទាំងឡាយដែលអាចកើតមានឡើង ដោយសារការរីកចម្រើននៃសេវា និងឧបករណ៍ហិរញ្ញវត្ថុទាំងនេះ ។

ដើម្បីការពារហានិភ័យក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ តម្រូវឱ្យអាជ្ញាធររៀបចំនូវក្របខ័ណ្ឌបទប្បញ្ញត្តិសមស្រប ប្រព័ន្ធប្រកាសអាសន្នជាមុន វិធានការការពារគ្រប់គ្រងនិងដោះស្រាយវិបត្តិស្របតាមគោលការណ៍គ្រឹះរបស់គណៈកម្មាធិការទីក្រុងបាសែល និងបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករជាប់ជាប្រចាំ ដើម្បីវាយតម្លៃហានិភ័យ បញ្ហាប្រឈមនិងការលើកជាវិធានការសម្រាប់ពង្រឹងស្ថិរភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ។ បច្ចុប្បន្ននេះ

យើងកំពុងបណ្តុះបណ្តាលសមត្ថភាពជំនាញដល់ក្រុមការងារស្ថិរភាពហិរញ្ញវត្ថុរបស់យើងបណ្តើរៗ ដើម្បីហាត់រៀនធ្វើការងារនេះបណ្តើរៗ ។

**៣/-វិស័យមីក្រូហិរញ្ញវត្ថុ:** វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាបានដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ រាជរដ្ឋាភិបាលកំពុងកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមជារូបវន្តដល់ជនបទ។ យើងបានបន្តលើកទឹកចិត្តឱ្យគ្រឹះស្ថានទាំងនោះពង្រីកបណ្តាញសេវារបស់ខ្លួនទៅតំបន់ជនបទដាច់ស្រយាលអាចទទួលប្រាក់បញ្ញើពីសាធារណជនបាននិងបង្កើតកម្មវិធីផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការប្រើប្រាស់ឥណទានខ្នាតតូច ។

ដើម្បីបន្តពង្រឹងនិងពង្រីកវិស័យនេះឱ្យរីកចម្រើនថែមទៀត យើងត្រូវរៀបចំឱ្យមានយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែង ដូចជា

១/-បង្កើតការិយាល័យឥណទាន
២/-កែលម្អក្របខ័ណ្ឌច្បាប់និងប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
៣/-បង្កបរិយាកាសប្រកួតប្រជែងផលិតផលហិរញ្ញវត្ថុ និង
៤/-ពង្រីកលទ្ធភាពទទួលបានឥណទានចំពោះប្រជាជនដែលមានចំណូលទាបនៅតំបន់ជនបទបន្ថែមទៀត។

**៤/- ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច** : លោក ហ៊ុយ ណាវី បានជម្រាបជូនអង្គសន្និបាតរួចហើយខ្ញុំសូមឯកភាពតាមការលើកឡើងនេះ ។ ការងារនេះ គឺដើម្បីវាយតម្លៃពីសុវត្ថិភាព និងសុខភាពធនាគារជាតិនៃកម្ពុជាប្រៀបដូចជាការធ្វើ Medical Checkup ខ្លួនឯងដើម្បីរកឱ្យឃើញពីចំណុចខ្លាំងនិងចំណុចខ្សោយសម្រាប់កែតម្រូវ ។ ការងារនេះមានសារៈសំខាន់ណាស់ សម្រាប់ធនាគារកណ្តាលក្នុងការពង្រឹងប្រតិបត្តិការផ្ទៃក្នុងរបស់ខ្លួនឱ្យប្រព្រឹត្តទៅដោយរលូនមានសុវត្ថិភាពនិងប្រសិទ្ធភាព ។ កន្លងមកការងារនេះ មន្ត្រីយើងបានបំពេញបានល្អប្រសើរហើយ ។ មន្ត្រីយើងក៏បានទទួលការបណ្តុះបណ្តាលផ្នែកនេះជាបន្តបន្ទាប់ផងដែរទាំងនៅកន្លែង និងក្រៅប្រទេស ។

ដើម្បីបន្តដំណើរការការងារនេះឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពថែមទៀត ខ្ញុំសូមស្នើសុំឱ្យបន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ និងរៀបចំកម្មវិធីចុះតាមដានការអនុវត្តតាមអនុសាសន៍ដែលបានលើកឡើង និងរៀបចំយន្តការវាយតម្លៃហានិភ័យប្រតិបត្តិការតាមផ្នែក (Targeted re-assessment procedures) និងពង្រឹងការងារអធិការកិច្ចទាំងនៅទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្តបន្តទៀត ។ យើងត្រូវរៀបចំផែនការសកម្មភាព និងកំណត់អាទិភាពតាមលំដាប់លំដោយចំពោះការប្រើប្រាស់ប្រព័ន្ធ Flexcube ។ អនុវត្តប្រព័ន្ធនេះដោយរលូនតម្រូវឱ្យមន្ត្រីជំនាញមានស្មារតីតស៊ូព្យាយាម លះបង់ចំពោះការងារ មានភាពស្មោះត្រង់ គោរពវិន័យនិងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះការងារ ។

**៥/- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ** : ខ្ញុំសូមជម្រាបថា ការងារគ្រប់គ្រងទុនបម្រុងអន្តរជាតិគឺជាតួនាទីស្នូលរបស់ធនាគារជាតិនៃកម្ពុជា ។ បច្ចុប្បន្ន ការងារនេះមានការរីកចម្រើនជាលំដាប់ទាំងផ្នែកសមត្ថភាព និងបច្ចេកទេស។ មន្ត្រីជំនាញយើងមានលទ្ធភាពអាចធ្វើដោយខ្លួនឯង(Indexation) លើចំណុចខ្លះ។ យើងបានពង្រឹងការគ្រប់គ្រងទុនបម្រុងអន្តរជាតិដោយប្រុងប្រយ័ត្ន ដោយផ្អែកលើគោលការណ៍សំខាន់បី គឺសុវត្ថិភាព សន្ទនីយភាព និងចំណូលព្រមទាំងមានការសម្រេចគោលនយោបាយពីក្រុមប្រឹក្សាភិបាល និងយុទ្ធសាស្ត្រវិនិយោគពីគណៈកម្មាធិការវិនិយោគរបស់ធនាគារជាតិនៃកម្ពុជា ។

បច្ចុប្បន្ន ទុនបម្រុងអន្តរជាតិយើងកើនឡើងជាង ៣ពាន់លានដុល្លារអាមេរិកស្មើនឹង ៤,៩ខែនៃការនាំចូល ។ គោលដៅសំខាន់នៃការគ្រប់គ្រងទុនបម្រុងអន្តរជាតិ គឺដើម្បីសម្រួលដល់ការទូទាត់ពាណិជ្ជកម្មរក្សាស្ថិរភាពថ្លៃ និងបង្កើនជំនឿទុកចិត្តលើរូបិយវត្ថុជាតិ ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាត្រូវរក្សាកម្រិតទុនបម្រុងអន្តរជាតិរបស់ខ្លួនយ៉ាងតិចស្មើនឹង ៣,៥ខែ នៃការនាំចូល និងជំរុញការបណ្តុះបណ្តាលមន្ត្រីជំនាញថែមទៀត ដើម្បីឱ្យដើរស្របនឹងការ ប្រែប្រួលនៃវិស័យហិរញ្ញវត្ថុ ។

**៦/- ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** : ឯកឧត្តម ផាន់ ហូរ បានជម្រាបជូនអង្គសន្និបាតរួចហើយ ឃើញថាការងារនេះកំពុងមានការរីកចម្រើនជាលំដាប់ ។ ការងារនេះ គឺជាការងារជំនាញផង និងសហប្រតិបត្តិការផងទាក់ទងនឹងការរួមចំណែកការពារទប់ស្កាត់ និងប្រឆាំងរាល់សកម្មភាពនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ។ ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិត្រូវបន្តពង្រឹង និងពង្រីកយន្តការសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្តក្នុងតំបន់ ដោយសហការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ មជ្ឈមណ្ឌលបណ្តុះបណ្តាលប្រចាំតំបន់ និងធនាគារកណ្តាលបរទេសទាំងក្នុងតំបន់ និងពិភពលោក ដើម្បីបណ្តុះបណ្តាលឯកទេសកម្មដល់មន្ត្រីជំនាញផ្លាស់ប្តូរបទពិសោធន៍គ្នា និងធ្វើការស្រាវជ្រាវអំពីដំណោះស្រាយ ចំពោះបញ្ហាប្រឈមនានា ដែលកំពុងតែកើតឡើងនៅក្នុងតំបន់ និងពិភពលោកនាពេលបច្ចុប្បន្ន ។

ដើម្បីអនុវត្តការងារនេះឱ្យបានជោគជ័យថែមទៀត យើងត្រូវបន្តបណ្តុះបណ្តាលសមត្ថភាពជំនាញដល់មន្ត្រី និងពង្រឹងការអនុវត្តច្បាប់ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងពង្រឹងកិច្ចសហការជាមួយអគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា និង សហគមន៍ជាតិ-អន្តរជាតិបន្ថែមទៀត ។

**៧/- ការពង្រឹងការប្រើប្រាស់ប្រាក់រៀល** : ជាការងារអាទិភាពរបស់យើង ដែលចាំបាច់ត្រូវធ្វើដោយសន្សឹមៗនិងប្រុងប្រយ័ត្ន ព្រោះជាការងារប្រទាក់ក្រឡាគ្នានិងប្រើប្រាស់ពេលវេលាយូរ ។ បញ្ហាដុល្លារូបនីយកម្មជាបញ្ហារួមរបស់យើង ដែលប្រវត្តិសាស្ត្របានបន្សល់ទុកឱ្យយើងទាំងអស់គ្នា ។ ដើម្បីឱ្យសាធារណជនទូទៅបានស្វែងយល់ពីសារៈសំខាន់នៃប្រាក់រៀល និងបញ្ហាប្រឈមក្នុងការប្រើប្រាស់រូបិយប័ណ្ណបរទេសក្នុងសេដ្ឋកិច្ចកម្ពុជា យើងបានរៀបចំខ្សែភាពយន្តឯកសារចំនួនបី ផ្សព្វផ្សាយតាមបណ្តាញព័ត៌មាន ។ តាមរយៈខ្សែភាពយន្តឯកសារនេះ យើងសង្កេតឃើញថា សាធារណជនភាគច្រើនបានគាំទ្រ និងយល់ពីតម្លៃនៃការប្រើប្រាស់ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចនិងជីវភាពប្រចាំថ្ងៃ ។ ដើម្បីឈានទៅធ្វើបដិដុល្លារូបនីយកម្មចេញពីសេដ្ឋកិច្ចយើងត្រូវរួមគ្នារៀបចំផែនការយុទ្ធសាស្ត្រថ្នាក់ជាតិរយៈពេលវែងមួយ ដើម្បីកំណត់ពីអាទិភាព តាមលំដាប់លំដោយឱ្យបានច្បាស់លាស់ ។

ការកំណត់អាទិភាពមានន័យថា ផ្នែកនយោបាយរូបិយវត្ថុយើងត្រូវមានវិធានការអ្វីខ្លះ? ផ្នែកនយោបាយសារពើពន្ធដែលជាអ្នកគ្រប់គ្រងចំណូលនិងចំណាយថវិកា ត្រូវធ្វើអ្វីខ្លះ? ផ្នែកអប់រំត្រូវធ្វើអ្វីខ្លះ ដើម្បីជំរុញការផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃ រូបិយវត្ថុជាតិ ដើម្បីឱ្យសាធារណជនរត់គំនិតក្នុងការសន្សំ ការប្រើប្រាស់ប្រាក់រៀល ផ្នែកទេសចរណ៍ ដែលជាអ្នកគ្រប់គ្រងសេវាមណ្ឌលកំសាន្តនិងសណ្ឋាគារត្រូវធ្វើអ្វីខ្លះ? ផ្នែកពាណិជ្ជកម្ម កសិកម្ម និងមហាផ្ទៃ ត្រូវធ្វើអ្វីខ្លះ? ។ និយាយឱ្យខ្លី គឺត្រូវមានការចូលរួមពីកម្លាំងសរុប ទើបអាចអនុវត្តផែនការយុទ្ធសាស្ត្រនេះដោយរលូននិងសម្រេចបានជោគជ័យ ។

**៨/- ការងារគណនេយ្យនិងប្រតិបត្តិការ** : លោក អ៊ូ ចាន់តារា បានបញ្ជាក់ថា ការងារនេះជាការងារជំនាញទាក់ទងនឹងបច្ចេកទេសចុះកិច្ចបញ្ជិកាហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ទាំងនៅទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្តឱ្យមានទម្រង់ជារបាយការណ៍ហិរញ្ញវត្ថុ រួមមួយស្របតាមស្តង់ដារគណនីរបស់ធនាគារជាតិនៃកម្ពុជា

និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ។ ដើម្បីសម្រួលដល់ការងារនេះ យើងបានបំពាក់ប្រព័ន្ធធនាគារស្នូល គឺប្រព័ន្ធ Flexcube ទាំងនៅទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត ក្នុងបំណងចែករំលែកព័ត៌មានហិរញ្ញវត្ថុ និងលំហូរការងារឱ្យទាន់គ្នាក្នុងពេលតែមួយ (real time) ចំពោះប្រតិបត្តិការតែមួយដូចគ្នា ។ ដោយសារប្រព័ន្ធនេះថ្មីមានលក្ខណៈវិទ្យាសាស្ត្រទំនើប (computerization) ជាងប្រព័ន្ធចាស់ (manual) ដែលកន្លងមកធ្វើឱ្យយើងជួបការលំបាកដោយអន្លើ ។

ក្នុងការប្រតិបត្តិការងារជាក់ស្តែង យើងតែងជួបការលំបាកខ្លះហើយ ប៉ុន្តែយើងត្រូវតែជម្នះ និងសម្របខ្លួនទៅនឹងការប្រែប្រួលនៃបច្ចេកវិទ្យាថ្មីនិងរៀនប្រើប្រាស់ ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់យើងឱ្យប្រព្រឹត្តទៅដោយរលូន ។ ដើម្បីអនុវត្តការងារនេះបានកាន់តែប្រសើរថែមទៀត ខ្ញុំស្នើសុំឱ្យនាយកដ្ឋានគណនេយ្យ និងនាយកដ្ឋានប្រតិបត្តិការ បន្តបណ្តុះបណ្តាល មន្ត្រីជំនាញនៅសាខារាជធានី-ខេត្តយើង លើផ្នែក ១/- មុខងារប្រព័ន្ធ (Functional) ២/- លំហូរ ការងារ (Workflows) ៣/- រៀបចំឱ្យមានការណែនាំពីរបៀបប្រើប្រាស់ (User guides) និងជាពិសេស ការប្រើប្រាស់ប្រព័ន្ធទូទាត់ផ្ទាល់ (Direct transfer) ជាលក្ខណៈអន្តរធនាគាររវាងទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត ។

**៩/- ការអភិវឌ្ឍប្រព័ន្ធធនាគារស្នូលនិងប្រព័ន្ធជាតិទូទាត់សងប្រាក់** : ប្រព័ន្ធធនាគារស្នូលយើងកំពុងអនុវត្តដោយជោគជ័យ ទាំងនៅទីស្នាក់ការកណ្តាលនិងនៅសាខារាជធានី-ខេត្តមួយចំនួន ។ យើងកំពុងបន្តបំពាក់ប្រព័ន្ធធនាគារស្នូល និងបណ្តុះបណ្តាលមន្ត្រីជំនាញផ្នែកនេះ នៅតាមសាខាខេត្តមួយចំនួនបន្ថែមទៀត ។ ចំពោះការងារអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់ បច្ចុប្បន្ននេះ ប្រតិបត្តិការទូទាត់សងប្រាក់នេះ ដូចជាមូលប្បទានបត្រការបញ្ជាទូទាត់ Credit Card, Debit Card, ATM និងការទូទាត់តាមទូរស័ព្ទចល័តជាដើម កំពុងមានការរីកចម្រើនយ៉ាងខ្លាំងនៅកម្ពុជា ទាំងផ្នែកបណ្តាញសេវានិងផលិតផលហិរញ្ញវត្ថុ ។ ខណៈពេលដែល ទីផ្សារហ៊ុននិងទីផ្សារសញ្ញាប័ណ្ណបានបង្កើតឡើងនេះ នឹងមានឧបករណ៍ហិរញ្ញវត្ថុថ្មីៗថែមទៀត ដូចជាសញ្ញាប័ណ្ណ និងសន្លឹកហ៊ុនជាដើម ដែលជាកម្មវត្ថុនៃការគ្រប់គ្រង ត្រួតពិនិត្យ និងផ្តល់ កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរត្រួតពិនិត្យ និងបញ្ញត្តិករវិស័យហិរញ្ញវត្ថុ ។ ការរីកចម្រើននៃឧបករណ៍និងសេវាហិរញ្ញវត្ថុនេះ ត្រូវស្ថិតនៅក្រោមច្បាប់ ។

ធនាគារជាតិនៃកម្ពុជាកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធជាតិទូទាត់សងប្រាក់ កសាងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធជាតិទូទាត់សងប្រាក់ និងបណ្តុះបណ្តាលមន្ត្រីជំនាញ ដើម្បីគ្រប់គ្រងប្រតិបត្តិការនេះ ដោយមានជំនួយបច្ចេកទេសនិងការឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ។ យើងសង្ឃឹមថា ការងារនេះនឹងបញ្ចប់ និងដាក់ឱ្យដំណើរការនៅឆ្នាំ២០១២ នេះ ។

**១០/- ការងារប្រតិបត្តិការជាមួយសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : អង្គសន្និបាតបានស្តាប់ខ្លឹមសារបទអន្តរាគមន៍ និងអនុសាសន៍របស់អង្គសន្និបាតរួចហើយ ។ ដើម្បីបន្តរួម ចំណែកអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ជំហានទី២ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត យើងបានពង្រីកប្រតិបត្តិការ និងបំពាក់ប្រព័ន្ធធនាគារស្នូលនៅតាមសាខារាជធានី-ខេត្ត ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការបើកគណនី និងគ្រប់គ្រងសេវាគណនីរបស់រដ្ឋ សំដៅជួយសម្រួលចរាចរសាច់ប្រាក់ ប្រតិបត្តិការផ្ទេរសាច់ប្រាក់ ការទូទាត់ពាណិជ្ជកម្ម ការបង់ពន្ធអាករ និងការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលនិងកង កម្លាំងប្រដាប់អាវុធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទូទាំងប្រទេស ឱ្យកាន់តែមានប្រសិទ្ធភាព ថែមទៀត ។

នេះគឺជាការងារអាទិភាពរបស់យើងហើយក៏ជាយន្តការជំរុញការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាលផងដែរ ។ ដូច្នេះ ខ្ញុំសូមស្នើសុំឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ត្រូវពង្រឹងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ដើម្បីសម្រួលការដាក់ឱ្យចរាចរប្រាក់រៀលឱ្យប្រព្រឹត្តទៅដោយរលូន និងកាន់តែទូលំទូលាយថែមទៀត ។

**១១/- ការងារគ្រប់គ្រងនិងបណ្តុះបណ្តាលមន្ត្រីបុគ្គលិក** : ឯកឧត្តម ស៊ុំ សន្និសិទ្ធបានអធិប្បាយអំពីសារៈសំខាន់នៃការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ស្ថាប័នមួយឬប្រទេសជាតិមួយ ជាពិសេស ធនធានមនុស្ស និងសមត្ថភាពជំនាញទាក់ទងនឹងឧស្សាហកម្មធនាគារនិងហិរញ្ញវត្ថុ ។ បច្ចុប្បន្ន មន្ត្រីយើងមានសមត្ថភាពស្រូបយកចំណេះដឹងថ្មីៗទាក់ទងទៅនឹងការត្រួតពិនិត្យ ការវិនិយោគ ការគ្រប់គ្រងហានិភ័យ និងការងារផ្សេងទៀត ។ ទស្សនទានទាំងនេះថ្មី និងមានសារៈសំខាន់ណាស់សម្រាប់មន្ត្រីធនាគារជាតិនៃកម្ពុជា ជាពិសេស សម្រាប់អ្នកត្រួតពិនិត្យ បញ្ញត្តិករ និងប្រតិបត្តិករ ដើម្បីយកទៅអនុវត្តឱ្យស្របតាមស្តង់ដារអន្តរជាតិ ។

ខ្ញុំក៏សូមបញ្ជាក់ថា ធនធានមនុស្សគឺជាកត្តាកំណត់ជោគជ័យនៃការងាររបស់យើងលើគ្រប់ផ្នែក ។ ថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិករបស់យើងបានចូលនិវត្តន៍ជាបណ្តើរៗ ។ ការដាក់ឱ្យចូលនិវត្តន៍នេះ គឺជាកាតព្វកិច្ចតាមផ្លូវច្បាប់ដែលយើងត្រូវតែគោរព ។ ទន្ទឹមនឹងការចូលនិវត្តន៍ យើងត្រូវពិចារណាបណ្តុះបណ្តាលកម្លាំងបន្តវេនជាប់ជាប្រចាំ ដើម្បីបន្តនិរន្តរភាព និងស្ថិរភាព ការងាររបស់យើងនៅពេលអនាគត ។

រយៈកាលកន្លងមក ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមវគ្គសិក្សារយៈពេលវែង និងខ្លី ទាំងក្នុងនិងក្រៅប្រទេស ក្នុងគោលបំណងលើកកម្ពស់សមត្ថភាពមុខជំនាញ ឯកទេស ភាសាបរទេស វិន័យការងារ និងស្មារតីទទួលខុសត្រូវចំពោះការងារ ជាពិសេស ស្មារតីចេះអភិវឌ្ឍខ្លួនឯងនៅកន្លែងការងារ ។ នេះគឺជារបៀបធ្វើការបណ្តើរ រៀនសូត្របណ្តើរ ។ ការអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជាត្រូវធ្វើជាប្រចាំនៅទីកន្លែងទាំងផ្នែក ជំនាញ (IQ) និងផ្នែកគុណធម៌ (EQ) ដើម្បីជ្រើសរើសមន្ត្រីបន្តវេននៅពេលអនាគត ។

បច្ចុប្បន្នធនាគារជាតិនៃកម្ពុជាកាន់តែមានទំនាក់ទំនងអន្តរជាតិយ៉ាងសកម្មនៅក្នុងតំបន់និងឆាកអន្តរជាតិ។ យើងមានដៃគូអភិវឌ្ឍក្នុងតំបន់និងអន្តរជាតិ ដូចជា មជ្ឈមណ្ឌល បណ្តុះបណ្តាល IMF, ADB, WB, មជ្ឈមណ្ឌល SEACEN, ASEAN, ASEAN+3 និង ការបណ្តុះបណ្តាលជាលក្ខណៈទ្វេភាគីជាមួយធនាគារកណ្តាលនៅតំបន់អឺរ៉ុបមានធនាគារកណ្តាលបារាំង អាល្លឺម៉ង់ និងលុចហ្សំបួរ និងនៅតំបន់អាស៊ីមានធនាគារកណ្តាលថៃ ម៉ាឡេស៊ី កូរ៉េ វៀតណាម ឡាវ និងម៉ុងហ្គោលីជាដើម ។ ដូច្នេះ សូមឱ្យមន្ត្រីបុគ្គលិកយើងខិតខំសិក្សា រៀនសូត្របន្ថែម ដើម្បីដើរឱ្យទាន់សភាពការណ៍រីកចម្រើននៃសេដ្ឋកិច្ច និងមានភាពម្ចាស់ការ ក្នុងការគ្រប់គ្រងធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធធនាគារនៅកម្ពុជា ឱ្យកាន់តែរីកចម្រើនថែមទៀត។

**១២/- ការងារសហប្រតិបត្តិការអន្តរជាតិ** : ការងារនេះមានសារៈសំខាន់ណាស់សម្រាប់ធនាគារជាតិនៃកម្ពុជាដើម្បី : (១). ពង្រឹងកិច្ចសហប្រតិបត្តិការជាមិត្តភាពជាមួយស្ថាប័ន ហិរញ្ញវត្ថុអន្តរជាតិ ដូចជា IMF, ADB, WB និងធនាគារកណ្តាលក្នុងតំបន់និងពិភពលោក (២). លើកកម្ពស់កិត្យានុភាព និងតួនាទីធនាគារជាតិនៃកម្ពុជានៅក្នុងតំបន់និងឆាកអន្តរជាតិ (៣). ជំរុញការធ្វើសមាហរណកម្មវិស័យធនាគារនៅកម្ពុជាចូលទៅក្នុងតំបន់ និងពិភពលោក និង (៤). ធ្វើជាវេទិកាថ្នាក់តំបន់សម្រាប់ធ្វើការបណ្តុះបណ្តាលឯកទេសកម្មដល់មន្ត្រីជំនាញ និងផ្លាស់ប្តូរយោបល់ពីការងារគ្រប់គ្រងធនាគារកណ្តាល និងការដឹកនាំនយោបាយរូបិយវត្ថុឆ្ពោះទៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាតិនិងតំបន់ ។

ធនាគារជាតិនៃកម្ពុជា នឹងចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃក្រុមប្រទេសនិយាយ

ភាសាបារាំង (Francophone) នៅប្រទេសម៉ូរីស ចាប់ពីថ្ងៃទី២៣-២៦ ខែឧសភា ឆ្នាំ២០១២ ខាងមុខនេះ ។ តាមរយៈកិច្ចប្រជុំនេះ និងកិច្ចប្រជុំផ្សេងទៀតធ្វើឱ្យប្រទេសកម្ពុជា មានលក្ខណៈសមាហរណកម្មចូលទៅក្នុងតំបន់ និងពិភពលោក ។

**១៣/- ការងារសហប្រតិបត្តិការអាស៊ាននិងអាស៊ាន+៣**

ខណៈដែលប្រទេសកម្ពុជាបានទទួលវេនជាប្រធានអាស៊ាននៅឆ្នាំ២០១២នេះរាជរដ្ឋាភិបាលបានប្រកាសថា រាល់កិច្ចប្រជុំអាស៊ានត្រូវធ្វើឡើងក្រោមប្រធានបទ "អាស៊ានគឺជាសហគមន៍តែមួយ និងមានវាសនាតែមួយដូចគ្នា" ។ នៅឆ្នាំ២០១២នេះ ធនាគារជាតិនៃកម្ពុជានឹងត្រូវធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំចំនួន៣ គឺ៖

១)-កិច្ចប្រជុំថ្នាក់បច្ចេកទេសអាស៊ាននិងអាស៊ាន+៣ ចាប់ពី ថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១២ នៅខេត្តសៀមរាប

២)-កិច្ចប្រជុំថ្នាក់ទេសា-ភិបាលរងធនាគារកណ្តាលអាស៊ានលើកទី២០ (ACDM) នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ និង

៣)-កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៨ (ACGM) នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ និងកិច្ចប្រជុំពាក់ព័ន្ធមួយចំនួនទៀតនៅទីក្រុងភ្នំពេញ ។

ទន្ទឹមនឹងពេលនោះ ធនាគារជាតិនៃកម្ពុជានឹងត្រូវធ្វើជាម្ចាស់ផ្ទះរៀបចំសិក្ខាសាលារបស់មជ្ឈមណ្ឌល SEACEN ស្តីពីការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុនិងម៉ាក្រូសេដ្ឋកិច្ច ចាប់ពីថ្ងៃ ទី១៨-២៤ ខែមីនា ឆ្នាំ២០១២ នៅខេត្តសៀមរាប ព្រមទាំងសន្និបាតនិងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃសមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិច ហៅកាត់ថា APRACA ផងដែរ ចាប់ពីថ្ងៃទី២៩ ខែឧសភា ដល់ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១២ នៅខេត្តសៀមរាប ។

ដើម្បីត្រៀមលក្ខណៈរៀបចំកិច្ចប្រជុំទាំងនេះឱ្យប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ខ្ញុំសូមស្នើសុំឱ្យបណ្តុះបណ្តាលនិងសម្រិតសម្រាំងធនធានមនុស្ស បណ្តុះបណ្តាល មន្ត្រីបង្គោលទទួលបន្ទុកការងារនេះ បង្កើតក្រុមការងារ និងសហការជាមួយក្រសួង-ស្ថាប័ន ផ្សេងទៀត ដើម្បីជាកិច្ចដំណើរការ ។

**១៤/- ការងារអគ្គលេខាធិការងារសមាគមមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា** : ឯកឧត្តម ថា យ៉ាវ និងលោកស្រី អ៊ុច សុខុម បានអធិប្បាយនិងពន្យល់ច្បាស់លាស់ហើយពីការងារនេះ ។ ការងារអគ្គលេខា គឺជាការងារបច្ចេកទេសហើយត្រូវការទាំងផ្នែកជំនាញនិងស្មារតីទទួលខុសត្រូវ និងតស៊ូអត់ធ្មត់ចំពោះការងារ ។ ដូច្នេះ ដើម្បីបង្កើនប្រសិទ្ធភាពការងារ តម្រូវឱ្យមន្ត្រីទាំងអស់ បន្តប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ សីលធម៌ វិន័យការងារ និងគោរពតាមការចាត់តាំងបន្ថែមទៀត ។

ចំពោះការងារសមាគមមន្ត្រីបុគ្គលិកយើង កន្លងមក សមាគមយើងបានបំពេញភារកិច្ច ល្អប្រសើរហើយ ។ ខ្ញុំសូមថ្លែងការកោតសរសើរ ។ ដើម្បីពង្រឹងសាមគ្គីភាពផ្ទៃក្នុង និងក្តាប់ បានពីការលំបាករបស់មន្ត្រីបុគ្គលិកយើង ខ្ញុំស្នើសុំឱ្យសមាគមចាត់តាំងឱ្យមានតំណាងបុគ្គលិកសមាគមជាប្រចាំ និងមន្ត្រីដែលបានចូលនិវត្តន៍នៅតាមនាយកដ្ឋាន ឬ អង្គភាពរបស់ខ្លួន ដើម្បីងាយស្រួលក្នុងការទំនាក់ទំនង និងរៀបចំកម្មវិធីប្រជុំជីវភាពសមាជិកនៅតាមនាយកដ្ឋាន ឬ អង្គភាពរបស់ខ្លួនជាទៀងទាត់ ត្រូវបន្តពង្រឹងសាមគ្គីភាពផ្ទៃក្នុងជាភាតរភាព និងជួយឧបត្ថម្ភគ្នាទៅវិញទៅមកក្នុងពេលមានការលំបាក ជាពិសេស ត្រូវយកចិត្តទុកដាក់ពីបញ្ហាសុខភាព និងការលំបាកជាក់ស្តែងបន្ថែមទៀត ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា**

ខ្លឹមសារដែលខ្ញុំបានលើកឡើងខាងលើនេះ សុទ្ធតែជាការងាររបស់ធនាគារជាតិនៃកម្ពុជាដែលយើងត្រូវអនុវត្តចំពោះមុខ រយៈពេលមធ្យមនិងវែងនៅពេលអនាគត ដើម្បីពង្រឹង ប្រព័ន្ធធនាគារទាំងមូលឱ្យកាន់តែមានសុវត្ថិភាព ប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មខ្ពស់ទៅក្នុងតំបន់ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។ ខ្ញុំសង្ឃឹមថា លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាទាំងអស់ នឹងបន្តការខិតខំប្រឹងប្រែងអនុវត្តទិសដៅភារកិច្ចទាំងឡាយឱ្យសម្រេចបានជោគជ័យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមចំណែកពង្រឹងប្រព័ន្ធធនាគារ និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យមានការរីកចម្រើនប្រកបដោយចីរភាព ។

**មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើនូវមតិមួយចំនួនដូចខាងក្រោម ៖**

១/-ត្រូវយកស្មារតីនៃអង្គសន្និបាតរបស់យើងទៅបន្តផ្សព្វផ្សាយនៅតាមនាយកដ្ឋាន និងអង្គភាពរៀងៗខ្លួន និងអនុវត្តចំពោះការងារប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

២/-រៀបចំកសាងសារមន្ទីររូបិយវត្ថុជាតិមួយដើម្បីចងក្រងប្រវត្តិនៃការរីកចម្រើននៃប្រព័ន្ធ ធនាគារ និងរចនាសម្ព័ន្ធរូបិយវត្ថុនៅកម្ពុជា ទុកសម្រាប់សាធារណជនទូទៅសិក្សាស្វែងយល់ និង

៣/-ជំរុញដំណើរការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ឱ្យទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០** របស់រាជរដ្ឋាភិបាលឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មជាមួយប្រទេសក្នុងតំបន់និងពិភពលោក ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលយ៉ាងច្រើនសម្រាប់ធនាគារជាតិនៃកម្ពុជា និងកសាងប្រព័ន្ធធនាគារឱ្យទទួលបានជំនឿទុកចិត្តពីសាធារណជនជាតិ និងអន្តរជាតិ ។ ដើម្បីសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ខ្ញុំសូមស្នើសុំឱ្យមន្ត្រីបុគ្គលិក ធនាគារជាតិនៃកម្ពុជាបន្តស្មារតីរួមសាមគ្គី សហការគ្នាជាប្រពៃណី និងទទួលខុសត្រូវចំពោះការងារ ដើម្បីរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗថែមទៀត និងកាន់តែមានប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតតាំងពីដើមរហូតដល់ចប់ និងសូមជូនពរ ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.............................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា
## នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២

**សូមគោរព :**

- **គណៈអធិបតី**
- **លោក Arnaud de VILLEPOIX ជំនាញការ IMF ប្រចាំនៅធនាគារជាតិនៃកម្ពុជា**
- **លោក Robert Beerens ជំនាញការនៅធនាគារជាតិនៃកម្ពុជា**
- **លោក Lachlan Fleming ជំនាញការនៅធនាគារជាតិនៃកម្ពុជា**
- **លោក Ye-Hong Ahn ជំនាញការធនាគារកណ្តាលកូរ៉េ នៅធនាគារជាតិនៃកម្ពុជា**
- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា ជាមួយលោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា នាពេលនេះ ។ ជារៀងរាល់ឆ្នាំ ធនាគារជាតិនៃកម្ពុជាយើងតែងតែរៀបចំប្រារព្ធពិធីនេះឡើង ដើម្បីផ្សព្វផ្សាយ និងអបអរសាទរចំពោះលទ្ធផលការងាររបស់ខ្លួនដែលសម្រេចបាន និងដើម្បីបង្កបរិយាកាសឱ្យមន្ត្រីបុគ្គលិករបស់យើងទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខារាជធានី-ខេត្ត បានជួបប្រាស្រ័យទាក់ទងគ្នាទាំងផ្នែកការងារនិងទំនាក់ទំនងសង្គមឱ្យកាន់តែជិតស្និទ្ធថែមទៀត ។ សន្និបាតយើងថ្ងៃនេះត្រូវបានរៀបចំឡើង បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៣ កាលពីដើមខែមិថុនាកន្លងមក ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណនិងកោតសរសើរយ៉ាងខ្លាំង ចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ កសាងសមិទ្ធផលជាច្រើនជូនធនាគារជាតិនៃកម្ពុជា និងរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើនប្រកបដោយមានសុវត្ថិភាព និងមានប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រដ្ឋាភិបាល ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបថា សន្និបាតរបស់យើងថ្ងៃនេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយពីលទ្ធផលការងារសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជា នៅឆមាសទី១ ឆ្នាំ២០១២ ដូចតទៅ ៖

## I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា

តាមការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅឆមាសទី១ ឆ្នាំ២០១២នេះ ស្ថានភាពសេដ្ឋកិច្ចពិភពលោកមានស្ថិរភាពជាបង្គួរ ដោយសារការងើបឡើងវិញបន្តិចម្តងៗនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក ការខិតខំដោះស្រាយវិបត្តិបំណុលសាធារណៈនៅតំបន់ប្រាក់អឺរ៉ូ ការថយចុះនៃសម្ពាធអតិផរណា និងការស្តារឡើងវិញកាន់តែប្រសើរនៃប្រព័ន្ធហិរញ្ញវត្ថុសកល បន្ទាប់ពីអាជ្ញាធរបានចាត់វិធានការដោះស្រាយវិបត្តិកន្លងមក ។

ស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០១២នេះ នឹងមានកំណើន ៣,៥% ធៀបនឹង ៣,៩% នៅឆ្នាំ២០១១ ។ ស្ថានភាពសេដ្ឋកិច្ចនៅសហគមន៍អឺរ៉ុបអាចមាននិន្នាការធ្លាក់ចុះក្នុងកម្រិតមួយទាប ខណៈដែលប្រទេសជឿនលឿនមួយចំនួននៅក្រៅតំបន់អឺរ៉ុប រួមទាំងប្រទេសជប៉ុនផងកំពុងប្រឈមនឹងកំណើនទាបនៅឡើយ ។ សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានកំណើន ២,១% ធៀបនឹងកំណើន ១,៧% នាឆ្នាំ២០១១ ។ ចំពោះប្រទេសឧស្សាហកម្មនៅអាស៊ី អាចនឹងមានកំណើន ២,២% គឺខ្ពស់ជាងកម្រិត -០,២% នៅឆ្នាំ២០១១ ក្នុងនោះប្រទេសអូស្ត្រាលីមានកំណើន ៣% ធៀបនឹង ២% ឆ្នាំ២០១១ និងជប៉ុនមានកំណើន ២% ធៀបនឹង -០,៧% ឆ្នាំ២០១១ ។

ចំណែកឯប្រទេសកំពុងអភិវឌ្ឍន៍និងកំពុងងើបឡើងមានកំណើន ៥,៧% ធៀបនឹង ៦,២% ឆ្នាំ២០១១ ក្នុងនោះសេដ្ឋកិច្ចប្រទេសចិនត្រូវបានរំពឹងថានឹងមានកំណើន ៨,២% ធៀបនឹង ៩,២% នាឆ្នាំ២០១១ ។ ទន្ទឹមនោះ ប្រទេសកូរ៉េនិងតៃវ៉ាន់ដែលជាដៃគូពាណិជ្ជកម្មនិងវិនិយោគសំខាន់សម្រាប់កម្ពុជា ត្រូវបានរំពឹងថាមានកំណើន ៣,៥% និង ៣,៦% រៀងគ្នា ។ សេដ្ឋកិច្ចអាស៊ាននឹងមានកំណើន ៥,២% ធៀបនឹង ៤,៦% នៅឆ្នាំ២០១១ ។ ភាពល្អប្រសើរនេះ ដោយសារតំបន់អាស៊ីមានមូលដ្ឋានសេដ្ឋកិច្ចរឹងមាំ និងបានអនុវត្តគោលនយោបាយសារពើពន្ធនិងរូបិយវត្ថុទន់ភ្លន់ ដែលជារនាំងទប់ស្កាត់ការឆ្លងរាលដាលនៃវិបត្តិទីផ្សារហិរញ្ញវត្ថុ ។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ បានបន្តកើនឡើងក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ។ តាមការព្យាករណ៍របស់រាជរដ្ឋាភិបាលរំពឹងថា នៅឆ្នាំ២០១២នេះ កំណើនសេដ្ឋកិច្ចនឹងកើនឡើងប្រមាណ ៧% ធៀបនឹង ៧,១% នៅឆ្នាំ២០១១ ។ កំណើននេះគាំទ្រដោយវិស័យកសិកម្ម ទេសចរណ៍ កាត់ដេរ និងវិនិយោគផ្ទាល់បរទេស គួបផ្សំនឹងការអនុវត្តគោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើពិពិធកម្មវិស័យផលិតកម្ម ជាពិសេសវិស័យកសិកម្ម និងពិពិធកម្មទីផ្សារនាំចេញផង ពិតជាបានរួមចំណែកគាំទ្រដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ។

## II/- លទ្ធផលការងារសំខាន់ៗដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន

ដើម្បីរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានខិតខំបំពេញតួនាទីរបស់ខ្លួន ក្នុងការរក្សាស្ថិរភាពថ្លៃប្រកបដោយប្រសិទ្ធភាព ដោយរក្សាបាននូវស្ថិរភាពនៃតម្លៃប្រាក់រៀល និងអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក និងគ្រប់គ្រងអត្រាអតិផរណាឱ្យមានកម្រិតទាប ប្រែប្រួលក្នុងកម្រិតមួយអាចគ្រប់គ្រងបាន ។ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ជារួម ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅតែរក្សាស្ថិរភាពល្អប្រសើរ សម្រាប់គាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ ។

សមិទ្ធផលទាំងនេះអាចឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗ ដូចខាងក្រោម ៖

នៅក្នុងឆមាសទី១ ឆ្នាំ២០១២នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារបានឡើងថ្លៃប្រមាណ ០,២% ធៀបនឹងខែមិថុនា នៅឆ្នាំ២០១១ ។ អត្រាអតិផរណាមាននិន្នាការថយចុះគួរឱ្យកត់សម្គាល់ ពី ៥,៨% នៅខែមករា មក ៣,១% នៅខែមិថុនា ។ រូបិយវត្ថុទូទៅ (M2) មានកំណើនឆ្នាំលើឆ្នាំ ១៣,៤% ដោយភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុមានកម្រិតប្រមាណ ៤៧% នៅខែមិថុនា ឆ្នាំ២០១២ ធៀបនឹង ៤២% នាគ្រាដូចគ្នានៅឆ្នាំមុន ។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងរហូតដល់ ៣.៣០៣ លានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបានចំនួនប្រមាណ ៤,៥ខែ ។ ការគ្រប់គ្រងទុនបម្រុងត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន ស្របតាមភាពរឹងមាំនៃមូលដ្ឋានសេដ្ឋកិច្ចជាតិ ។ ស្ថិរភាពថ្លៃនិងតម្លៃប្រាក់រៀលបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនទូទៅចំពោះសេដ្ឋកិច្ចកម្ពុជា ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ហើយសម្រេចបានលទ្ធផលល្អប្រសើរ ដូចខាងក្រោម ៖

**១/- វិស័យធនាគារ** : វិស័យនេះមានការអភិវឌ្ឍនិងរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ និងបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ផ្នែកវិសាលភាពនាពេលបច្ចុប្បន្ននេះ ធនាគារពាណិជ្ជមានចំនួន៣២ ធនាគារឯកទេសចំនួន៧ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣២ ក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៧ ត្រូវបានអនុញ្ញាតឱ្យទទួលប្រាក់បញ្ញើពីសាធារណជន ប្រតិបត្តិករឥណទានជនបទដែលបានចុះបញ្ជីចំនួន៣០ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន១ តតិយភាគីចំនួន១១ ការិយាល័យព័ត៌មានឥណទានចំនួន១ និងអាជីវកម្មប្តូរប្រាក់ដែលមានអាជ្ញាបណ្ណចំនួន ៤៧ និងបានចុះបញ្ជីចំនួន ១.៥១២ ។

ចំពោះទំហំប្រតិបត្តិការវិញ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារបានកើនឡើង ២២% និងឥណទានដល់វិស័យឯកជនបានកើនឡើង ៣៣% ធៀបនឹងគ្រាដូចគ្នានៅឆ្នាំ២០១១ ។ ចំនួនអ្នកផ្ញើប្រាក់កើនដល់ ១.៣៦៩.០០០ នាក់ ធៀបនឹង ១.១៦៤.០០០ នាក់ និងអ្នកខ្ចីឥណទានកើនដល់ ៤៤៣.០០០ នាក់ ធៀបនឹង ២៨៦.០០០ នាក់ ក្នុងគ្រាដូចគ្នានៅឆ្នាំ២០១១ ។ ការវិវត្តរីកចម្រើននេះគួបផ្សំនឹងការអនុវត្តវិធានការប្រុងប្រយ័ត្នផងនោះ បានធ្វើឱ្យឥណទានមិនដំណើរការ (NPL) ថយចុះជាលំដាប់មកត្រឹម ២,៤% នៃកញ្ចប់ឥណទានសរុប ។

ប្រការដែលគួរឱ្យកត់សម្គាល់នៅដើមឆ្នាំ២០១២នេះ គ្រឹះស្ថានធនាគារបានពង្រីកបណ្តាញសាខារបស់ខ្លួន ១១កន្លែងនៅក្នុងប្រទេស និងបានបើកការិយាល័យតំណាងរបស់ខ្លួននៅបរទេស គឺប្រទេសឡាវនិងភូមាផងដែរ ។ ចំពោះផលិតផលហិរញ្ញវត្ថុនៅក្នុងវិស័យធនាគារបានបន្តរីកចម្រើនជាលំដាប់ ដូចជាម៉ាស៊ីន ATM បច្ចុប្បន្នមានចំនួន ៦១៣កន្លែង រួមទាំងសេវាបណ្ណឥណពន្ធ, បណ្ណឥណទាន, សេវាសន្សំជាមាស, សេវាធនាគារ E-banking, និងប្រតិបត្តិករធនាគារចល័តជាដើម ក៏មានការរីកចម្រើនឥតឈប់ឈរផងដែរ ។

**២/- វិស័យមីក្រូហិរញ្ញវត្ថុ** : មានការរីកចម្រើនយ៉ាងខ្លាំង ត្រូវបានគេចាត់ទុកថាជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ជាក់ស្តែង ចំនួនអតិថិជនបានកើនដល់ ១.៣០០.០០០ នាក់ ធៀបនឹងប្រមាណ ១.១៩៥.០០០ នាក់ និងឥណទានសរុបមានចំនួន ២.៩៩២ ពាន់លានរៀល គឺកើនឡើងប្រមាណ ៤៥,១% ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១១ ។ ប្រាក់បញ្ញើវិញមានចំនួន ៧១៩,២៣ ពាន់លានរៀល ពីអ្នកផ្ញើប្រាក់ចំនួន ៣៦០.៦៧៦ នាក់ ។ អនុបាតឥណទានមិនដំណើរការមានចំនួនតែ ០,៣% ប៉ុណ្ណោះ គិតត្រឹមដំណាច់ឆមាសទី១នេះ ។

ការរីកចម្រើននេះ បានរួមចំណែកអភិវឌ្ឍអាជីវកម្មធុនតូចនិងមធ្យម និងវិស័យកសិកម្មនៅកម្ពុជា ។

**៣/- ការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** : ខណៈដែលវិស័យហិរញ្ញវត្ថុមានភាពប្រទាក់ក្រឡាគ្នា និងប្រឈមនឹងហានិភ័យនៃវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិកម្ម បានពង្រឹងការត្រួតពិនិត្យសុខភាពគ្រឹះស្ថានធនាគារជាប់ជាប្រចាំ តាមរយៈការចុះទៅត្រួតពិនិត្យដល់ទីកន្លែងនិងត្រួតពិនិត្យលើឯកសារ ក្នុងបំណងដើម្បីជួយពង្រឹងអភិបាលកិច្ចល្អនិងភាពរឹងមាំរបស់គ្រឹះស្ថានធនាគារ ។ គិតត្រឹមឆមាសទី១ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន១១ ធនាគារឯកទេសចំនួន២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៥ និងប្រតិបត្តិករឥណទានជនបទចំនួន៣ ។

ជារួម យើងបានពិនិត្យឃើញថា ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារមានភាពល្អប្រសើរ និងគោរពតាមវិធានការប្រុងប្រយ័ត្ន ។ ចំពោះគ្រឹះស្ថានធនាគារមួយចំនួនដែលមានចំណុចខ្វះខាត យើងបានផ្តល់អនុសាសន៍ដើម្បីកែតម្រូវ និងមានវិធានការដោះស្រាយតាមស្ថានភាពជាក់ស្តែងផងដែរ ។

**៤/- ការពង្រឹងអភិបាលកិច្ចល្អ** : ធនាគារជាតិនៃកម្ពុជាបានពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ចឱ្យស្របតាមគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង តាមរយៈការបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា ដាក់ចេញនូវបទប្បញ្ញត្តិនានា និងបណ្តុះបណ្តាលសមត្ថភាពជំនាញរបស់មន្រ្តីបុគ្គលិកនៅតាមសាខារាជធានី-ខេត្ត ។ ជាក់ស្តែង នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចេញផ្សាយរបាយការណ៍សវនកម្មសម្រេចរបស់នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ព្រមទាំងសាខាខេត្តស្វាយរៀង កំពត តាកែវ ក្រចេះ និងកំពង់ឆ្នាំង ព្រមទាំងបានចុះធ្វើសវនកម្មនៅខុទ្ទកាល័យអំពីការគ្រប់គ្រងសម្ភារៈ និងនៅសាខារាជធានី-ខេត្តអំពីដំណើរការនៃប្រព័ន្ធ Flexcube ។

ចំពោះការងារអធិការកិច្ចវិញ យើងបានចុះត្រួតពិនិត្យនៅសាខាធនាគារជាតិនៃកម្ពុជាបានចំនួន៥ ដោយផ្តោតជាសំខាន់ទៅលើការធានាសុវត្ថិភាពឃ្លាំងប្រាក់ ការគ្រប់គ្រងសុវត្ថិភាពឃ្លាំងប្រាក់ ការងារគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តរាល់សេចក្តីណែនាំរបស់នាយកដ្ឋានជំនាញដែលបានដាក់ចុះ ព្រមទាំងពង្រឹងគុណវុឌ្ឍិ វិន័យការងាររបស់មន្រ្តីបុគ្គលិក និងប្រសិទ្ធភាពការងារនៅតាមសាខាឱ្យកាន់តែប្រសើរ ។

**៥/- ការអភិវឌ្ឍទីផ្សារអន្តរធនាគារ** : បច្ចុប្បន្ន យើងកំពុងរៀបចំយន្តការអនុវត្តតាមលក្ខណៈបច្ចេកទេស បណ្តុះបណ្តាលធនធានមនុស្ស កសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និងមូលដ្ឋានគតិយុត្តជាដើម ខណៈដែលទីផ្សារមូលបត្រនិងទីផ្សារទុននៅកម្ពុជាបានដំណើរការនាពេលថ្មីៗនេះ ដើម្បីបង្កើនជំនឿទុកចិត្តនិងឱ្យគ្រឹះស្ថានធនាគារនិងធនាគារខ្ចីគ្នា នៅពេលដែលជួបបញ្ហាខ្វះខាតសន្ទនីយភាព ។

**៦/- ការអភិវឌ្ឍប្រព័ន្ធជាតិទូទាត់** : ក្រោមជំនួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារជាតិនៃកម្ពុជាយើងបានរៀបចំប្រព័ន្ធទូទាត់សងប្រាក់ ដែលមានលក្ខណៈមជ្ឈការ ដើម្បីសម្រួលដល់ការទូទាត់ពាណិជ្ជកម្មឱ្យកាន់តែសម្បូរបែប និងមានប្រសិទ្ធភាព តាមរយៈការប្រើប្រាស់ឧបករណ៍ទូទាត់ផ្សេងៗ ដូចជា មូលប្បទានបត្រនិងការផ្ទេរអេឡិចត្រូនិកជាដើម ។ ដើម្បីសម្រួលប្រតិបត្តិការនេះ ធនាគារជាតិនៃកម្ពុជាបានបំពាក់ Client Module ដល់សមាជិកសភាផាត់ទាត់ចំនួន ៣៨គ្រឹះស្ថាន និងសាខាធនាគារជាតិនៃកម្ពុជាដែលមានសភាផាត់ទាត់ ។

ក្រៅពីនេះ យើងបានរៀបចំក្របខ័ណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងក្រុមហ៊ុន ឬគ្រឹះស្ថានមិនមែនធនាគារ រួមទាំងក្រុមហ៊ុនទូរសព្ទចល័តដែលធ្វើជាអ្នកដំណើរការតតិយភាគីក្នុងការផ្តល់សេវាផ្ទេរប្រាក់ ឬសេវាទូទាត់ផ្សេងៗទៀត ដើម្បីធ្វើប្រតិបត្តិការរបស់ខ្លួនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជាផងដែរ ។

**៧/- ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : ដើម្បីបន្តអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជំហានទី២ យើងបានពង្រឹងប្រតិបត្តិការផ្ទៃក្នុងរបស់ខ្លួន ដោយបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា បណ្តុះបណ្តាលផ្នែកការងារប្រតិបត្តិការនិងជំនាញ IT និងរៀបចំការងារចាត់តាំងមន្ត្រីបុគ្គលិកនៅតាមសាខារាជធានី-ខេត្ត ស្របតាមការងារជាក់ស្តែង ។

ក្រៅពីនេះ យើងបានបន្តតាមដានការអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល (CBS) នៅតាមសាខារាជធានី-ខេត្ត ព្រមទាំងបន្តបណ្តុះបណ្តាលធនធានមនុស្ស ទាំងផ្នែកបច្ចេកទេសនិងការងារគ្រប់គ្រងត្រូវបានពង្រឹង ដើម្បីពង្រឹងការអនុវត្តប្រព័ន្ធនេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

## លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិជាលក្ខណៈទ្វេភាគីនិងពហុភាគីវិញ ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារកណ្តាលនៃប្រទេសក្នុងតំបន់ ហើយសម្រេចបានសមិទ្ធផលដូចតទៅ ៖

**១/- មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)** : ក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានមកបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជាចំនួន ២លើក ។ លើកទី១នៅចុងខែមេសា ដើម្បីពិភាក្សាពីវឌ្ឍនភាពការងារស្ថិតិនិងជញ្ជីងទូទាត់ ការរៀបចំផែនការសកម្មភាព និងអនុសាសន៍ថ្មីស្របតាមស្តង់ដារស្ថិតិរូបិយវត្ថុអន្តរជាតិ ។ លើកទី២ នៅចុងខែឧសភា ឆ្នាំ២០១២នេះ ដើម្បីពិនិត្យការវិវត្តរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ច និងពិភាក្សាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៅឆ្នាំ២០១២ និងឆ្នាំ២០១៣ ដោយផ្តោតសំខាន់លើ (១). ស្ថានភាពរូបិយវត្ថុបច្ចុប្បន្ន និងការព្យាករណ៍ស្ថានភាពរូបិយវត្ថុអនាគត (២). ការគ្រប់គ្រងទុនបម្រុងអន្តរជាតិឆ្នាំ២០១២-២០១៣ (៣). ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១២-២០១៣ និង (៤). បញ្ហាអតិផរណា និងស្ថានភាពបច្ចុប្បន្ននៃក្របខ័ណ្ឌព្យាករសន្ទនីយភាពនៃប្រព័ន្ធធនាគារ។

ជារួម អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានវាយតម្លៃល្អពីស្ថានភាពសេដ្ឋកិច្ចកម្ពុជាជាពិសេសចំពោះសមិទ្ធផលនានាដែលធនាគារជាតិនៃកម្ពុជាខិតខំរក្សាស្ថិរភាពថ្លៃនិងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុក្នុងរយៈពេលខ្លីនិងមធ្យមបានប្រសើរ និងបានជួយគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ ។

**២/- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)** : ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេស ដើម្បីរៀបចំអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់ និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ឱ្យទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ដែលត្រូវបានរាជរដ្ឋាភិបាលប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២ កន្លងទៅនេះ ដើម្បីធ្វើជាមាគ៌ាចង្អុលទិសអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែស៊ីជម្រៅ និងមានកម្រិតសមាហរណកម្មខ្ពស់ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

**៣/- ក្រុមប្រទេសអាស៊ាន (ASEAN)** : ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៨ និងកិច្ចប្រជុំថ្នាក់ទេសាភិបាលរងធនាគារកណ្តាល និងថ្នាក់អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី២០ ព្រមទាំងបានចូលរួមកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀតនៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២៦-២៩ ខែមីនា ឆ្នាំ២០១២ ។

នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២ គណៈប្រតិភូធនាគារជាតិនៃកម្ពុជាក៏បានចូលរួមប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន+៣ លើកទី១៥ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ។ នេះជាកិច្ចប្រជុំលើកដំបូងដែលរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលអាស៊ាន+៣ បានជួបពិភាក្សាគ្នា ដើម្បីចែករំលែកជំនាញនិងបទពិសោធន៍គ្នាទៅវិញទៅមក ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុនិងរូបិយវត្ថុក្នុងតំបន់ ។

**៤/- មជ្ឈមណ្ឌល SEACEN** : កិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌល SEACEN មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវជ្រាវ ។ គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានទៅចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាលធនាគារកណ្តាលស៊ាសិន (BOG) នៅខែកុម្ភៈ ឆ្នាំ២០១២ នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ ។ ក្នុងក្របខ័ណ្ឌស៊ាសិន ធនាគារជាតិនៃកម្ពុជាក៏បានសហការជាមួយធនាគារកណ្តាលអង់គ្លេសធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសិក្ខាសាលាលើកទី៥ ស្តីពី **ការគ្រប់គ្រងនយោបាយរូបិយវត្ថុ** និងម៉ាក្រូសេដ្ឋកិច្ច ចាប់ពីថ្ងៃទី១៨-២៤ ខែមីនា ឆ្នាំ២០១២ នៅខេត្តសៀមរាប ប្រកបដោយជោគជ័យ ។ ក្រៅពីនេះ យើងបានបញ្ជូនមន្ត្រីជំនាញចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងវគ្គសិក្សានានារបស់ស៊ាសិនជាប់ជាប្រចាំ ។

**៥/- ធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone)** : ប្រតិភូធនាគារជាតិនៃកម្ពុជាតែងតែបានទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone) ជារៀងរាល់ឆ្នាំ ដើម្បីផ្លាស់ប្តូរយោបល់និងបទពិសោធន៍ក្នុងការគ្រប់គ្រងប្រតិបត្តិការធនាគារកណ្តាល ការដឹកនាំគោលនយោបាយរូបិយវត្ថុ និងការពង្រឹងកិច្ចសហប្រតិបត្តិការរូបិយវត្ថុ ។ កាលពីថ្ងៃទី២៣-២៦ ខែឧសភា ឆ្នាំ២០១២ គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានអញ្ជើញទៅចូលរួមសន្និសីទប្រចាំឆ្នាំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង លើកទី១៩ នៅប្រទេសម៉ូរីស ។

**៦/- សមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APRACA) :** ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និបាតលើកទី១៨ កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ APRACA លើកទី៦១ និងសន្និសីទថ្នាក់តំបន់ស្តីពី ការពង្រឹងសមត្ថភាពកសិករខ្នាតតូច តាមរយៈភាពច្នៃប្រឌិតនៃហិរញ្ញវត្ថុជនបទ ចាប់ពីថ្ងៃទី៣០ ខែឧសភា ដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១២ នៅខេត្តសៀមរាប ប្រកបដោយជោគជ័យ ។ ធនាគារជាតិនៃកម្ពុជាត្រូវបានមហាសន្និបាតជ្រើសតាំងជាប្រធានសមាគមនេះសម្រាប់អាណត្តិរយៈពេល ២ឆ្នាំ ចាប់ពីខែមិថុនា ឆ្នាំ២០១២ ដល់ខែមិថុនា ឆ្នាំ២០១៤ ។

**៧/- កិច្ចសហប្រតិបត្តិការទ្វេភាគី** មានការរីកចម្រើនជាលំដាប់ ។ យើងបានពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ កូរ៉េ បារាំង វៀតណាម ឡាវ ម៉ាឡេស៊ី ម៉ុងហ្គោលី ឆេក្ញ លុចហ្សំបួរ អាល្លឺម៉ង់ និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ាននិងអាស៊ាន+៣ លើផ្នែកបណ្តុះបណ្តាលធនធានមនុស្សនិងផ្លាស់ប្តូរបច្ចេកទេស ។ នៅខែមីនា ឆ្នាំ២០១២នេះ យើងបានបើកកិច្ចប្រជុំទ្វេភាគី និងចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាចំនួនពីរជាមួយធនាគាររដ្ឋវៀតណាម ៖ ទី១/- អនុស្សារណៈយោគយល់គ្នាស្តីពី ការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង ទី២/- អនុស្សារណៈយោគយល់គ្នាស្តីពី ការបណ្តុះបណ្តាល កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ នៅទីក្រុងភ្នំពេញ ។

**- គណៈអធិបតី**
**- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

សរុបមក សមិទ្ធផលទាំងឡាយដែលយើងសម្រេចបានសព្វថ្ងៃនេះ បានមកពីការខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការចូលរួមសហការពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ដើម្បីជ្រាបពីសមិទ្ធផលលម្អិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍លម្អិតជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានខិតខំប្រឹងប្រែងរួមចំណែកអភិវឌ្ឍធនាគារជាតិនៃកម្ពុជាឱ្យរីកចម្រើន និងសម្រេចបានសមិទ្ធផលជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៅទៀត ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅរយៈពេលមួយថ្ងៃ សូមលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ខិតខំស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារដែលអនុវត្តកន្លងមក និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ ដើម្បីយកទៅអនុវត្តការងាររបស់ខ្លួនឱ្យបានជោគជ័យនិងមានប្រសិទ្ធភាព ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនឹងនេះ សូមឱ្យអង្គសន្និបាតរបស់យើងមាន ដំណើរការប្រកបដោយជោគជ័យ ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា
### នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២

**សូមគោរព :**

- **គណៈអធិបតី**
- **លោក Arnaud de VILLEPOIX ជំនាញការ IMF ប្រចាំនៅធនាគារជាតិនៃកម្ពុជា**
- **លោក Robert Beerens ជំនាញការនៅធនាគារជាតិនៃកម្ពុជា**
- **លោក Ye-Hong Ahn ជំនាញការធនាគារកណ្តាលកូរ៉េ នៅធនាគារជាតិនៃកម្ពុជា**
- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា**

នៅពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារក្នុងឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជារបស់យើងបានឈានដល់ទីបញ្ចប់ ប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយនិងស្និទ្ធស្នាលបំផុត ។ ជារួម ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា សន្និបាតយើងថ្ងៃនេះ ពិតជាបានផ្តល់ខ្លឹមសារសំខាន់ៗចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់គ្នា ។ ខ្ញុំជឿជាក់ថា សមាជិក-សមាជិកានៃអង្គសន្និបាតយើង ពិតជាក្តាប់បានពីខ្លឹមសារសំខាន់ អនុសាសន៍ណែនាំ និងក្តាប់បានទិសដៅការងារយកទៅអនុវត្ត ដើម្បីអភិវឌ្ឍធនាគារជាតិនៃកម្ពុជាឱ្យកាន់តែល្អប្រសើរថែមទៀត ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោក លោកស្រី ដែលបានផ្តល់បទអន្តរាគមន៍និងអនុសាសន៍ល្អៗជូនអង្គសន្និបាតយើង ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះសមាជិក-សមាជិកាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គសន្និបាត និងខិតខំយកចិត្តទុកដាក់ស្តាប់ខ្លឹមសារសំខាន់ៗ ទិសដៅការងារសម្រាប់ឆមាសទី២ និងមានវត្តមានក្នុងអង្គសន្និបាតនេះតាំងពីដើមរហូតដល់ចប់ ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ខ្ញុំបានកត់សម្គាល់ឃើញថា ក្នុងរយៈពេលមួយថ្ងៃនេះ អង្គសន្និបាតរបស់យើងបានប្រព្រឹត្តទៅយ៉ាងសកម្ម ដោយផ្តោតលើចំណុចសំខាន់ៗ ដូចតទៅ ៖

**១/- ស្ថានភាពសេដ្ឋកិច្ច និងសមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជា** : កាលពីព្រឹកមិញនេះ លោកស្រី ស្រី ស៊ីយុត បានជម្រាបជូនអង្គសន្និបាតអំពីសមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជាក្នុងការដឹកនាំនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការងារគណនេយ្យ ការងារ IT ការងារប្រតិបត្តិការជាមួយសាខារាជធានី-ខេត្ត ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការងារសវនកម្មនិងអធិការកិច្ច និងការងារអគ្គលេខាធិការ ជាដើម ។ ការងារទាំងអស់នេះ ពិតជារួមចំណែកក្នុងការពង្រឹងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា សុខភាពប្រព័ន្ធធនាគារទាំងមូល និងការរក្សាស្ថិរភាពថ្លៃនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ។

នៅឆ្នាំ២០១២នេះ កំណើនសេដ្ឋកិច្ចពិភពលោករំពឹងថា មានអត្រាកំណើនទាប និងកំណើនសេដ្ឋកិច្ចនៅតំបន់អឺរ៉ុបអាចមាននិន្នាការធ្លាក់ចុះបន្តិច ។ សេដ្ឋកិច្ចអាស៊ីនៅរក្សាបាននូវភាពរឹងមាំនៃមូលដ្ឋានកំណើនរឹងមាំ ពិសេសប្រទេសចិន ឥណ្ឌា និងឥណ្ឌូណេស៊ី ។ ចំពោះកំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១២នេះ រំពឹងថានឹងមានកំណើន ៧% ប្រហាក់ប្រហែលនឹងឆ្នាំមុនដែរ ។ កំណើននេះទ្រទ្រង់ដោយវិស័យកសិកម្ម ទេសចរណ៍ កាត់ដេរ និងវិនិយោគផ្ទាល់បរទេស ។

ដើម្បីរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឱ្យកាន់តែប្រសើរឡើងថែមទៀត និងគាំទ្រចីរភាពនៃកំណើននេះ ខ្ញុំសូមលើកឡើងនូវមតិខ្លះៗដើម្បីឱ្យមន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាលនិងនៅសាខារាជធានី-ខេត្ត ជ្រាបពីអ្វីដែលធនាគារជាតិនៃកម្ពុជាត្រូវធ្វើនាពេលអនាគត ដូចតទៅ ៖

**២/- ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច** : លោក ហ៊ុយ ណាវី ក៏បានជម្រាបជូនអង្គសន្និបាតរួចហើយដែរ ។ ខ្ញុំពិនិត្យឃើញថា ការងារនេះកន្លងមក មន្ត្រីយើងបានបំពេញបានល្អប្រសើរហើយ ។ ការងារសវនកម្មប្រៀបដូចជាការធ្វើ Medical Checkup ខ្លួនឯង ដើម្បីរកឱ្យឃើញពីចំណុចខ្លាំងនិងចំណុចខ្សោយសម្រាប់កែតម្រូវ ។

សូមអនុវត្តការងារនេះ តាមអនុសាសន៍ណែនាំរបស់លោកអគ្គពិនិត្យដែលបានលើកឡើង ដើម្បីកែលម្អចំណុចខ្វះខាតទាក់ទងនឹងការប្រើលេខសម្ងាត់ (password) និង

លេខសម្គាល់អត្តសញ្ញាណអ្នកប្រើប្រាស់ (user ID) សក្ខីបត្រសម្រាប់ប្រតិបត្តិការបង់ប្រាក់-បើកប្រាក់ ការដឹកជញ្ជូនទំនិញពិសេស និងភារកិច្ចនិងការទទួលខុសត្រូវរបស់មន្ត្រីទទួលបន្ទុក ។ ចំណុចដែលបានលើកឡើងទាំងអស់នេះ គឺទាក់ទងនឹងសុវត្ថិភាពប្រតិបត្តិការធនាគារកណ្តាល។ ការងារនេះមានសារៈសំខាន់ណាស់សម្រាប់វាយតម្លៃពីភាពរឹងមាំ សុវត្ថិភាព និងប្រសិទ្ធភាព នៃប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ស្របតាមគោលការណ៍អភិបាលកិច្ច ។

ដើម្បីបន្តដំណើរការការងារនេះឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពថែមទៀត ខ្ញុំសូមស្នើសុំឱ្យបន្តចុះតាមដានការអនុវត្តតាមអនុសាសន៍ដែលបានលើកឡើង និងរៀបចំយន្តការវាយតម្លៃហានិភ័យប្រតិបត្តិការតាមផ្នែក និងពង្រឹងការងារអធិការកិច្ច ទាំងនៅទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្តបន្តទៀត ។ យើងត្រូវរៀបចំផែនការសកម្មភាព និងកំណត់អាទិភាពតាមលំដាប់លំដោយចំពោះការប្រើប្រាស់ប្រព័ន្ធ Flexcube ។

យើងតែងតែធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញរបស់យើងសម្រាប់ការងារនេះជាប់ជាប្រចាំ ទាំងនៅកន្លែងនិងក្រៅប្រទេស ។ នៅឆ្នាំនេះ យើងនឹងបញ្ជូនមន្ត្រីជំនាញចំនួន ២រូបទៀត ទៅធ្វើកម្មសិក្សានៅធនាគារកណ្តាលលុចហ្សំបួរ ដើម្បីហាត់រៀនការងារជាក់ស្តែង ជាពិសេស ទៅសិក្សាស្វែងយល់ពីរបៀបធ្វើសវនកម្មការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ។

**៣/- ការអភិវឌ្ឍប្រព័ន្ធធនាគារ** : ឯកឧត្តម ប៉ាល់ ប៊ុយបុណ្ណាង បានជម្រាបជូនអង្គសន្និបាតរួចហើយ អំពីការរីកចម្រើននៃវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ ។ សុវត្ថិភាពនិងស្ថិរភាពនៃប្រព័ន្ធធនាគារ គឺជាការងារអាទិភាពដែលយើងត្រូវពង្រឹងជាប់ជាប្រចាំ ទាំងគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ។ ដើម្បីអនុវត្តការងារនេះបានសម្រេច ធនាគារជាតិនៃកម្ពុជាត្រូវធ្វើបច្ចុប្បន្នកម្មប្រព័ន្ធវិភាគរបាយការណ៍ COBRA ទៅជាប្រព័ន្ធត្រួតពិនិត្យលើឯកសារ (Off-site Supervision System) វិញ ។ ប្រព័ន្ធនេះជាប្រព័ន្ធត្រួតពិនិត្យថ្មីផ្អែកលើមូលដ្ឋានហានិភ័យ (Risk-based) ដែលផ្តោតការត្រួតពិនិត្យជាសំខាន់ទៅលើទិន្នន័យហិរញ្ញវត្ថុ ការបញ្ជូនរបាយការណ៍តាមប្រព័ន្ធ internet, ការវិភាគស្ថានភាពហិរញ្ញវត្ថុនិងហានិភ័យ, សាវតារធនាគារ, និងវិធានការកែតម្រូវជាបន្ទាន់ ។ ជាមួយគ្នានេះ យើងត្រូវបន្តលើកកម្ពស់សមត្ថភាពមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករ បន្តកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិឱ្យស្របតាមគោលការណ៍គ្រឹះរបស់គណៈកម្មាធិការទីក្រុងបាសែលផងដែរ រៀបចំវិធីសាស្ត្រនៃការត្រួតពិនិត្យដោយផ្អែកលើទស្សនៈអនាគត (Forward-looking) និងការត្រួតពិនិត្យរួបសរុប (Consolidated) បន្ថែមលើយន្តការត្រួតពិនិត្យបច្ចុប្បន្ន ខណៈពេលដែលទីផ្សារមូលបត្រនិងទីផ្សារទុនត្រូវបានចាប់ផ្តើមដំណើរការនាពេលថ្មីៗកន្លងនេះ ។

ចំពោះវិស័យមីក្រូហិរញ្ញវត្ថុវិញ ក៏មានការរីកចម្រើននិងមានបណ្តាញសេវាដល់ជនបទ ។ ដើម្បីបន្តពង្រឹងនិងពង្រីកវិស័យនេះឱ្យរីកចម្រើនថែមទៀត យើងត្រូវរៀបចំផែនការសកម្មភាព

ឱ្យស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែង ដូចជា ១/- បង្កើនប្រសិទ្ធភាពតួនាទីការិយាល័យឥណទាន ២/- កែលម្អក្របខ័ណ្ឌច្បាប់និងប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣/- បង្កបរិយាកាសប្រកួតប្រជែងលើអត្រាការប្រាក់ សេវានិងផលិតផលហិរញ្ញវត្ថុ និង ៤/- ពង្រីកលទ្ធភាពប្រើប្រាស់ឥណទានចំពោះប្រជាជនដែលមានចំណូលទាបនៅតំបន់ជនបទបន្ថែមទៀត ។

**៤/- ការងារអគ្គបេឡា** : ឯកឧត្តម ថា យ៉ាវ បានជម្រាបជូនអង្គសន្និបាតទាក់ទងនឹងការងារគ្រប់គ្រងបេឡាប្រតិបត្តិការ ការផ្គត់ផ្គង់ធនបត្រ ការគ្រប់គ្រងថែរក្សាការពារឃ្លាំងទ្រព្យសម្បត្តិ និងការដឹកជញ្ជូនធនបត្រ មានការរីកចម្រើនយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ទាំងផ្នែកបរិមាណ និងគុណភាព បន្ទាប់ពីយើងបានកែលម្អសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តឡើងវិញ ។ ការងារអគ្គបេឡា គឺជាការងារបច្ចេកទេសដែលទាមទារទាំងផ្នែកជំនាញ ស្មារតីទទួលខុសត្រូវ ភាពស្មោះត្រង់ និងការតស៊ូអត់ធ្មត់ចំពោះការងារ ។ ដូច្នេះ ដើម្បីបង្កើនប្រសិទ្ធភាពការងារ តម្រូវឱ្យមន្ត្រីទាំងអស់បន្តប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ សីលធម៌ វិន័យការងារ និងគោរពតាមការចាត់តាំងបន្ថែមទៀត ។

ការថែរក្សាសុវត្ថិភាពឃ្លាំងទ្រព្យសម្បត្តិជាតិ តម្រូវឱ្យមន្ត្រីមានវិន័យការងារ ភាពស្មោះត្រង់ និងការទទួលខុសត្រូវច្បាស់លាស់ ក្នុងការទុកដាក់និងគ្រប់គ្រងទ្រព្យសម្បត្តិតាមលក្ខណៈបច្ចេកទេស ព្រមទាំងត្រូវបង្កើនការប្រុងប្រយ័ត្នថែមទៀត ដើម្បីការពារទឹកជំនន់ ។

ចំពោះការពង្រឹងវិន័យការងារ ខ្ញុំសូមឯកភាពតាម ឯកឧត្តម ថា យ៉ាវ ដែលបានលើកឡើង ។ ខ្ញុំស្នើសុំឱ្យគ្រប់អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាទាំងអស់ ត្រូវពង្រឹងវិន័យការងារ និងចាត់តាំងឱ្យមានអ្នកប្រចាំការនៅកន្លែងការងារ នៅរាល់ថ្ងៃចុងសប្តាហ៍និងថ្ងៃបុណ្យ ដើម្បីថែរក្សាការពារនូវសុវត្ថិភាពទ្រព្យសម្បត្តិយើងកុំឱ្យបាត់បង់ ឬបង្ការក្រែងមានហេតុការណ៍ណាមួយកើតឡើងដោយចៃដន្យ អាចដោះស្រាយបានទាន់ពេលវេលា ។

**៥/- ការងារពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ** : ដូច ឯកឧត្តម ស៊ុំ សន្និសិទ្ធ បានជម្រាបជូនអង្គសន្និបាតអញ្ចឹង បញ្ហាស្ថិរភាពហិរញ្ញវត្ថុជារឿងថ្មីសម្រាប់អាជ្ញាធរនៃប្រទេសក្នុងតំបន់និងពិភពលោក ដូច្នេះយើងត្រូវសហការគ្នាពង្រឹង ខណៈដែលវិស័យធនាគារនិងហិរញ្ញវត្ថុកំពុងរីកចម្រើន និងមានភាពប្រទាក់ក្រឡាគ្នា ។ ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ ទាំងផ្នែកបណ្តាញសេវានិងផលិតផលនេះ បានផ្តល់សញ្ញាណពីរ គឺ *១/-* ជួយរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និង *២/-* បានបង្ហាញពីសញ្ញាណថ្មីសម្រាប់អាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិករ ត្រូវបង្កើនការយកចិត្តទុកដាក់គ្រប់គ្រងហានិភ័យទាំងឡាយដែលអាចកើតមានឡើង ដោយសារពិពិធកម្មនៃសេវានិងឧបករណ៍ហិរញ្ញវត្ថុទាំងនេះ ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ខ្ញុំសូមជម្រាបផងដែរថា បច្ចុប្បន្ននេះ វិស័យហិរញ្ញវត្ថុក្នុងប្រទេសអភិវឌ្ឍន៍កំពុងប្រឈមបញ្ហាធំពីរ គឺ ៖

*១-* ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅតែមានលក្ខណៈផុយស្រួយ ដោយសារធនាគារធំៗមួយចំនួននៅតែមានអនុបាតបំណុលខ្ពស់ក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ (leverage) និងគុណភាពទ្រព្យសកម្មស្ថិតនៅក្នុងស្ថានភាពមិនទាន់រឹងមាំ និង

*២-* អតុល្យភាពនៃរចនាសម្ព័ន្ធទ្រង់ទ្រាយធំ (Large structural imbalance) : ដោយសារក្រុមហ៊ុនសាជីវកម្មនិងប្រជាជននៅតែមានបន្ទុកបំណុលខ្ពស់ វិស័យអចលនទ្រព្យនៅប្រទេសមួយចំនួននៅតែមានបញ្ហានៅឡើយ និងកំណើនសេដ្ឋកិច្ចពឹងផ្អែកទាំងស្រុងលើការនាំចេញ ។

ដើម្បីដោះស្រាយបញ្ហាប្រឈមជាហានិភ័យនេះ គឺតម្រូវឱ្យ ៖

*១-* ធនាគារកណ្តាលនៃបណ្តាប្រទេសត្រូវកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិ ដើម្បីពង្រឹងការគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានហានិភ័យជាប្រព័ន្ធ (SIFIs) ឱ្យកាន់តែស៊ីជម្រៅថែមទៀត ។ បទប្បញ្ញត្តិសម្រាប់គ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានហានិភ័យជាប្រព័ន្ធ (SIFIs) ត្រូវមានលក្ខណៈស៊ីជម្រៅ និងមានលក្ខណៈប្រុងប្រយ័ត្នខ្ពស់ ក្នុងនោះក៏ត្រូវយកចិត្តទុកដាក់គ្រប់គ្រងដល់បណ្តាក្រុមហ៊ុនធានារ៉ាប់រងធំៗផងដែរ ។

ខ្ញុំសូមបញ្ជាក់ថា ថ្មីៗនេះ ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) បានកំណត់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធំៗ លំដាប់ពិភពលោកដែលមានហានិភ័យជាប្រព័ន្ធ (G-SIFIs) ចំនួន ២៩ គ្រឹះស្ថាន ក្នុងនោះនៅអាស៊ីមានពីរ គឺ Bank of China នៅប្រទេសចិន និង Mitsubishi UFJ នៅប្រទេសជប៉ុន ។ គោលការណ៍ត្រួតពិនិត្យត្រូវពង្រីកការយកចិត្តទុកដាក់ដល់វិស័យហិរញ្ញវត្ថុមិនមែនធនាគារនិងវិស័យធនាគារស្រមោល (Shadow Banking) ដែលបច្ចុប្បន្នមានប្រតិបត្តិការច្រើនជាងប្រតិបត្តិការរបស់វិស័យធនាគារ ហើយពុំត្រូវបានត្រួតពិនិត្យឱ្យបានហ្មត់ចត់ពីសំណាក់អាជ្ញាធរទេ ។

*២-* ធនាគារកណ្តាលនៃបណ្តាប្រទេសកំណត់និងរៀបចំវិធានការគ្រប់គ្រងធនាគារធំៗក្នុងស្រុករបស់ខ្លួនដែលមានហានិភ័យជាប្រព័ន្ធ (D-SIFIs) ដោយកំណត់ថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងស្រុកធំៗណាខ្លះដែលមានហានិភ័យជាប្រព័ន្ធ និងចាំបាច់ត្រូវរៀបចំវិធានការប្រុងប្រយ័ត្នឱ្យបានហ្មត់ចត់ ដើម្បីកាត់បន្ថយឥទ្ធិពលជាអវិជ្ជមានជាយថាហេតុ នៅពេលធនាគារធំៗនោះដួលរលំ ។

*៣-* ការកែទម្រង់ក្របខ័ណ្ឌបទប្បញ្ញត្តិ : ត្រូវបន្តអនុវត្តដើម្បីពង្រឹងភាពរឹងមាំនិងអភិបាលកិច្ចល្អរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទាំងផ្នែកមីក្រូប្រុងប្រយ័ត្ននិងផ្នែកម៉ាក្រូ

ប្រុងប្រយ័ត្ន តាមរយៈការខិតខំអនុវត្តតាមគោលការណ៍គ្រឹះថ្មីៗរបស់គណៈកម្មាធិការទីក្រុងបាសែល និងរៀបចំឱ្យមានវិធានការសម្រាប់ទប់ទល់និងដោះស្រាយវិបត្តិហិរញ្ញវត្ថុ ។

នៅកម្ពុជា ដើម្បីការពារហានិភ័យក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ តម្រូវឱ្យអាជ្ញាធររៀបចំនូវក្របខ័ណ្ឌបទប្បញ្ញត្តិ ប្រព័ន្ធប្រកាសអាសន្នជាមុន វិធានការការពារ គ្រប់គ្រងនិងដោះស្រាយវិបត្តិ ស្របតាមគោលការណ៍គ្រឹះរបស់គណៈកម្មាធិការទីក្រុងបាសែល ក្នុងក្របខ័ណ្ឌម៉ាក្រូប្រុងប្រយ័ត្ននិងមីក្រូប្រុងប្រយ័ត្ន ។ ទន្ទឹមគ្នានេះ យើងត្រូវបន្តបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករជាប់ជាប្រចាំ ដើម្បីវាយតម្លៃហានិភ័យ បញ្ហាប្រឈម និងការលើកជាវិធានការសម្រាប់ពង្រឹងស្ថិរភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ។ បច្ចុប្បន្ននេះ យើងកំពុងបណ្តុះបណ្តាលសមត្ថភាពក្រុមការងារស្ថិរភាពហិរញ្ញវត្ថុរបស់យើងបណ្តើរ ដើម្បីហាត់រៀនធ្វើការងារនេះបណ្តើរៗ ។

**៦/- ការអភិវឌ្ឍប្រព័ន្ធទូទាត់** : ជាតួនាទីសំខាន់របស់ធនាគារជាតិនៃកម្ពុជា ។ បច្ចុប្បន្ននេះប្រតិបត្តិការទូទាត់សងប្រាក់នេះ ដូចជា មូលប្បទានបត្រ ការបញ្ជាទូទាត់ Credit Card, Debit Card, ATM, Easy Cash និងការទូទាត់តាមទូរសព្ទចល័តជាដើម កំពុងមានការរីកចម្រើនយ៉ាងខ្លាំងនៅកម្ពុជា ទាំងផ្នែកបណ្តាញសេវានិងផលិតផលហិរញ្ញវត្ថុ ទន្ទឹមនឹងការដាក់ឱ្យដំណើរការទីផ្សារហ៊ុននិងទីផ្សារសញ្ញាបណ្ណនាពេលថ្មីៗនេះ ក៏មានឧបករណ៍ហិរញ្ញវត្ថុថ្មីៗថែមទៀត ដូចជា សញ្ញាបណ្ណនិងសន្លឹកហ៊ុនកើតឡើងផងដែរ ។ យើងបានបំពាក់ប្រព័ន្ធ Client Module សម្រាប់ប្រព័ន្ធទូទាត់ដែលមានលក្ខណៈមជ្ឈការ និងបណ្តុះបណ្តាលមន្ត្រីជំនាញពីវិធីប្រើប្រាស់ប្រព័ន្ធនេះដល់ធនាគារជាសមាជិកសភាផាត់ទាត់ ។ ប្រព័ន្ធនេះនឹងត្រូវអនុវត្តនៅឆមាសទី២ ឆ្នាំ២០១២នេះ ។

**៧/- ការងារគ្រប់គ្រងនិងបណ្តុះបណ្តាលមន្ត្រីបុគ្គលិក** : ធនធានមនុស្សគឺជាកត្តាកំណត់ជោគជ័យនៃការងាររបស់យើងលើគ្រប់ផ្នែក ។ យើងធ្វើការបណ្តុះបណ្តាលកម្លាំងបន្តវេនលើផ្នែកជំនាញជាប់ជាប្រចាំ ដើម្បីបន្តនិរន្តរភាព និងស្ថិរភាពការងាររបស់យើងនៅពេលអនាគតខណៈដែលថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិករបស់យើងកំពុងចូលនិវត្តន៍ជាបណ្តើរៗ ។ យើងទើបតែបានបង្កើតក្រុមអ្នកសេដ្ឋកិច្ចវ័យក្មេងសម្រាប់ពិគ្រោះយោបល់ និងធ្វើការជាមួយនឹងតំណាង IMF ប្រចាំនៅកម្ពុជា និងជំនាញការបរទេសនៅធនាគារជាតិនៃកម្ពុជា ។

បច្ចុប្បន្ន យើងជំរុញឱ្យមានការបណ្តុះបណ្តាលគ្រប់រូបភាព ទាំងក្នុងនិងក្រៅប្រទេស ។ ក្នុងប្រទេស យើងបានរៀបចំវគ្គផ្លាស់ប្តូរយោបល់គ្នា និងវគ្គបណ្តុះបណ្តាលផ្សេងៗ និងនៅក្រៅប្រទេស យើងមានដៃគូអភិវឌ្ឍក្នុងតំបន់និងអន្តរជាតិ ដូចជា មជ្ឈមណ្ឌលបណ្តុះបណ្តាល IMF, ADB, WB, មជ្ឈមណ្ឌល SEACEN, ASEAN, ASEAN+3 និងមជ្ឈមណ្ឌល Toronto និងការបណ្តុះបណ្តាលជាលក្ខណៈទ្វេភាគីជាមួយធនាគារកណ្តាលនៅតំបន់អឺរ៉ុប មានធនាគារកណ្តាលបារាំង អាល្លឺម៉ង់ និងលុចហ្សំបួរ និងនៅតំបន់អាស៊ីមានធនាគារកណ្តាលថៃ ម៉ាឡេស៊ី កូរ៉េ វៀតណាម ឡាវ និងម៉ុងហ្គោលីជាដើម ។

ដូច្នេះ សូមឱ្យមន្ត្រីបុគ្គលិកយើងខិតខំសិក្សារៀនសូត្របន្ថែម ដើម្បីដើរឱ្យទាន់សភាពការណ៍រីកចម្រើននៃសេដ្ឋកិច្ច និងមានភាពម្ចាស់ការក្នុងការគ្រប់គ្រងធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធធនាគារនៅកម្ពុជាឱ្យកាន់តែរីកចម្រើនថែមទៀត។

**៨/- ការងារសហប្រតិបត្តិការអន្តរជាតិ** : ការងារនេះមានសារៈសំខាន់ណាស់សម្រាប់ធនាគារជាតិនៃកម្ពុជានិងប្រទេសកម្ពុជា ។ នៅខែវិច្ឆិកា ឆ្នាំ២០១២នេះ ប្រទេសកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន ហើយកាលពីចុងខែមីនាកន្លងទៅនេះ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៨ កិច្ចប្រជុំថ្នាក់ទេសាភិបាលរងអាស៊ាន អាស៊ាន+៣ និងកិច្ចប្រជុំពាក់ព័ន្ធមួយចំនួនទៀត ។

តាមរយៈកិច្ចប្រជុំនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុង :(១). ពង្រឹងកិច្ចសហប្រតិបត្តិការជាមិត្តភាពជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា IMF, ADB, WB និងធនាគារកណ្តាលក្នុងតំបន់និងពិភពលោក (២). លើកកម្ពស់កិត្យានុភាពនិងតួនាទីធនាគារជាតិនៃកម្ពុជានៅក្នុងតំបន់និងឆាកអន្តរជាតិ (៣). ជំរុញការធ្វើសមាហរណកម្មវិស័យធនាគារនៅកម្ពុជាចូលទៅក្នុងតំបន់និងពិភពលោក និង (៤). ធ្វើជាវេទិកាថ្នាក់តំបន់សម្រាប់ធ្វើការបណ្តុះបណ្តាលឯកទេសកម្មដល់មន្ត្រីជំនាញ និងផ្លាស់ប្តូរយោបល់ពីការងារគ្រប់គ្រងធនាគារកណ្តាល និងការដឹកនាំនយោបាយរូបិយវត្ថុ ឆ្ពោះទៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាតិនិងតំបន់ ។

**៩/- ការពង្រឹងប្រតិបត្តិការជាមួយសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : គឺជាយន្តការពង្រឹងប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការបើកគណនីនិងគ្រប់គ្រងសេវាគណនីរបស់រដ្ឋ សំដៅជួយសម្រួលចរាចរសាច់ប្រាក់ ប្រតិបត្តិការផ្ទេរសាច់ប្រាក់ ការទូទាត់ពាណិជ្ជកម្ម ការបង់ពន្ធអាករ និងការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធនិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទូទាំងប្រទេស ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២ ។

ការងារនេះគឺជាការងារអាទិភាពរបស់យើង ហើយក៏ជាយន្តការជំរុញការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាលផងដែរ ។ ដូច្នេះ ខ្ញុំសូមស្នើសុំឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ត្រូវពង្រឹងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន និងសហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងដែនដីរដ្ឋបាល ដើម្បីសម្រួលការដាក់ឱ្យចរាចរប្រាក់រៀល ឱ្យប្រព្រឹត្តទៅដោយរលូន និងកាន់តែទូលំទូលាយថែមទៀត ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា**

ខ្លឹមសារដែលខ្ញុំបានលើកឡើងខាងលើនេះ សុទ្ធតែជាការងាររបស់ធនាគារជាតិនៃកម្ពុជាដែលយើងត្រូវអនុវត្តចំពោះមុខ រយៈពេលមធ្យមនិងវែងនៅពេលអនាគត ដើម្បីពង្រឹង

ប្រព័ន្ធធនាគារទាំងមូលឱ្យប្រព្រឹត្តទៅដោយរលូននិងមានសុវត្ថិភាព ។ ខ្ញុំសង្ឃឹមថា លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាទាំងអស់ នឹងបន្តការខិតខំប្រឹងប្រែងអនុវត្តទិសដៅភារកិច្ចទាំងឡាយឱ្យសម្រេចបានជោគជ័យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមចំណែកពង្រឹងប្រព័ន្ធធនាគារ និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ឱ្យមានការរីកចម្រើនប្រកបដោយចីរភាព ។

មុននឹងបញ្ចប់ ខ្ញុំសូមផ្ដាំផ្ញើនូវមតិមួយចំនួនដូចខាងក្រោម ៖

១/- ត្រូវយកស្មារតីនៃអង្គសន្និបាតរបស់យើងទៅបន្តផ្សព្វផ្សាយ នៅតាមនាយកដ្ឋាន និងអង្គភាពរៀងៗខ្លួននូវខ្លឹមសារនិងអនុសាសន៍ល្អៗ ដើម្បីអនុវត្តចំពោះការងារប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

២/- បន្តអនុវត្តនូវ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០** របស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មជាមួយប្រទេសក្នុងតំបន់និងពិភពលោក ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ជាថ្មីម្ដងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលយ៉ាងច្រើនសម្រាប់ធនាគារជាតិនៃកម្ពុជា និងកសាងប្រព័ន្ធធនាគារឱ្យទទួលបានជំនឿទុកចិត្តពីសាធារណជនជាតិនិងអន្តរជាតិ ។ ដើម្បីសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ខ្ញុំសូមស្នើសុំឱ្យមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាបន្តស្មារតីរួមសាមគ្គី សហការគ្នាជាប្រពៃណី និងទទួលខុសត្រូវចំពោះការងារ ដើម្បីរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗថែមទៀតនិងកាន់តែមានប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតតាំងពីដើមរហូតដល់ចប់ និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ**!

## សុន្ទរកថា
## របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងពិធីសម្ពោធផ្លូវការ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០"

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០១២

៚៚៚❁៙៙៙

- ឯកឧត្តម **ជា ចាន់តូ** អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
- ឯកឧត្តម Kunio Senga អគ្គនាយក នាយកដ្ឋានអាស៊ីអាគ្នេយ៍ នៃធនាគារអភិវឌ្ឍន៍អាស៊ី
- ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ភ្ញៀវកិត្តិយស ជាទីរាប់អាន!

ថ្ងៃនេះខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងសេចក្តីរីករាយជាអនេក ដោយទទួលបាននូវបុព្វសិទ្ធិដ៏ថ្លៃថ្លា ធ្វើជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមជាអធិបតីនៅក្នុងពិធីសម្ពោធផ្លូវការ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០" នាឱកាសដ៏សែនប្រពៃនេះ។ ក្នុងឋានៈនេះ និងក្នុងឋានៈជាប្រធានគណៈកម្មាធិការ គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី ទាំងអស់ ដែលអញ្ជើញមកពីគ្រប់មជ្ឈដ្ឋាននៃក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុនៃផ្នែកឯកជន រួមមានគ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនអចលនទ្រព្យ ព្រមទាំងដៃគូអភិវឌ្ឍន៍និងស្ថាប័ន-អង្គការក្រៅរដ្ឋាភិបាលទាំងអស់ដែលបានចូលរួមក្នុងពិធីដ៏ឱឡារិកនេះ។ បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលជាតួអង្គសំខាន់មួយក្នុងឋានៈជាអនុប្រធានប្រចាំការនៃគណៈកម្មាការធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានការសោកស្តាយ ដោយឯកឧត្តមមានការជាប់រវល់ ហើយមិនបានចូលរួមនៅក្នុងពិធីនេះ។

ជាការពិតណាស់ ដូចអ្វីដែលឯកឧត្តម Kunio Senga និងឯកឧត្តម ជា ចាន់តូ បានមានប្រសាសន៍មុននេះថា វិស័យហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យឯកជន និងធានាចីរភាពនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ បន្ថែមលើអ្វីដែលឯកឧត្តមវាគ្មិនទាំងពីរខាងលើ បានជម្រាបជូន ខ្ញុំសូមបញ្ជាក់បន្ថែមថា រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ដោយបានចាប់ផ្តើមអនុម័ត "**ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០**" នៅឆ្នាំ២០០១ ដែលជាផែនទីមគ្គុទ្ទេសក៍ដំបូងសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុរយៈកាលវែងរបស់កម្ពុជា ហើយឯកសារនេះ ត្រូវបានធ្វើបច្ចុប្បន្នកម្មជា "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥**" នៅឆ្នាំ២០០៧ ដើម្បីតម្រឹមតាមការអនុវត្ត និងសភាពការណ៍ជាក់ស្តែង។ ដោយផ្អែកលើវឌ្ឍនភាពនៃការអនុវត្ត "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥**" និងដើម្បីឆ្លើយតបនឹងការវិវឌ្ឍថ្មីៗនៃបរិស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងប្រទេស ក្នុងតំបន់ និងពិភពលោក រាជរដ្ឋាភិបាលដែលមានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការ បានពិនិត្យឃើញអំពីតម្រូវការធ្វើបច្ចុប្បន្នកម្ម "**យុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥**" ទៅជា "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" ដែលត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ កន្លងទៅនេះ។ ឯកសារយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទាំងនេះ គឺជាឯកសារមានភាពទន់ភ្លន់ដែលអនុញ្ញាតឲ្យយើងអាចធ្វើបច្ចុប្បន្នកម្មបានក្នុងពេលសមស្របទៅតាមស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងវឌ្ឍនភាពនៃវិស័យហិរញ្ញវត្ថុ។

ការធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំធ្វើឡើងដើម្បីឲ្យកិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុអាចដំណើរការស្របតាម "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣**" របស់រាជរដ្ឋាភិបាលកម្ពុជា ដោយទទួលយកសន្និធិនៃសមិទ្ធផលនៃការអនុវត្ត "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥**" និង បានរៀបចំកែសម្រួលតាមរយៈមេរៀននៃការអនុវត្តកំណែទម្រង់កន្លងមក បទពិសោធន៍ពីវិបត្តិហិរញ្ញវត្ថុសកល និងបម្រែបម្រួលចាំបាច់ទាំងឡាយដែលអាចកើតឡើងពីការវិវឌ្ឍដ៏លឿននៃទីផ្សារហិរញ្ញវត្ថុ។ ការធ្វើបច្ចុប្បន្នកម្មនេះ ក៏បានដាក់បញ្ចូលផងដែរនូវគោលការណ៍អភិបាលកិច្ចល្អ ដើម្បីតម្រង់ទិសបរិស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកំពុងមានលក្ខណៈកាន់តែស្មុគស្មាញ និងវិវឌ្ឍន៍ឆាប់រហ័សនាពេលបច្ចុប្បន្ន និងអនាគត។

ម្យ៉ាងវិញទៀត ការធ្វើបច្ចុប្បន្នកម្ម "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០" នេះ ត្រូវបានធ្វើឡើងស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានមានប្រសាសន៍ក្នុងពិធីផ្សព្វផ្សាយ និង

ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវរបាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០១១ ស្ដីពីការអនុវត្ត "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣" កាលពីពេលកន្លងទៅនេះថា÷*"ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវរៀបចំ ឬធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ តាមវិស័យរបស់ខ្លួននីមួយៗ តាមរយៈការពិនិត្យឡើងវិញរាល់គម្រោង ឬកម្មវិធីកំពុងដំណើរការ ព្រមទាំងគម្រោង ឬកម្មវិធីថ្មីៗ ដែលគាំទ្រដោយធនធានពីក្នុងនិងក្រៅប្រទេស ដើម្បីធានាសង្គតិភាព និងអាទិភាព និងទំនាក់ទំនង ផ្សារភ្ជាប់ជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣"។*

*ឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី!*

បទពិសោធន៍ពីវិបត្តិបំណុលជាតិនៅបណ្ដាប្រជាជាតិប្រើប្រាស់ប្រាក់អឺរ៉ូ (Eurozone) ដែលកំពុងកើតមាននាពេលបច្ចុប្បន្នបានផ្ដល់មេរៀនដ៏សំខាន់មួយថា÷ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនបានគ្រប់ជ្រុងជ្រោយ និងខ្វះការប្រមើមើលទុកជាមុនរបស់រាជរដ្ឋាភិបាលអាចធ្វើឱ្យមានវិបត្តិសេដ្ឋកិច្ចជាប្រព័ន្ធធ្ងន់ធ្ងរ។

ដូច្នេះ **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០"** ដែលនឹងត្រូវសម្ពោធដាក់ឱ្យប្រើប្រាស់នាពេលបន្តិចទៀតនេះ គឺជាឯកសារដែលមានលក្ខណៈជាក់ស្ដែង ប្រមើលទុកមុន និងគ្របដណ្ដប់លើគ្រប់វិស័យនៃប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីឆ្លើយតបយ៉ាងសមស្រប និងទាន់ពេលវេលា ចំពោះបញ្ហាប្រឈមថ្មីៗទាំងឡាយដែលអាចកើតមានឡើងជាយថាហេតុ សំដៅទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ជវភាព និងសមធម៌ ឆ្ពោះទៅកាត់បន្ថយភាពក្រីក្រ ដែលជាគោលដៅចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជា ស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា។ *ឯកសារយុទ្ធសាស្ត្រនេះ ផ្ដោតលើទិដ្ឋភាពសំខាន់ៗ ចំនួនបួន រួមមាន (១) វិស័យធនាគារ (២) វិស័យហិរញ្ញវត្ថុមិនមែនធនាគារ (៣) អភិបាលកិច្ចនិងហេដ្ឋារចនាសម្ព័ន្ធ និង (៤) ការកសាងសមត្ថភាព។ ដើម្បីធានាបាននូវការអនុវត្តប្រកបដោយជោគជ័យលើទិដ្ឋភាពទាំងបួននេះ យុទ្ធសាស្ត្រនេះបានរៀបចំជាផែនការអភិវឌ្ឍន៍ជាជំហានៗ តាមវិស័យសំខាន់ៗ ដោយត្រូវបានប្រមូលផ្ដុំជាបីដំណាក់កាលទៅតាមលំដាប់អាទិភាព។*

*ឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី!*

ដោយអនុវត្តតាម **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥"** ក្នុងរយៈកាលកន្លងមកនេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរជាទីមោទនៈ រួមមាន ការពង្រឹងវិស័យធនាគារ ការពង្រីកវិសាលភាពវិស័យធានារ៉ាប់រង និង ជាពិសេស ការចាប់បដិសន្ធិនៃវិស័យថ្មីគឺវិស័យមូលបត្រ និងសោធន។ កំណើនឥណទាន និងប្រាក់បញ្ញើនៅក្នុងប្រព័ន្ធធនាគារ ក៏ដូចជាកំណើននៃវិស័យធានារ៉ាប់រងបានបន្តជវភាពរបស់ខ្លួនទាំងមុនពេល ក្នុងកំឡុងពេល និងក្រោយពេលនៃវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨-២០០៩ កន្លងទៅ។ ទាំងនេះជាសញ្ញាបង្ហាញថា ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាមិនត្រឹមតែមិនទទួល

ផលប៉ះពាល់ធ្ងន់ធ្ងរនៃវិបត្តិហិរញ្ញវត្ថុសកលប៉ុណ្ណោះទេ ប៉ុន្តែបានបន្តគាំទ្រដល់កំណើនសេដ្ឋកិច្ចកម្ពុជាផងដែរ។ ជាក់ស្តែង នៅក្នុងឆ្នាំ២០០៨ អត្រាកំណើនសេដ្ឋកិច្ចមានកម្រិត ៦,៧%។ ក្នុងឆ្នាំ២០០៩ បានធ្លាក់ចុះដល់0,១% ដោយសារឥទ្ធិពលនៃវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះសេដ្ឋកិច្ចសាកល-លោក ប៉ុន្តែបានហក់ឡើងវិញយ៉ាងឆាប់រហ័ស ក្នុងទម្រង់ជាអក្សរវ៉េ "V" នៅក្នុងឆ្នាំ២០១០ និងឆ្នាំ២០១១ មកកម្រិតស្មើ ឬជិតស្មើនឹងចំណុចដៅប្រមាណពី ៦% ទៅ៧,១% ជាមធ្យមសម្រាប់ឆ្នាំនីមួយៗ។ តាមសិមិទ្ធិផលនៃឆមាសទី១ ឆ្នាំ ២០១២ យើងមានសុទិដ្ឋិនិយមថាកំណើនសេដ្ឋកិច្ចនៃកម្ពុជាឆ្នាំ ២០១២ នៅខ្ពស់ដដែលបើសិនគ្មានគ្រោះធម្មជាតិ និងឥទ្ធពលអាក្រក់ពីកលិយុគមកពីក្រៅ។

ដើម្បីឲ្យវិស័យហិរញ្ញវត្ថុបន្តទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចកាន់តែមានប្រសិទ្ធភាព "យុទ្ធសាស្ត្រអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០" បានដាក់បញ្ចូលនូវគោលនយោបាយអភិវឌ្ឍន៍សម្រាប់វិស័យសំខាន់ៗរួមមាន÷

**១.វិស័យធនាគារ÷** ផ្តោតសំខាន់លើការអនុវត្តគោលនយោបាយរូបិយវត្ថុកាន់តែសម្បូរបែប និងពង្រឹងការត្រួតពិនិត្យវិស័យធនាគារ តាមរយៈការពង្រឹងសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការប្រើប្រាស់ប្រាក់រៀល និងកាត់បន្ថយដុល្លារូបនីយកម្មអនុលោមតាមគោលការណ៍ស្នូលបាសែល សម្រាប់ការពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យធនាគារ បង្កើតប្រព័ន្ធឲ្យសញ្ញាជាមុនសម្រាប់ការពារវិបត្តិ ពិចារណាលើការបង្កើតគ្រឹះស្ថានធានាលើប្រាក់បញ្ញើ និងជម្រុញដំណើរការទីផ្សារអន្តរធនាគារ និងទីផ្សាររូបិយវត្ថុ។ លើសពីនេះ ក៏បានកំណត់ផងដែរអំពីការពង្រឹងវិស័យមីក្រូហិរញ្ញវត្ថុឲ្យកាន់តែទូលាយសម្រាប់ប្រជាជនក្រីក្រ អនុវត្តគោលការណ៍ស្នូលបាសែលសម្រាប់ការត្រួតពិនិត្យធនាគារទៅលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាក់ឲ្យអនុវត្តស្តង់ដាររបាយការណ៍រួមសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កែលម្អបទប្បញ្ញត្តិដើម្បីទ្រទ្រង់ពិពិធកម្មផលិតផលមីក្រូហិរញ្ញវត្ថុ កែលម្អប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អភិវឌ្ឍវិស័យទទួលបញ្ចាំឲ្យមានលក្ខណៈជាផ្លូវការ និងពង្រឹងការត្រួតពិនិត្យការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**២.វិស័យហិរញ្ញវត្ថុមិនមែនធនាគារ÷** ផ្តោតលើការអភិវឌ្ឍន៏វិស័យធានារ៉ាប់រងសោធន និងទីផ្សារទុន រួមមាន កែសម្រួលក្របខ័ណ្ឌបទប្បញ្ញត្តិធានារ៉ាប់រង បង្កើតទីផ្សារធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូច ដាក់ឲ្យអនុវត្តបន្ថែមនូវកាតព្វកិច្ចធានារ៉ាប់រង អភិវឌ្ឍប្រព័ន្ធជូនដំណឹងជាមុនសម្រាប់បញ្ញត្តិករធានារ៉ាប់រង ជម្រុញដំណើរការអភិវឌ្ឍបេឡាជាតិ រៀបចំគោលនយោបាយ និងបទប្បញ្ញត្តិដើម្បីអភិវឌ្ឍសោធនស្ម័គ្រចិត្តពីផ្នែកឯកជន ព្រមទាំងជម្រុញការបង្កើតក្រុមហ៊ុនឯកទេសគ្រប់គ្រងសោធនស្ម័គ្រចិត្តពីផ្នែកឯកជន។ ជាមួយគ្នានេះ អភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត ពាក់ព័ន្ធនឹងការក្ស័យធនក្នុងទីផ្សារមូលបត្រ អនុវត្តអភិបាលកិច្ចសាជីវកម្មល្អសម្រាប់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ និងក្រុមហ៊ុនមិនបានចុះបញ្ជីលក់មូលបត្រ ជម្រុញការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណ រៀបចំយន្តការអប់រំអ្នកវិនិយោគ និងដោះ-

ស្រាយវិវាទក្នុងទីផ្សារមូលបត្រ និងពិចារណាលើការបង្កើតវិស័យខុម៉ូឌីធី យន្តការហិរញ្ញប្បទានមូលបត្រ មូលនិធិទ្រព្យអធិបតេយ្យ និងមណ្ឌលអភិវឌ្ឍន៍ហិរញ្ញវត្ថុ។

**៣.អភិបាលកិច្ចនិងហេដ្ឋារចនាសម្ព័ន្ធ÷** កំណត់ពីតម្រូវការនៃការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្ម ការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ការកែលម្អបទប្បញ្ញត្តិគណនេយ្យ និងសវនកម្ម ការដាក់ឱ្យដំណើរការប្រព័ន្ធជាតិផាត់ទាត់ និងទូទាត់ព្រមទាំងការិយាល័យព័ត៌មានឥណទាន ការអភិវឌ្ឍប្រព័ន្ធចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្ម និងការបង្កើតហេដ្ឋារចនាសម្ព័ន្ធផ្នែកច្បាប់ ដើម្បីគាំទ្រដល់វិស័យសេវាកម្មវាយតម្លៃសេវាកម្មអចលនវត្ថុ និងអាជីវកម្មអភិវឌ្ឍន៍លំនៅឋាន។

**៤.ការកសាងសមត្ថភាព÷** កំណត់ពីយុទ្ធសាស្ត្រក្នុងការកសាងសមត្ថភាពជំនាញក្នុងវិស័យហិរញ្ញវត្ថុទាំងមូល ជាពិសេស ការកសាងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុដែលជាប្រការសំខាន់ក្នុងការធានាបាននូវតម្លាភាព និងគណនេយ្យភាពក្នុងទីផ្សារ។

*ឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី!*

ខ្ញុំមានជំនឿមុតមាំថា ការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវ **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០"** នឹងទទួលបានលទ្ធផលកាន់តែល្អប្រសើរ ដើម្បីបន្តអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុដែលមានភាពប្រកួតប្រជែង សមាហរណកម្ម និងមានប្រសិទ្ធភាពក្នុងគោលដៅកៀរគរការសន្សំឱ្យបានច្រើនសម្រាប់ផ្តល់ហិរញ្ញប្បទានដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ទន្ទឹមនឹងនេះ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមលើកទឹកចិត្តឱ្យបណ្តាស្ថាប័នអនុវត្តទាំងក្នុងវិស័យរដ្ឋនិងឯកជន សូមផ្តល់ការគាំទ្រ និង សូមយកចិត្តទុកដាក់ចូលរួមអនុវត្ត **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១ -២០២០"**នេះ ឱ្យបានទទួលជោគជ័យ និងប្រសិទ្ធភាពខ្ពស់ទៅតាមវិស័យរៀងៗខ្លួន។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមសម្តេចតេជោនាយករដ្ឋមន្ត្រី និងក្នុងនាមជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខ្ញុំសូមថ្លែងអំណរគុណចំពោះ គណៈកម្មាធិការដឹកនាំសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដែលមានឯកឧត្តម **ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាប្រធាន ក្រុមការងារបច្ចេកទេសសម្រាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដែលមានឯកឧត្តម **វង្ស សីលវ៉ា** អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន និងក្រុមលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសសម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកដល់ការងារធ្វើបច្ចុប្បន្នកម្ម **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០"**នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសផងដែរចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានផ្តល់ហិរញ្ញប្បទានផ្នែកបច្ចេកទេស។ ទទឹមនឹងនេះ ADB ក៏ផ្តល់ធាតុចូលមានលក្ខណៈជាយុទ្ធសាស្ត្រដល់ការងារធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រនេះ។ ក្នុងន័យនេះខ្ញុំសូមសំដែងអំណរគុណដោយឡែកចំពោះអ្នកជំនាញ ADB គឺលោក Samiuela Tukuafu។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធិពរជ័យជូន ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ដែលមានវត្តមាននៅក្នុងពិធីដ៏អធិកអធមនេះ ប្រកបដោយសុខភាពល្អបរិបូរណ៍ សិរីមង្គល វិបុលសុខ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច និងកិច្ចការធុរកិច្ច។

ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមប្រកាសសម្ពោធ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ “យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០” ចាប់ពីពេលនេះតទៅ៕

*សូមអរគុណ!*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

## សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាអនុប្រធាន គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងក្នុងពិធីសម្ពោធយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ ជាផ្លូវការ
## សណ្ឋាគារ Le Royal ភ្នំពេញ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២

សូមគោរព ៖

- ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្តម Kunio Senga អគ្គនាយកនៃនាយកដ្ឋានអាស៊ីអាគ្នេយ៍នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- លោក Putu Kamayana នាយកធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំនៅកម្ពុជា
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយនិងកិត្តិយសបំផុត ដោយបានមកចូលរួមក្នុងពិធីសម្ពោធជាផ្លូវការនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាលក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ វត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី នាពេលនេះកាន់តែញ៉ាំងឱ្យពិធីនេះប្រព្រឹត្តទៅកាន់តែឱឡារិក អធិកអធម និងមានអត្ថន័យជ្រាលជ្រៅថែមទៀត ។

ឆ្លៀតក្នុងឱកាសនេះ តាងនាមគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានគណៈកម្មាធិការដឹកនាំការរៀបចំនិងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំធនាគារអភិវឌ្ឍន៍អាស៊ី ឯកឧត្តម Kunio Senga លោក Putu Kamayana លោក Samiule Tukuafu និងសហការី ដែលបានគាំទ្រដំណើរការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជារហូតមកដល់បច្ចុប្បន្ន ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះក្រុមការងារបច្ចេកទេសអន្តរក្រសួងរបស់រាជរដ្ឋាភិបាល ដែលចូលរួមចំណែកយ៉ាងសកម្មក្នុងការធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រនេះ ប្រកបដោយជោគជ័យ ។

**- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជាទីគោរព**

**- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី**

ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ជម្រាបពីប្រវត្តិ សារៈសំខាន់ និងសមិទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកន្លងមក ដូចតទៅ៖

**១/- ប្រវត្តិនៃការរៀបចំឯកសារយុទ្ធសាស្ត្រនេះ**

វិស័យហិរញ្ញវត្ថុត្រូវបានគេចាត់ទុកថា ជាធាតុផ្សំមួយដ៏ចាំបាច់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ព្រោះថានៅពេលដែលវិស័យហិរញ្ញវត្ថុមានដំណើរការល្អ មានភាពរឹងមាំ វិស័យនេះជាអន្តរការិយកម្មកៀរគរប្រភពធនធានហិរញ្ញវត្ថុនៅទំនេរសម្រាប់បំពេញតម្រូវការផលិតកម្ម ទ្រទ្រង់ដល់ការរីកចម្រើននៃវិស័យឯកជននិងកំណើនសេដ្ឋកិច្ចជាតិ ប្រកបដោយចីរភាព ។

ដោយយល់ឃើញពីសារៈសំខាន់នេះ នៅឆ្នាំ២០០១ ដោយមានការគាំទ្រផ្នែកជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី រាជរដ្ឋាភិបាលបានអនុម័តចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ធ្វើជាផែនការយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីកំណត់លំដាប់លំដោយ គោលនយោបាយ និងផែនការសកម្មភាពនានា សម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាមួយរឹងមាំ ។ ក្នុងដំណាក់កាលទី១នៃការអនុវត្តយុទ្ធសាស្ត្រនេះ យើងសម្រេចបានសមិទ្ធផលសំខាន់ៗទាក់ទងនឹងវិស័យធនាគារ ធានារ៉ាប់រង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពនៃកំណើនសេដ្ឋកិច្ចជាតិ ។

បន្ទាប់មក នៅឆ្នាំ២០០៦ ក្នុងដំណាក់កាលទី២ ដើម្បីពង្រឹងនិងបន្តនិរន្តរភាពនៃការអភិវឌ្ឍវិស័យនេះឱ្យកាន់តែស៊ីជម្រៅនិងរឹងមាំថែមទៀត រាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ដើម្បីរំកិលទៅអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ ចំគោលដៅ អាទិភាពតាមលំដាប់លំដោយ និងស៊ីចង្វាក់ប្រទាក់ក្រឡាជាមួយវិស័យធនាគារនិងហិរញ្ញវត្ថុ ។ សមិទ្ធផលក្នុងដំណាក់កាលនេះ អាចឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើននៃវិស័យធនាគារ វិស័យមីក្រូហិរញ្ញវត្ថុ វិស័យធានារ៉ាប់រង ស្ថិរភាពអត្រាប្តូរប្រាក់ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច ។

នៅដំណាក់កាលទី៣ ក្នុងឆ្នាំ២០១១ ដោយយល់ឃើញពីសារៈសំខាន់នៃយុទ្ធសាស្ត្រនេះ និងគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការធ្វើពិពិធកម្មនិងទំនើបកម្មសេដ្ឋកិច្ច ដើម្បីលើកកម្ពស់កម្រិតជីវភាពប្រជាជន និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ីធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ស្របតាមផែនការសកម្មភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ របស់រាជរដ្ឋាភិបាល ដើម្បី

បន្តអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយរឹងមាំ និងផ្អែកលើគោលការណ៍ទីផ្សារ ដែលជួយកៀរគរនិងបែងចែកធនធាន រួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពបន្ថែមទៀត ។

ម្យ៉ាងទៀត យុទ្ធសាស្ត្រនេះក៏បានធ្វើបច្ចុប្បន្នកម្មស្របនឹងបរិបទសំខាន់បី គឺ *(១)*- ការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ក្រោមបរិយាកាសអំណោយផលនៃស្ថិរភាពនយោបាយ សន្តិភាព និងសន្តិសុខសង្គមក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក *(២)*- ការប្រែប្រួលនៃស្ថាបត្យកម្មហិរញ្ញវត្ថុអន្តរជាតិ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចពិភពលោកនាពេលថ្មីៗនេះ និង *(៣)*-តម្រូវការអភិក្រមអភិវឌ្ឍន៍ថ្មីៗ ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ចរឹងមាំនិងអន្តរវិស័យរវាងផ្នែកផ្សេងៗនៃសេដ្ឋកិច្ចកម្ពុជា ដែលវិស័យហិរញ្ញវត្ថុដើរតួនាទីគាំទ្រសំខាន់ជាប្រព័ន្ធនិងប្រទាក់ក្រឡាគ្នា ។

## ២/- ខ្លឹមសារនៃការរៀបចំយុទ្ធសាស្ត្រនេះ

ដោយយល់ឃើញពីភាពចាំបាច់និងសារៈសំខាន់ខាងលើ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ដែលមានសមាសភាពអន្តរក្រសួងមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជា ដើម្បីសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ីរៀបចំធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រនេះ ។

ការរៀបចំឯកសារយុទ្ធសាស្ត្រនេះ បានផ្តោតការយកចិត្តទុកដាក់ទៅលើទស្សនវិស័យ គោលបំណង ទិសដៅ អាទិភាពគន្លឹះ និងលំដាប់លំដោយនៃសកម្មភាពកំណែទម្រង់ចាំបាច់នានា ។ ឯកសារយុទ្ធសាស្ត្រនេះមានរចនាសម្ព័ន្ធដូចខាងក្រោមនេះ ៖

- **ជំពូកទី១** ស្តីពីទិដ្ឋភាពទូទៅ :ឆ្លុះបញ្ចាំងអំពីទិដ្ឋភាពរួមនិងបញ្ហាគន្លឹះក្នុងវិស័យហិរញ្ញវត្ថុ
- **ជំពូកទី២** ស្តីពីវិស័យធនាគារ : មានប្រព័ន្ធធនាគារ ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម វិស័យមីក្រូហិរញ្ញវត្ថុ និងភតិសន្យា
- **ជំពូកទី៣** ស្តីពីវិស័យហិរញ្ញវត្ថុមិនមែនធនាគារ:មានវិស័យធានារ៉ាប់រង សោធន និងទីផ្សារទុន
- **ជំពូកទី៤** ស្តីពីអភិបាលកិច្ចនិងរចនាសម្ព័ន្ធទីផ្សារ : មានក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ គណនេយ្យនិងសវនកម្ម ប្រព័ន្ធទូទាត់ ប្រព័ន្ធប្រាតិភោគ និងការិយាល័យព័ត៌មានឥណទាន
- **ជំពូកទី៥** ស្តីពីការកសាងសមត្ថភាពសម្រាប់វិស័យហិរញ្ញវត្ថុ និង
- **ជំពូកទី៦** ស្តីពីផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍឆ្នាំ២០១១-២០២០ ជាបីដំណាក់កាល។

ជារួម ឯកសារយុទ្ធសាស្ត្រនេះមានលក្ខណៈជាផែនការរំកិល និងបានបង្ហាញពីការរីកចម្រើននៃទីផ្សារ បណ្តាញសេវា និងផលិតផលហិរញ្ញវត្ថុថ្មីៗក្នុងប្រព័ន្ធ ហើយក៏ជាមាគ៌ាសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យរឹងមាំ មានលក្ខណៈសមាហរណៈទៅក្នុងតំបន់ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព ស្របតាមគោលនយោបាយរាជរដ្ឋាភិបាល ។

**- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជាទីគោរព**

**- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី**

ការរៀបចំឯកសារយុទ្ធសាស្ត្រនេះ គឺសំដៅឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងវិស័យធនាគារ វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។ បច្ចុប្បន្ន វិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុមានការអភិវឌ្ឍជាងគេក្នុងវិស័យហិរញ្ញវត្ថុ ដែលកំពុងផ្តល់សេវាអន្តរការិយកម្មហិរញ្ញវត្ថុដល់គ្រប់វិស័យ រួមទាំងបន្តផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងដល់គ្រួសារកសិករនៅជនបទ ។ ការអភិវឌ្ឍទីផ្សាររូបិយវត្ថុនិងទីផ្សារទុនក្នុងស្រុកអាចផ្តល់ ៖ *១/-* ប្រភពថ្មីបន្ថែមទៀតក្នុងការកៀងគរមូលនិធិ *២/-* ហិរញ្ញប្បទានសម្រាប់ការវិនិយោគរយៈពេលវែងក្នុងវិស័យកម្មន្តសាល ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ និង *៣/-* ប្រភពទុនសម្រាប់សហគ្រាសធំៗ ។ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារក៏ជាប្រភពទុនមួយទៀតសម្រាប់ជំរុញឱ្យអន្តរការិយកម្មហិរញ្ញវត្ថុកាន់តែមានទំហំធំនិងមានប្រសិទ្ធភាព ។ ក្នុងរយៈពេលវែង គំនិតផ្តួចផ្តើមកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការកសាងសមត្ថភាពនឹងជំរុញឱ្យមានការរីកចម្រើនទាំងវិស័យធនាគារ និងទាំងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ។

ដើម្បីអនុវត្តការងារនេះឱ្យប្រព្រឹត្តទៅដោយរលូននិងទទួលបានជោគជ័យ យើងបានរៀបចំផែនការសកម្មភាពជាជំហានៗ និងជាបីដំណាក់កាលតាមលំដាប់អាទិភាព ដូចខាងក្រោម ៖

- *ដំណាក់កាលទី១ ៖* រយៈកាលខ្លី (២០១១-២០១៤) ផ្តោតសំខាន់លើការពង្រឹងការអនុវត្តគោលនយោបាយរបស់ស្ថាប័ន ដូចជា ការកែទម្រង់ក្របខ័ណ្ឌច្បាប់ ការលើកកម្ពស់ការអនុវត្តច្បាប់ ការកសាងសមត្ថភាពមន្ត្រី បញ្ញត្តិករ និងអ្នកត្រួតពិនិត្យ ការបង្កើតក្រុមការងារចាំបាច់តាមស្ថាប័ន ការបង្កើតហេដ្ឋារចនាសម្ព័ន្ធ បង្កើនប្រសិទ្ធភាពការងារ និងការបង្កើតយន្តការសម្របសម្រួលការងារ និងសហប្រតិបត្តិការដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ។
- *ដំណាក់កាលទី២ ៖* រយៈពេលមធ្យម (២០១៤-២០១៧) ផ្តោតសំខាន់លើការបន្តអនុវត្តគោលនយោបាយរយៈពេលខ្លីដែលពុំអាចសម្រេចបាន ជាពិសេស គោលនយោបាយពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការនិងការងារអន្តរក្រសួង ដូចជាការបង្កើតគណៈកម្មការថ្នាក់ជាតិគ្រប់គ្រងវិបត្តិ ការពង្រឹងការអនុវត្តច្បាប់ និងការត្រួតពិនិត្យរួមជាដើម ។
- *ដំណាក់កាលទី៣ ៖* រយៈពេលវែង (២០១៧-២០២០) ផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយបន្តពីរយៈកាលមធ្យម ការបង្កើតបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុ និងគោលនយោបាយគាំទ្រមួយចំនួន ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែង ទប់ស្កាត់វិបត្តិក្នុងវិស័យហិរញ្ញវត្ថុ ។

ដើម្បីសំយោគធាតុចូលខាងលើ យើងបានបើកកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើកជាច្រើនសា ក្នុងក្របខ័ណ្ឌរវាងក្រុមការងារបច្ចេកទេសនិងធនាគារអភិវឌ្ឍន៍អាស៊ី ។ ជាពិសេស នៅពីថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ២០១១ យើងបានរៀបចំកម្មសិក្ខាសាលាជាតិ ក្រោមអធិបតីភាពដ៏

ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីប្រមូលផ្តុំមតិនិងធាតុចូលពីវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងភាគីមានចំណាប់អារម្មណ៍ដទៃទៀត ។ បន្ទាប់មក នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបើកអង្គប្រជុំ ដើម្បីពិនិត្យនិងសម្រេចលើឯកសារយុទ្ធសាស្ត្រនេះ ហើយចុងក្រោយនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអនុម័តឯកសារយុទ្ធសាស្ត្រនេះជាផ្លូវការ សម្រាប់ធ្វើជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។

### ៣/- សមិទ្ធផលសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រនេះកន្លងមក

អនុវត្តតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទីមួយនិងទីពីរកន្លងមក រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលជាច្រើននិងអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយជោគជ័យជាបន្តបន្ទាប់ក្នុងទសវត្សរ៍កន្លងមក ។ សមិទ្ធផលសំខាន់ៗរួមមាន ៖

- ការអនុម័តច្បាប់សំខាន់ៗពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ធនាគារ និងហិរញ្ញវត្ថុ ដើម្បីទ្រទ្រង់វិស័យហិរញ្ញវត្ថុឱ្យមានភាពរឹងមាំ ផ្អែកលើយន្តការទីផ្សារ និងមានលក្ខណៈប្រកួតប្រជែង
- កំណែទម្រង់រចនាសម្ព័ន្ធធនាគារនិងការពង្រឹងគ្រឹះស្ថានហិរញ្ញវត្ថុគន្លឹះ
- ការបង្កើតហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់វិស័យហិរញ្ញវត្ថុ សំដៅពង្រឹងសកម្មភាពទីផ្សារហិរញ្ញវត្ថុ និងពង្រីកសេវាហិរញ្ញវត្ថុដល់ជនបទ
- ការកសាងសមត្ថភាពធនធានមនុស្សនិងឯកទេសកម្ម
- ការពង្រីកតួនាទីវិស័យហិរញ្ញវត្ថុក្នុងការកៀរគរធនធានហិរញ្ញវត្ថុក្នុងស្រុក និងបន្សីភាពប្រទាក់ក្រឡាគ្នារវាងវិស័យហិរញ្ញវត្ថុនិងអន្តរវិស័យផ្សេងទៀត ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច ។
- ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ បន្ទាប់ពីបានអនុវត្តតាមយុទ្ធសាស្ត្ររួចមក វិស័យហិរញ្ញវត្ថុនៅកម្ពុជាមានការរីកចម្រើនប្រកបដោយថាមភាពនិងភាពប្រកួតប្រជែងខ្ពស់ ក្នុងនោះ វិស័យធនាគារ វិស័យមីក្រូហិរញ្ញវត្ថុ វិស័យធានារ៉ាប់រង វិស័យសោធន ទីផ្សារមូលបត្រ និងទីផ្សារទុនជាដើម ។ បច្ចុប្បន្ន វិស័យធនាគារនៅកម្ពុជានៅតែគ្របដណ្តប់លើប្រព័ន្ធហិរញ្ញវត្ថុទាំងមូល និងព្រមទាំងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ មានលក្ខណៈសមាហរណជាមួយប្រទេសក្នុងតំបន់ និងបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ជាក់ស្តែង នៅឆ្នាំ២០០០ នៅពេលដែលយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទីមួយត្រូវបានរៀបចំនោះ ពេលនោះវិស័យហិរញ្ញវត្ថុនៅកម្ពុជាស្ថិតនៅក្នុងដំណាក់កាលប្រៀបដូចជាទារកក្នុងផ្ទៃនៅឡើយ ។ អនុបាតរូបិយវត្ថុទូទៅ (M2) ធៀបនឹងផលិតផលក្នុងស្រុកសរុបមានកម្រិត

ត្រឹមតែ ១២,៥% ប៉ុណ្ណោះ ប៉ុន្តែនៅឆ្នាំ២០០៦ នៅពេលដែលយើងរៀបចំបច្ចុប្បន្នកម្មយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទីពីរ (២០០៦-២០១៥) អនុបាតនេះបានកើនឡើងដល់ ២០,៥% ។ បច្ចុប្បន្ននេះ អនុបាតរូបិយវត្ថុទូទៅធៀបនឹងផលិតផលក្នុងស្រុកសរុបបានកើនឡើងរហូតដល់ ៤៣,៤% នៅឆមាសទី១ ឆ្នាំ២០១២ ពោលគឺកើនឡើងជាង ៣ដង ធៀបនឹងគ្រាដូចគ្នាឆ្នាំ២០០០ ។ ការកើនឡើងជាប់ជាប្រចាំនៃប្រាក់បញ្ញើនិងឥណទានរបស់ប្រព័ន្ធធនាគារ បានឆ្លុះបញ្ចាំងពីការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើវិស័យធនាគារ ទំហំនៃការរីកចម្រើនរបស់ប្រព័ន្ធហិរញ្ញវត្ថុទាំងមូល ក៏ដូចជាភាពស៊ីជម្រៅនៃសេវាហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ននេះផងដែរ ។

ជារួម ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាពល្អប្រសើរ ដោយតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាព អត្រាអតិផរណាប្រែប្រួលក្នុងកម្រិតមួយខ្ទង់អាចគ្រប់គ្រងបាន ។ ស្ថិរភាពនេះបានរួមចំណែកបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល ដោយបរិមាណប្រាក់រៀលក្នុងចរាចរណ៍នៅឆមាសទី១ ឆ្នាំ២០១២ បានកើនឡើងប្រមាណ ៣.៧០០ ពាន់លានរៀល គឺកើនឡើង ៩ដង ធៀបនឹង ៤០០ ពាន់លានរៀល នៅគ្រាដូចគ្នាក្នុងឆ្នាំ២០០០ ។

ថ្មីៗនេះ បម្រែបម្រួលរចនាសម្ព័ន្ធក៏បានកើតឡើង ក្រោមរូបភាពជាការរីកដុះដាលនូវស្ថាប័នថ្មីៗ ការកើនឡើងនូវវត្តមាននៃប្រតិបត្តិករបរទេស និងផលិតផលនិងសេវាហិរញ្ញវត្ថុដ៏សម្បូរបែបជាច្រើន ។ ផ្សារហ៊ុនកម្ពុជាបានបើកដំណើរការ ដោយមានប្រតិបត្តិករជាច្រើនផ្តល់សេវាមូលបត្រ ។ ការជួញដូរលើទីផ្សារនេះ ក៏បានចាប់ផ្តើមជាមួយនឹងការដាក់លក់មូលបត្រសាធារណៈលើកដំបូងរបស់ក្រុមហ៊ុនរដ្ឋាករទឹករបស់រដ្ឋ ។ ទន្ទឹមនោះ វិស័យធានារ៉ាប់រងក៏កំពុងអភិវឌ្ឍជាបន្ត និងបានផ្តល់សេវាធានារ៉ាប់រងលើជីវិត និងការធានារ៉ាប់រងផ្សេងទៀត រួមទាំងការធានារ៉ាប់រងជាកាតព្វកិច្ចនិងការធានារ៉ាប់រងខ្នាតតូច ។ ដោយឡែក ប្រព័ន្ធសោធនកំពុងស្ថិតក្នុងការរៀបចំជាបណ្តើរៗ ។ លើសពីនេះ ការអនុវត្តគោលនយោបាយសេរីភាវូបនីយកម្មហិរញ្ញវត្ថុដ៏សមស្រប ជាមួយនឹងការយកចិត្តទុកដាក់ ជាពិសេសទៅលើសុខភាពនិងភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុ បានបង្កើននូវការប្រកួតប្រជែងដែលផ្តល់ឱកាសពាណិជ្ជកម្មថ្មីៗបន្ថែមទៀត ។ នៅក្នុងបរិបទនៃការអភិវឌ្ឍនេះ វិស័យធនាគារបានក្លាយជាសសរទ្រូងយ៉ាងសំខាន់នៃសេដ្ឋកិច្ច និងជាវិស័យឈានមុខនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុក្នុងស្រុក ។

នាដំណាច់ខែឧសភា ឆ្នាំ២០១២ ទ្រព្យសកម្មសរុបរបស់ប្រព័ន្ធធនាគារធៀបនឹង ផសស មានចំនួនប្រមាណ ៦៦% ដែលក្នុងឆ្នាំ២០០១ មានត្រឹម ១៩% ប៉ុណ្ណោះ ។ ការណ៍នេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីការកើនឡើងគួរឱ្យកត់សម្គាល់ នូវជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។ សុខភាពនិងភាពរឹងមាំនៃវិស័យធនាគារត្រូវបានរក្សានិងធានា ក្នុងអំឡុងពេល

វិបត្តិហិរញ្ញវត្ថុសកលនាពេលកន្លងមកនេះ ។ សូចនាករថ្មីៗបានបង្ហាញថា ប្រព័ន្ធធនាគារមានប្រាក់ចំណេញសមរម្យ មានប្រសិទ្ធភាព សន្ទនីយភាពគ្រប់គ្រាន់ និងមានដើមទុនរឹងមាំ ។ ជាមធ្យម ប្រព័ន្ធធនាគារបានរក្សាអនុបាតសាធនភាពក្នុងរង្វង់ ២៥% តាំងពីឆ្នាំ២០០១មក ធៀបនឹងកម្រិតកំណត់ប្រុងប្រយ័ត្នជាអប្បបរមាចំនួន ១៥% ។ អនុបាតឥណទានមិនដំណើរការ (NPL) របស់ធនាគារ បានធ្លាក់ចុះពី ៤,៩% នៅចុងឆ្នាំ២០០៩ ទៅ ២,២% នាពេលបច្ចុប្បន្ននេះ ។ ជាមួយនឹងការកើនឡើងនៃចំនួនធនាគារ ការប្រកួតប្រជែងបានធ្វើឱ្យអត្រាការប្រាក់ប្រចាំឆ្នាំជាមធ្យមថយចុះពី ១៥% ក្នុងឆ្នាំ២០០៣ មក ១០% នាដើមឆ្នាំ២០១២នេះ ។

ក្នុងគោលបំណងបង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធនាគារ និងហិរញ្ញវត្ថុ ត្រូវបានទទួលការយកចិត្តទុកដាក់ជាខ្លាំង ។ ប្រព័ន្ធទូទាត់សងប្រាក់ និងប្រព័ន្ធរបាយការណ៍ឥណទានត្រូវបានធ្វើទំនើបកម្មជាបណ្តើរៗ ខណៈដែលប្រព័ន្ធជាត់ទាត់មូលប្បទានបត្រត្រូវបានពង្រឹងនិងពង្រីកដល់បណ្តាខេត្តធំៗជាច្រើន ។ ប្រព័ន្ធទូទាត់ដែលប្រើប្រាស់បញ្ជាទូទាត់សម្រាប់ការបង្វែរឥណទានក៏កំពុងត្រូវបានអភិវឌ្ឍ ។ ការប្រកួតប្រជែងក្នុងវិស័យធនាគារក៏បានជំរុញការផ្តល់សេវាទូទាត់ផងដែរ ។ បច្ចុប្បន្ន សេវាជាច្រើនដូចជាសេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក និងសេវាទូទាត់ចំណាយទឹក-ភ្លើង មានដំណើរការកាន់តែច្រើនឡើង តាមរយៈកំណើននៃការប្រើប្រាស់សេវាទូរសព្ទចល័តរបស់ប្រជាជន ។ ការអនុញ្ញាតឱ្យធនាគារប្រើប្រាស់នូវសេវាអ្នកដំណើរតតិយភាគី បានធ្វើឱ្យមានការពង្រីកសេវាទូទាត់ដល់ស្រទាប់ប្រជាជនដែលមិនបានប្រើប្រាស់សេវាធនាគារ ឬដែលបានប្រើប្រាស់សេវាធនាគារតិចតួច ។ ដំណើរការនេះនឹងជួយបំពេញបន្ថែមដល់កំណើនសេវាមីក្រូហិរញ្ញវត្ថុ ក្នុងការផ្តល់សេវាធនាគារដល់ប្រជាជនតាមតំបន់ជនបទ ។ ទន្ទឹមនេះ ការិយាល័យឥណទានកម្ពុជាក៏ត្រូវបានបង្កើតឡើងហើយដែរ ។

គោលដៅចម្បង គឺការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុដែលមានលក្ខណៈប្រកួតប្រជែង សមាហរណ និងប្រសិទ្ធភាព ពោលគឺប្រព័ន្ធហិរញ្ញវត្ថុដែលមានការគ្រប់គ្រងនិងត្រួតពិនិត្យបានសមស្រប ដែលអាចកៀរគរធនធានហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព ដើម្បីផ្តល់ហិរញ្ញប្បទានសម្រាប់ទ្រទ្រង់ការរីកចម្រើននៃសេដ្ឋកិច្ចជាតិ និងផ្តល់សេវាហិរញ្ញវត្ថុនានាសម្រាប់បំពេញតម្រូវការនៃសេដ្ឋកិច្ច ។

ការវិវត្តរីកចម្រើននៃវិស័យហិរញ្ញវត្ថុពិតជាបានរួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ គិតជាមធ្យមប្រចាំឆ្នាំមានកំណើនក្នុងរង្វង់ ៧% ។ ជាក់ស្តែងនៅឆ្នាំ២០១១ ចំណូលប្រចាំឆ្នាំសម្រាប់ប្រជាជនម្នាក់បានកើនដល់ ៩០៩ ដុល្លារអាមេរិក និងអាចកើនដល់ ៩៨៨ ដុល្លារអាមេរិក នៅឆ្នាំ២០១២ ។ ការណ៍នេះបានរួមចំណែកកាត់បន្ថយអត្រាភាពក្រីក្ររបស់ប្រជាជនប្រមាណ ១% ក្នុងមួយឆ្នាំជាប់ជាប្រចាំ ដែលអត្រាភាពក្រីក្របានធ្លាក់ចុះមកត្រឹម ២៦% នៅឆ្នាំ២០១១ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

**- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជាទីគោរព**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី**

សរុបមក ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០នេះ គឺជាសមិទ្ធផលរួមរបស់យើងទាំងអស់គ្នា និងមានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ជាពិសេសសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាដ៏សម្បូរបែប ប្រកបដោយភាពប្រកួតប្រជែង និងមានលក្ខណៈប្រយ័ត្នប្រយែង មានសុខភាពល្អ និងមានប្រសិទ្ធភាព ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ម្យ៉ាងទៀត ឯកសារនេះក៏ជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីឥណទានអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងជាឧបករណ៍សម្រាប់សម្របសម្រួលជំនួយឧបត្ថម្ភជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀតផងដែរ ។

ជារួម លក្ខណៈពិសេសនៃការអនុវត្តឯកសារយុទ្ធសាស្ត្រនេះ គឺត្រូវមានភាពទន់ភ្លន់ ហើយរាជរដ្ឋាភិបាលអាចកែតម្រូវគោលនយោបាយចាំបាច់មួយចំនួន ដើម្បីឆ្លុះបញ្ចាំងពីការរីកចម្រើននិងលក្ខខណ្ឌចាំបាច់មួយចំនួន ជាពិសេស បានបង្កើតយន្តការត្រៀមដោះស្រាយបញ្ហាប្រឈមក្នុងប្រព័ន្ធហិរញ្ញវត្ថុ ។ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុត្រូវតែដើរទន្ទឹមគ្នាជាមួយការអភិវឌ្ឍរបស់វិស័យឯកជននិងអភិបាលកិច្ចល្អ ហើយក៏ត្រូវបន្តពង្រឹងវិស័យធនាគារនិងហិរញ្ញវត្ថុបន្ថែមទៀត ដើម្បីទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ឆ្ពោះទៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដែលជាគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល ។

ជាថ្មីម្តងទៀត ខ្ញុំសម្តែងនូវអំណរគុណចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ឯកឧត្តម Kunio Senga លោក Putu Kamayana លោក Samiule Tukuafu និងសហការី ដែលបានគាំទ្រការធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រនេះឱ្យទទួលបានជោគជ័យ និងថ្លែងអំណរគុណដល់បណ្តាក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដែលបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ ប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យជាទីមោទនៈ ។ នេះគឺជាជោគជ័យនិងមោទនភាពរួមរបស់យើងទាំងអស់គ្នា ។

ជាទីបញ្ចប់ ខ្ញុំក៏សូមថ្លែងអំណរគុណ ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ និងសូមគោរពជូនពរឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សូមមានសុខភាពល្អ កម្លាំងមាំមួន ជួបប្រទះតែពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។ ខ្ញុំបាទក៏សូមជូនពរផងដែរ ចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញាដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ និងទទួលបានជ័យជម្នះគ្រប់ភារកិច្ច ។

**សូមអរគុណ**!

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number.........................................................

## Opening Remarks
## H.E. Chea Chanto, Governor of the National Bank of Cambodia
## on the occasion of the 18th APRACA General Assembly,
## the 61st APRACA EXCO Meeting and the Regional Forum
## Siem Reap, 30 May 2012

********

- Mr. ILYOS Amanov, APRACA Deputy Chairman,
- Mr. Won-sik Noh, APRACA Secretary General,
- Mr. Gopal Prasad Kaphle, Deputy Governor of Nepal Rastra Bank,
- Dr. Ganesh Thapa, IFAD Representative,
- Distinguished Guests, Ladies and Gentlemen,

Good morning!

Today, on behalf of the National Bank of Cambodia, I have the great honor and pleasure to host the 18th APRACA General Assembly, the 61st APRACA Executive Committee Meeting and the Regional Forum on "Strengthening the Resilience of Smallholder Farmers through Rural Innovation" in Siem Reap province. Our meetings today are organized in the time that Cambodia is holding the ASEAN Chairmanship under the theme 'ASEAN: *One Community, One destiny*'.

In the meantime, I would like to warmly welcome Excellencies, Ladies and Gentlemen, honorable speakers, representatives and all delegates from respective APRACA member countries to Cambodia, *especially*, to Siem Reap province, the ancient capital city of Cambodia. I hope that all of you had a pleasant journey from your country all the ways to Cambodia and discovered cultural exchanges.

I would like to thank Dr. Ganesh Thapa, Mr. Won-Sik Noh, and all the staff who are always striving to provide good cooperation among the members across the region. I would also like to thank our resource speakers for your contribution. Today's topic is truly important for Microfinance practitioners, local and regional policy makers, experts from the government and private sectors, SMEs development agencies and academia to meet and discuss about strengthening the resilience of smallholder farmers through rural finance in Cambodia.

Distinguished Guests, Ladies and Gentlemen,

Taking this opportunity, let me say a few words about microfinance development. Microfinance industry in Cambodia was born in the early nineties by nongovernmental organizations and donor communities to first provide humanitarian aid to the poor in rural areas. Then this sector has continued to further develop owing to wide demand for financial services, significant sustainability, sound and safe development environment and increase in number of nongovernmental organizations that recognize the large potential market for microfinance services throughout the country.

By seeing the importance of microfinance in contributing to socio-economic development that can help reduce poverty by promoting opportunities and facilitating empowerment, the Royal Government of Cambodia set up a national policy for microfinance development. *First*, in 1999, the Law on Banking and Financial Institutions was adopted to integrate microfinance industry into regulated financial system under the authority of the National Bank of Cambodia. *Second*, in 2001 the Royal Government adopted a long-term Blueprint (FSDS) to set a clear vision, identify challenges and constraints, and lay out alternatives and action plans of future strategies. The Blueprint was continuously updated to reflect the current economic development and changes.

Microfinance in Cambodia today is recognized as a key factor in contributing socio-economic development. It is also regarded as an effective tool for poverty reduction in a peaceful and stable political environment. Microfinance today is already recorded a successful story to serve the interests of the poor by providing financial services, increasing incomes, improving lives and reducing poverty. Hence, Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia declared "*the Year 2006 as the Year of Microfinance of Cambodia*" after the United Nations General Assembly announced "*the Year 2005 as the Year of Microfinance of the World*".

Microfinance sector in Cambodia now continues to grow rapidly both of scopes and scales. Since May 2012, we have 32 licensed Microfinance institutions with total assets of USD800 million and total loans of USD700 million reaching over one million clients. Total deposits increased sharply from a low base to USD114 million. The average non-performing loan ratio is now at 0.2% despite the severe flooding in the country. This progress reflects the better awareness of our people, *especially*, the female clients, on the importance of microfinance services and credit culture.

**Distinguished Guests, Ladies and Gentlemen,**

With regards to today's topic, it is especially relevant when talking about rural finance innovations, value chain, green financing and risk management strategies. These issues are of particular importance to improve the microfinance sector and thus important to our respective countries as well.

Smallholder farmers are the backbone of the rural economy – but they are bearing the brunt of climate change. Worldwide, there are 500 million smallholder farms supporting over 2 billion people. Over the centuries, smallholders have learned to adjust to environmental change and climate variability. Crop failures and livestock deaths are causing economic losses, raising food prices and undermining food security with ever-greater frequency. At the same time, demand for food is increasing as population grows and dietary habits change.

Agriculture, along with forestry, can play a key role in tackling climate change. Improving land management and farming practices and planting forests can help lower greenhouse effect. The poor farmers are custodians of natural resources. Authorities are keen to scale up investments in sustainable agricultural intensification,

focusing on risk and resilience, promoting value chains that drive '*green growth*', supporting better governance and policies on natural assets, and promoting knowledge-intensive and community-led responses.

Beyond traditional risks, smallholders will face new threats, such as the rise of sea level and the impact of flood. Climate change magnifies traditional risks. Farmers can no longer rely on historical averages of factors such as rainfall and temperature, because climate change is increasing climate variability, the range of extremes and the scale of volatility.

Agriculture value chain can provide many opportunities for both farmers and financial institutions. Innovations in rural finance have led to reductions in transaction costs, increased outreach and new products, which have had significant positive impacts on greater access to finance. However, many challenges remain and we should explore further on how innovative techniques can be used to overcome traditional barriers in providing financial services.

In this regard, let me share with you that in order to avoid environmental threats such as climate changes and enable poor rural people to overcome poverty, the strategies should be to:

- Support innovative approaches to help smallholder producers build their resilience to climate change,
- Enable smallholder farmers to take advantages of available mitigation incentives and funding and
- Inform a more cogent dialogue on climate change, rural development, agriculture and food security.

In short, experiences have indicated that microfinance has proven to be the vehicle of changes in the lives of millions of rural communities, as it adopts innovative delivery channels of green technologies and products from tradition. I however will not elaborate too much on this because our honorable speakers will deliver very interesting speeches in the courses and panel discussion today. There is no need to convince you that rural finance is a key issue for our countries.

**Distinguished Guests, Ladies and Gentlemen,**

Let me conclude that this forum is very important for us. I know that your upcoming discussion will be very rich and useful. Your conclusion will be the basis for future important policy formulation.

Last but not least, let me wish all of you a productive and successful discussion. I would like to take this opportunity to register our deep appreciation for your support and kind cooperation in participating in the important meetings.

Even though you are on a tight schedule here, I hope you will find time to go sightseeing and visit more temples and other interesting places and to get to know about our people and culture during your stay in Siem Reap.

May I wish you all good luck and a pleasant stay in our ancient capital city of Siem Reap, Angkor.

**Thank you!**

បកប្រែក្រៅផ្លូវការ

## សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ក្នុងឱកាសបើកមហាសន្និបាតអាប្រាកាលើកទី១៨
## កិច្ចប្រជុំគណៈកម្មការអាប្រាកាលើកទី៦១ និងសន្និសីទថ្នាក់តំបន់
## ខេត្តសៀមរាប ៣០ ឧសភា ឆ្នាំ២០១២

-លោក ILYOS Amanov អនុប្រធានអាប្រាកា

-លោក Won-sik Noh អគ្គលេខាធិការអាប្រាកា

-លោក Gopal Prasad Kaphle ទេសាភិបាលរងធនាគារកណ្តាលណេប៉ាល់

-បណ្ឌិត Ganesh Thapa តំណាង IFAD

-លោក លោកស្រី ភ្ញៀវកិត្តិយស

**អរុណសួស្តី**

ថ្ងៃនេះ តាងនាមឲ្យធនាគារជាតិនៃកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយនិងមានកិត្តិយសបំផុតដែលបានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំមហាសន្និបាតអាប្រាកាលើកទី១៨ កិច្ចប្រជុំគណៈកម្មការអាប្រាកាលើកទី៦១ និងសន្និសីទថ្នាក់តំបន់ស្តីពី **"ការពង្រឹងសមត្ថភាពកសិករខ្នាតតូចតាមរយៈភាពច្នៃប្រឌិតនៃ ហិរញ្ញវត្ថុជនបទ"** នៅខេត្តសៀមរាបនេះ។កិច្ចប្រជុំនៅថ្ងៃនេះត្រូវបានរៀបចំឡើងស្របពេលដែលកម្ពុជាកំពុងធ្វើជាប្រធានអាស៊ានក្រោមពាក្យស្លោកអាស៊ាន **"សហគមន៍មួយ វាសនាតែមួយ"** ។

ទន្ទឹមគ្នានេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី វាគ្មិនកិត្តិយស អ្នកតំណាងនិងភ្ញៀវកិត្តិយសដែលអញ្ជើញពីប្រទេសសមាជិកអាប្រាកាមកកាន់កម្ពុជា ជាពិសេស ខេត្តសៀមរាប ដែលជារាជធានីបុរាណរបស់កម្ពុជា ។ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី បានមកកាន់កម្ពុជាដោយរីករាយនិងបានចែករំលែកនូវវប្បធម៌ ។

ខ្ញុំសូមថ្លែងអំណរគុណ បណ្ឌិត Ganesh Thapa លោក Won-sik Noh និងមន្ត្រីទាំងអស់ដែលបានផ្តល់នូវកិច្ចសហប្រតិបត្តិការយ៉ាងល្អទៅវិញទៅមកក្នុងតំបន់ ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់វាគ្មិនកិត្តិយសសម្រាប់ការចែករំលែកបទពិសោធន៍ល្អៗ ។ ប្រធានបទនៅថ្ងៃនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកអនុវត្តក្នុងវិស័យមីក្រូហិរញ្ញវត្ថុ អ្នករៀបចំគោលនយោបាយថ្នាក់ជាតិនិងថ្នាក់តំបន់ អ្នកជំនាញក្នុងជួររដ្ឋាភិបាល និងវិស័យឯកជន ភ្នាក់ងារអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម និងអ្នកសិក្សាក្នុងការជួបនិងពិភាក្សាអំពីការពង្រឹងសមត្ថភាពរបស់កសិករខ្នាតតូច តាមរយៈហិរញ្ញប្បទានជនបទនៅកម្ពុជា ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតជម្រាបជូនពីការអភិវឌ្ឍមីក្រូហិរញ្ញវត្ថុ។ វិស័យមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាបានចាប់កំណើតនៅដើមទសវត្សរ៍ឆ្នាំ៩០ ដោយអង្គការក្រៅរដ្ឋាភិបាល និងសហគមន៍អ្នកផ្តល់

ជំនួយដើម្បីផ្តល់នូវជំនួយមនុស្សធម៌ដល់ប្រជាជនក្រីក្រនៅតំបន់ជនបទដាច់ស្រយាល។ បន្ទាប់មកវិស័យនេះបានបន្តអភិវឌ្ឍន៍ដោយសារការកើនឡើងនៃតម្រូវការសេវាហិរញ្ញវត្ថុ និងបរិកាសអភិវឌ្ឍន៍ប្រកបដោយសុវត្ថិភាព និងការកើនឡើងនៃចំនួនអង្គការក្រៅរដ្ឋាភិបាល ដែលស្គាល់ពីសក្តានុពលទីផ្សាដ៏ធំនៃសេវាមីក្រូហិរញ្ញវត្ថុនៅទូទាំងប្រទេស ។

ដោយយល់ឃើញពីសារៈសំខាន់នៃមីក្រូហិរញ្ញវត្ថុ ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដែលអាចជួយកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើនឱកាសនិងពង្រឹងសហគមន៍ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលនយោបាយជាតិមួយ ដើម្បីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ។ នៅលើកទីមួយឆ្នាំ១៩៩៩ ច្បាប់លើស្ថាប័នហិរញ្ញវត្ថុនិងធនាគារត្រូវបានអនុម័តដើម្បីបញ្ចូលវិស័យមីក្រូហិរញ្ញវត្ថុទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានគ្រប់គ្រងដោយច្បាប់ក្រោមសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជា។ លើកទី២ ឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាអនុម័តផែនការរយៈពេលវែង(យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ) ដើម្បីបង្កើតនូវទស្សនវិស័យច្បាស់លាស់ កំណត់នូវឧបសគ្គ កង្វះខាត និងរៀបចំជម្រើសនានា និងផែនការសកម្មភាពសម្រាប់យុទ្ធសាស្ត្ររយៈពេលវែង ។ ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ដើម្បីឆ្លុះបញ្ចាំងអំពីការផ្លាស់ប្តូរនិងការអភិវឌ្ឍសេដ្ឋកិច្ចបច្ចុប្បន្ន ។

មីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាបច្ចុប្បន្នត្រូវបានចាត់ទុកថាជាកត្តាគន្លឹះ ដែលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ វិស័យនេះក៏ត្រូវបានចាត់ទុកថាជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ការកាត់បន្ថយភាពក្រីក្រ ក្នុងបរិយាកាសសន្តិភាព និងស្ថិរភាពនយោបាយ ។ វិស័យមីក្រូហិរញ្ញវត្ថុបច្ចុប្បន្នត្រូវបានកត់ត្រាជាបទពិសោធន៍ជោគជ័យដោយបានបម្រើដល់អត្ថប្រយោជន៍ជនក្រីក្រ តាមរយៈការផ្តល់នូវសេវាហិរញ្ញវត្ថុបង្កើនប្រាក់ចំណូល ធ្វើឲ្យជីវភាពកាន់តែប្រសើរ និងកាត់បន្ថយភាពក្រីក្រ ។ ដូច្នេះហើយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសថា "ឆ្នាំ២០០៦ជាឆ្នាំមីក្រូហិរញ្ញវត្ថុនៃកម្ពុជា" បន្ទាប់ពីសភានៃអង្គការសហប្រជាជាតិបានប្រកាសថា "ឆ្នាំ២០០៥ ជាឆ្នាំនៃមីក្រូហិរញ្ញវត្ថុនៃពិភពលោក" ។

វិស័យមីក្រូហិញ្ញវត្ថុក្នុងកម្ពុជាបច្ចុប្បន្នបន្តរីកចម្រើនយ៉ាងលឿនទាំងវិសាលភាពនិងទំហំប្រតិបត្តិការ។ ចាប់ពីខែឧសភា ឆ្នាំ២០១២ កម្ពុជាមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣២ ដែលមានទ្រព្យសកម្មសរុបចំនួន ៨០០លានដុល្លារអាមេរិក និងឥណទានសរុបចំនួន ៧០០លានដុល្លារអាមេរិកដែលមានអតិថិជនជាងមួយលាននាក់ ។ ជាមធ្យមឥណទានមិនដំណើរការស្ថិតក្នុងអត្រា ០,២% ទោះបីជាគ្រោះទឹកជំនន់ធ្ងន់ធ្ងរក្នុងប្រទេសក៏ដោយ ។ ការរីកចម្រើននេះ បានឆ្លុះបញ្ចាំងពីការយល់ដឹងប្រសើរជាងមុនរបស់ប្រជាជន ជាពិសេសអតិថិជនជាស្ត្រី ទៅលើសារៈប្រយោជន៍នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទាន ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី**

ប្រធានបទថ្ងៃនេះ គឺទាក់ទងជាពិសេសទៅនឹងភាពច្នៃប្រឌិតនៃហិរញ្ញវត្ថុជនបទ ខ្សែសង្វាក់សកម្មភាពផ្តល់សេវាប្រកបដោយគុណភាព (Value chain) ហិរញ្ញប្បទានបៃតង (Green financing) និងយុទ្ធសាស្ត្រការគ្រប់គ្រងហានិភ័យ ។ កត្តាទាំងនេះគឺ មានសារៈសំខាន់ក្នុងការជំរុញវិស័យមីក្រូហិរញ្ញវត្ថុឲ្យរីកចម្រើន និងមានសារៈសំខាន់ដល់ប្រទេសជាតិទាំងមូល ។

កសិករខ្នាតតូចគឺជាឆ្អឹងខ្នងដ៏សំខាន់នៃសេដ្ឋកិច្ចជនបទ ក៏ប៉ុន្តែពួកគាត់កំពុងតែរងនូវបញ្ហានៃការប្រែប្រួលអាកាសធាតុ។ នៅទូទាំងសកលលោក មានកសិដ្ឋានខ្នាតតូចចំនួនជាង៥០០លាន ដែលផ្តល់ការងារឲ្យ

ប្រជាជនលើសពី២ ពាន់លាននាក់។ ជាច្រើនសតវត្សមកហើយ កសិករខ្នាតតូចបានយល់ដឹងពីការសម្របខ្លួនទៅតាមការប្រែប្រួលបរិស្ថាននិងអាកាសធាតុ។ ការខូចខាតដំណាំនិងការស្លាប់សត្វពាហនៈបានធ្វើឲ្យសេដ្ឋកិច្ចបាត់បង់នូវប្រយោជន៍ជាច្រើន បង្កើនថ្លៃម្ហូបអាហារប៉ះពាល់ដល់សន្តិសុខស្បៀងកាន់តែញឹកញាប់ ។ ក្នុងពេលជាមួយគ្នានេះ តម្រូវការម្ហូបអាហារកើនឡើង ខណៈដែលចំនួនប្រជាជនកាន់តែច្រើននិងទំលាប់នៃការហូបចុកមានការប្រែប្រួល ។

កសិកម្មនិងព្រៃឈើមានតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ ពង្រឹងការគ្រប់គ្រងដីនិងការធ្វើកសិកម្ម ហើយព្រៃឈើអាចជួយកាត់បន្ថយផលប៉ះពាល់ពីឧស្ម័នផ្ទះកញ្ចក់ ។ កសិករក្រីក្រគឺជាអ្នកអភិរក្សធនធានធម្មជាតិ។ អាជ្ញាធរបានខិតខំកេណ្ឌប្រមូលការវិនិយោគទៅលើការពង្រឹងនិរន្តរភាពវិស័យកសិកម្ម ដោយយកចិត្តទុកដាក់លើហានិភ័យនិងភាពធន់ ជំរុញខ្សែសង្វាក់ផលិតកម្ម ដែលជំរុញកំណើនបៃតង គាំទ្រអភិបាលកិច្ច និងគោលនយោបាយដ៏សមស្របទៅលើធនធានធម្មជាតិ និងជំរុញការស្វែងរកដំណោះស្រាយ ដែលដឹកនាំដោយសហគមន៍និងប្រកបដោយការយល់ដឹង ។

ក្រៅពីហានិភ័យប្រពៃណី កសិករខ្នាតតូចអាចនឹងជួបប្រទះនឹងការគំរាមកំហែងថ្មី ដូចជាការកើនឡើងនៃកម្ពស់ទឹកសមុទ្រនិងផលប៉ះពាល់ពីទឹកជំនន់។ បម្រែបម្រួលអាកាសធាតុបានធ្វើឲ្យហានិភ័យប្រពៃណីមានសភាពខ្លាំងជាងមុន។ កសិករមិនអាចពឹងពាក់លើកត្តាធម្មជាតិដូចជា ទឹកភ្លៀងនិងសីតុណ្ហភាពបានទៀតឡើយ ដោយសារតែបម្រែបម្រួលអាកាសធាតុបានធ្វើឲ្យអាកាសធាតុផ្លាស់ប្តូរច្រើន។

តម្លៃបន្ថែមលើកសិកម្មអាចផ្តល់នូវអត្ថប្រយោជន៍ជាច្រើនសម្រាប់កសិករនិងគ្រឹះស្ថានហិរញ្ញវត្ថុ។ ការច្នៃប្រឌិតនៃហិរញ្ញវត្ថុជនបទអាចជួយកាត់បន្ថយចំណាយប្រតិបត្តិការ បង្កើនវិសាលភាពនិងផលិតផលថ្មីដែលជាកត្តាដ៏សំខាន់ក្នុងការជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុ។ ទោះបីជាយ៉ាងណាក៏ដោយក៏នៅមានបញ្ហាប្រឈមជាច្រើនទៀត ហើយយើងទាំងអស់គ្នាត្រូវខិតខំបន្តស្វែងយល់បន្ថែមពីបច្ចេកវិទ្យាច្នៃប្រឌិតក្នុងការជួយដោះស្រាយឧបសគ្គប្រពៃណីក្នុងការផ្តល់នូវសេវាហិរញ្ញវត្ថុ ។

ក្នុងបរិបទនេះ ខ្ញុំសូមចែករំលែកជាមួយអ្នកទាំងអស់គ្នានូវយុទ្ធសាស្ត្រ ដើម្បីជៀសផុសពីការគំរាមកំហែងរបស់ធម្មជាតិ ដូចជាបម្រែបម្រួលធាតុអាកាសនិងដើម្បីជួយឲ្យប្រជាជនក្រីក្រនៅជនបទអាចគេចផុតពីភាពក្រីក្រដែលមានដូចជា ៖

- គាំទ្រវិធីសាស្ត្រថ្មីដើម្បីជួយដល់ផលិតករតូចៗឲ្យមានភាពធនទៅនឹងការប្រែប្រួលអាកាសធាតុ
- ជំរុញឲ្យកសិករខ្នាតតូចទទួលបានផលប្រយោជន៍ពីការផ្តល់ហិរញ្ញប្បទាននិងលើកទឹកចិត្តក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីកាត់បន្ថយបរិមាណធនធានដាក់បញ្ចូលនិងការបញ្ចេញជាតិពុល និង
- ផ្តល់ព័ត៌មានតាមរយៈកិច្ចពិភាក្សាស្តីពីការប្រែប្រួលអាកាសធាតុការអភិវឌ្ឍជនបទនិងសន្តិសុខ ស្បៀងនិងកសិកម្ម ។

ជារួម បទពិសោធន៍បានបង្ហាញឲ្យឃើញថាមីក្រូហិរញ្ញវត្ថុ គឺជាយានដែលអាចផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជនរាប់លាននាក់នៅក្នុងសហគមន៍ជនបទ ដោយសារសកម្មភាពនេះផ្សារភ្ជាប់បច្ចេកវិទ្យាបៃតង

(Green technology) ដែលទំនើប និងនៅតែប្រើប្រាស់ឧបករណ៍ប្រពៃណី ។

ខ្ញុំនឹងមិនលើកឡើងច្រើនអំពីបញ្ហានេះទេ ដោយសារនាពេលបន្តិចទៀតនេះ វាគ្មិនរបស់យើងនឹងធ្វើបទឧទ្ទេសនាមលើបញ្ហានេះជូនអង្គសិក្ខាសាលា និងក្នុងកិច្ចពិភាក្សានាថ្ងៃនេះ ។ ដូចនេះ ខ្ញុំមិនចាំបាច់ជម្រាបលម្អិតដើម្បីធ្វើឲ្យ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជឿថាហិរញ្ញវត្ថុជនបទ គឺពិតជាបញ្ហាគន្លឹះសម្រាប់ប្រទេសយើង ដោយទុកឱកាសនេះជូនវាគ្មិន និងកិច្ចពិភាក្សា ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

សរុបមក វេទិកានេះពិតជាមានសារៈសំខាន់ណាស់សម្រាប់យើងទាំងអស់គ្នា ។ ខ្ញុំជឿថា កិច្ចពិភាក្សានាពេលបន្តិចទៀតនេះ នឹងប្រព្រឹត្តទៅប្រកបដោយភាពក្បោះក្បាយ និងផ្លែផ្កា ហើយលទ្ធផលអង្គប្រជុំ និងសិក្ខាសាលា នឹងក្លាយជាមូលដ្ឋានគ្រឹះ សម្រាប់បង្កើតគោលនយោបាយនាពេលអនាគត ។

ជាចុងក្រោយ ខ្ញុំសូមជូនពរឲ្យកិច្ចពិភាក្សាប្រព្រឹត្តទៅដោយផ្លែផ្កានិងជោគជ័យ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការគាំទ្រ និងកិច្ច សហប្រតិបត្តិយ៉ាងជិតស្និតក្នុងការចូលរួមកិច្ចប្រជុំនេះ ។

ទោះបីជាមានការមមាញឹកយ៉ាងណាក៏ដោយ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់នឹងឆ្លៀតឱកាសដើរទស្សនាប្រាសាទបុរាណ និងកន្លែងដែលគួរឲ្យចាប់អារម្មណ៍មួយចំនួន ដើម្បីស្វែងយល់អំពីប្រជាពលរដ្ឋ និងវប្បធម៌ខ្មែរក្នុងអំឡុងពេលស្នាក់នៅក្នុងទឹកដីនៃខេត្តសៀមរាបនេះ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមឲ្យជួបតែសំណាងល្អ និងមានភាពរីករាយក្នុងការស្នាក់នៅទឹកដីសៀមរាបអង្គរ ទីក្រុងបុរាណរបស់យើង ។

**សូមអរគុណ** !

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

# សេចក្តីប្រកាសព័ត៌មាន

ចាប់ពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជានឹងដំណើរការ "ប្រព័ន្ធផាត់ទាត់ជាតិ" (National Clearing System) ជាផ្លូវការ ដើម្បីបង្កើនប្រសិទ្ធភាព និងពង្រីកការផ្តល់សេវាផាត់ទាត់ និងទូទាត់សម្រាប់ការទូទាត់អន្តរធនាគារនៅកម្ពុជា តាមរយៈប្រព័ន្ធផាត់ទាត់ជាតិថ្មីនេះ ។

ប្រព័ន្ធផាត់ទាត់ជាតិដែលដាក់ដំណើរការនេះអាចផាត់ទាត់ និងទូទាត់ឧបករណ៍ទូទាត់ ដូចជាមូលប្បទានបត្រ និងបញ្ជាទូទាត់ជាអេឡិចត្រូនិកដែលបង្កើតស្របច្បាប់ (ការផ្ទេរឥណទាន ឥណទានផ្ទាល់ និងឥណពន្ធផ្ទាល់) ជាលក្ខណៈមជ្ឈការ នៅសភាផាត់ទាត់ជាតិ (National Clearing House) ពោលគឺការផាត់ទាត់និងទូទាត់ឧបករណ៍ទាំងនេះអាចបញ្ចប់នៅក្នុងថ្ងៃ និងប្រព្រឹត្តទៅនៅសភាផាត់ទាត់ជាតិដែលមានទីតាំងនៅធនាគារជាតិនៃកម្ពុជា ។ ដូច្នេះ ធនាគារអាចធ្វើការផ្ទេរប្រាក់អតិថិជនរបស់ធនាគារមួយទៅអតិថិជនរបស់ធនាគារមួយផ្សេងទៀតនៅក្នុងថ្ងៃដដែល គ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា ។

ធនាគារជាតិនៃកម្ពុជាបានដំណើរការអភិវឌ្ឍប្រព័ន្ធផាត់ទាត់ជាតិនេះដោយបានប្រើរយៈពេលជាច្រើនឆ្នាំ ក្រោមការឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា និងដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ។ ប្រព័ន្ធផាត់ទាត់ជាតិនេះត្រូវបានរៀបចំឡើងដោយបានប្រើប្រាស់បច្ចេកវិទ្យាសុវត្ថិភាព និងទំនើបដែលមានចុងក្រោយ ដើម្បីធានាសុវត្ថិភាពនិងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាផាត់ទាត់និងទូទាត់អន្តរធនាគារ ។

ការអភិវឌ្ឍប្រព័ន្ធនេះ ជាផ្នែកមួយដ៏ធំនៃការអនុវត្តតាមទិសដៅរយៈពេលវែងរបស់ធនាគារជាតិនៃកម្ពុជាដែលមានចែងនៅក្នុងឯកសារ "យុទ្ធសាស្ត្រនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០១១-២០២០" របស់រាជរដ្ឋាភិបាល ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ចកម្ពុជាដែលកំពុងមានការអភិវឌ្ឍយ៉ាងលឿន និងតម្រូវការទូទាត់ឧបករណ៍ទូទាត់ផ្សេងៗដែលកាន់តែមានការប្រើប្រាស់ច្រើនឡើង ។

ធនាគារជាតិនៃកម្ពុជារំពឹងថា ធនាគារនឹងប្រើប្រាស់ប្រព័ន្ធថ្មីនេះដើម្បីពង្រីកការផ្តល់សេវាទូទាត់ឲ្យកាន់តែមានប្រសិទ្ធភាព ជូនអតិថិជនរបស់ខ្លួន ។

ភ្នំពេញ, ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០១១.២៤៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៨ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងប្រកាសលេខ ធ៧-០១១-២៤១ ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងបង្កើត លើកកម្ពស់ និងអភិវឌ្ឍវិស័យភតិសន្យាហិរញ្ញវត្ថុនៅកម្ពុជា ដើម្បីពង្រឹងការត្រួតពិនិត្យនិងគ្រប់គ្រងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដោយកំណត់លក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណនិងដាក់បទប្បញ្ញត្តិចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ។

**ប្រការ ២.- វិសាលភាព**

ប្រកាសនេះ គ្របដណ្តប់លើប្រតិបត្តិការរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ជាគ្រឹះស្ថានដែលធ្វើតែអាជីវកម្មភតិសន្យាហិរញ្ញវត្ថុប៉ុណ្ណោះ។

**ប្រការ ៣.- ដើមទុនចុះបញ្ជី**

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាចំនួន ២០០.០០០.០០០ រៀល (ពីររយលានរៀល) ហើយដើមទុនចុះបញ្ជីនេះត្រូវតែជាដើមទុនបង់ជម្រះ។

## ជំពូកទី ២
## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាបណ្ណ

**ប្រការ ៤.- ការដាក់ពាក្យសុំអាជ្ញាបណ្ណ**

១. គ្មានបុគ្គលណាម្នាក់ ទោះជារូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវបានអនុញ្ញាតឲ្យធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាឡើយ។

២. ពាក្យសុំអាជ្ញាបណ្ណត្រូវធ្វើឡើងដោយបុគ្គល ដែលមានសិទ្ធិអំណាចនៅក្នុងក្រុមហ៊ុន (នាយកគ្រប់គ្រង ឬបុគ្គលដែលត្រូវបានផ្តល់សិទ្ធិអំណាច) និងបង្ហាញព័ត៌មានដូចខាងក្រោម៖

ក. កិច្ចព្រមព្រៀងចូលភាគហ៊ុន ឬកិច្ចព្រមព្រៀងរបស់ភាគទុនិក

ខ. នាម ឬនាមករណ៍របស់ក្រុមហ៊ុន

គ. អាសយដ្ឋាននៃទីស្នាក់ការកណ្តាល ឬសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីជាសាខាក្រុមហ៊ុនបរទេស

ឃ. រូបភាពគតិយុត្ត និងលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬឯកសារផ្សេងទៀត

ង. ប្រភេទមូលបត្រតំណាងឲ្យដើមទុន និងទំនាក់ទំនងរវាងការកាន់កាប់មូលបត្រ និងការអនុវត្តសិទ្ធិបោះឆ្នោត

ច. ចំនួនទឹកប្រាក់នៃភាគហ៊ុនដែលបានបោះផ្សាយ និងដើមទុនបង់ជម្រះ

ឆ. ការបែងចែកភាគហ៊ុន សិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀង ដែលអាចមានរវាងភាគទុនិកដែលធ្វើសកម្មភាពក្នុងការដឹកនាំគោលនយោបាយរបស់ក្រុមហ៊ុន

ជ. ភាគទុនិកដែលកាន់កាប់៥% (ប្រាំភាគរយ) នៃសិទ្ធិបោះឆ្នោត ឬលើស ត្រូវផ្តល់ព័ត៌មានដូចមាន រៀបរាប់នៅក្នុងប្រការ ១៣ នៃប្រកាសនេះ។

ឈ. អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិច១រូប (មួយរូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន។ បុគ្គលនោះត្រូវផ្តល់ព័ត៌មានតាមឧបសម្ព័ន្ធ២ ព្រមទាំងមានបញ្ជាក់លិខិតថ្កោលទោសមួយច្បាប់ផង

ញ. អត្តសញ្ញាណរបស់បុគ្គលទទួលខុសត្រូវក្នុងការចេញសេចក្តីសម្រេច។ បុគ្គលនោះត្រូវបំពេញប្រវត្តិរូប និងបញ្ជាក់ថាខ្លួនមិនត្រូវបានហាមឃាត់នៅក្នុងប្រការ១៤ នៃប្រកាសនេះទេ។ បុគ្គលនោះត្រូវមានបទពិសោធន៍ពាក់ព័ន្ធនឹងអាជីវកម្មភតិសន្យានិងឥណទានយ៉ាងតិច៣ឆ្នាំ (បីឆ្នាំ)

ង. ប្រសិនបើនីតិបុគ្គល ដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនេះ ជាក្រុមហ៊ុនដែលបានបង្កើតរួចហើយ ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានអំពីអាជីវកម្ម ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុបញ្ជាក់ដោយសវនករគណនី សម្រាប់ប្រតិបត្តិការរយៈពេល៣ឆ្នាំ (បីឆ្នាំ)

ខ. ភស្តុតាងសមស្របផ្សេងទៀត ដូចជា៖

- ដំណើរការគ្រប់គ្រងហានិភ័យ ដូចជា ការកំណត់អត្តសញ្ញាណ ការវាស់វែង ការតាមដាន និងត្រួតពិនិត្យហានិភ័យ
- ផែនការគ្រប់គ្រង៖
  - ហានិភ័យសន្ទនីយភាព អត្រាការប្រាក់ និងកាលវសាន្ត (ការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម)
  - ហានិភ័យឥណទាន
  - ហានិភ័យប្រតិបត្តិការ
  - ហានិភ័យទីផ្សារ
  - ហានិភ័យទ្រព្យសកម្ម
  - ហានិភ័យឯកសារ (Documentation Risk)
  - ហានិភ័យប្រមូលផ្តុំ (Concentration Risk)
  - ហានិភ័យដទៃទៀត ដែលអាចកើតមានចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅពេលធ្វើប្រតិបត្តិការភតិសន្យាតាមផែនការអាជីវកម្ម។

**ប្រការ ៥.- សំណើសុំផ្លាស់ប្តូរព័ត៌មាន**

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជា ដូចជា៖

ក . ការផ្លាស់ប្តូរនាមករណ៍

ខ. ការផ្លាស់ប្តូរទម្រង់ក្រុមហ៊ុន

គ. ការកែប្រែវិសាលភាពអាជីវកម្ម

ឃ .ការផ្លាស់ប្តូរដើមទុនចុះបញ្ជី

ង. ការកែប្រែលក្ខន្តិកៈ

ច. ការផ្លាស់ប្តូរទីតាំងអាជីវកម្ម

ឆ. ការផ្លាស់ប្តូរអភិបាល ឬអ្នកគ្រប់គ្រងជាន់ខ្ពស់

ជ. ការរួមបញ្ចូល ឬការបែងចែកឬ

ឈ.បញ្ហាផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៣
## អនុមតិផ្តល់អាជ្ញាបណ្ណ និង ការយកតម្លៃ

**ប្រការ ៦.- ការផ្តល់លិខិតអនុញ្ញាតជាគោលការណ៍**

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចរបស់ខ្លួន ក្នុងរយៈពេល ៣ខែ(បីខែ) ចាប់ពីពេលបានទទួលពាក្យស្នើសុំពេញលេញ។ ក្នុងករណីចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់

លក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាត។ ប្រសិនបើពុំបានអនុវត្តតាមពេលវេលាកំណត់ ឬពុំបានសុំពន្យារពេល លិខិតអនុញ្ញាតនោះត្រូវចាត់ទុកជាមោឃៈ។

**ប្រការ៧.- អនុមតិផ្តល់អាជ្ញាបណ្ណ**

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបំពេញគ្រប់លក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតជាគោលការណ៍ជាមុនសិន មុននឹងទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

**ប្រការ៨.- សុពលភាពនៃអាជ្ញាបណ្ណ**

អាជ្ញាបណ្ណរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានសុពលភាពរយៈពេល៥ឆ្នាំ (ប្រាំឆ្នាំ) ហើយអាចសុំបន្តជាថ្មីទៀតបាន។

**ប្រការ៩.- សោហ៊ុយសិក្សាឯកសារ និងសោហ៊ុយអាជ្ញាបណ្ណ**

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបង់សោហ៊ុយសិក្សាឯកសារចំនួន ៥០០.០០០ រៀល (ប្រាំរយពាន់រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំត្រូវបង់មុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំដូចខាងក្រោមៈ

- ៤.០០០.០០០រៀល (បួនលានរៀល) សម្រាប់ស្នាក់ការកណ្តាល
- ២.០០០.០០០រៀល (ពីរលានរៀល) ក្នុងមួយសាខា។

សម្រាប់ក្រុមហ៊ុនដែលបង្កើតនៅក្នុងឆ្នាំ សោហ៊ុយអាជ្ញាបណ្ណត្រូវបង់តាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។

## ជំពូកទី ៤
## វិធានប្រុងប្រយ័ត្ន

**ប្រការ១០.- ការបង់ដើមទុន**

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបង់ជម្រះ ១០០% (មួយរយភាគរយ) នៃដើមទុនចុះបញ្ជីទៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមប្រតិបត្តិការ។

ក្រុមហ៊ុនត្រូវតម្កល់ប្រាក់ចំនួន៥% (ប្រាំភាគរយ) នៃដើមទុនចុះបញ្ជី ដោយគ្មានការប្រាក់នៅក្នុងគណនីអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជានឹងប្រគល់ប្រាក់តម្កល់ឲ្យក្រុមហ៊ុនវិញ តែក្នុងករណីជម្រះបញ្ជី និងគ្មានបំណុល។

**ប្រការ ១១.- កាតព្វកិច្ចរាយការណ៍**

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តតាមកាតព្វកិច្ចរាយការណ៍ ដូចខាងក្រោម ៈ

១. ក្រុមហ៊ុនត្រូវបង្ហាញព័ត៌មាន ស្របតាមស្តង់ដារគណនេយ្យសម្រាប់អាជីវកម្មសហគ្រាស និងបញ្ញត្តិនានារបស់ធនាគារជាតិនៃកម្ពុជា។

២. ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍គណនេយ្យការ របាយការណ៍ចំណូលនិងចំណាយ និងរបាយការណ៍ដទៃទៀតតាមតម្រូវការរបស់អាជ្ញាធរត្រួតពិនិត្យ។ តំណាងស្របច្បាប់ និងអ្នកទទួលខុសត្រូវដទៃទៀតនៃក្រុមហ៊ុន ត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនៃរបាយការណ៍ទាំងអស់។

៣. ក្រុមហ៊ុនត្រូវផ្ញើរបាយការណ៍ប្រចាំខែមកធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល១៥ថ្ងៃ (ដប់ប្រាំថ្ងៃ) ដំបូងនៃខែបន្ទាប់។

៤. ក្រុមហ៊ុនត្រូវផ្ញើរបាយការណ៍សវនកម្មប្រចាំឆ្នាំ បញ្ជាក់ដោយសវនករដែលបានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល៤ខែ (បួនខែ) ដំបូងនៃឆ្នាំបន្ទាប់។

## ប្រការ ១២.- បទប្បញ្ញត្តិប្រុងប្រយ័ត្ន

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា ដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៥
## រចនាសម្ព័ន្ធភាគហ៊ុន និងអភិបាលកិច្ច

## ប្រការ ១៣. ភាគទុនិក

ភាគទុនិកត្រូវផ្ដល់ព័ត៌មានមកធនាគារជាតិនៃកម្ពុជាដូចខាងក្រោម៖

១. អត្តសញ្ញាណនៃភាគទុនិក :

ក. ក្នុងករណីជានីតិបុគ្គល ត្រូវផ្ដល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋាននៃស្នាក់ការកណ្ដាល របាយការណ៍សវនកម្មហិរញ្ញវត្ថុ លក្ខន្តិកៈ និងព័ត៌មានផ្សេងទៀតដែលតម្រូវដោយអាជ្ញាធរត្រួតពិនិត្យ

ខ ក្នុងករណីជារូបវន្តបុគ្គល ត្រូវរៀបរាប់ គោត្តនាម នាម ទីកន្លែង និងថ្ងៃខែឆ្នាំកំណើត សញ្ជាតិ អាសយដ្ឋាន និងឯកសារពាក់ព័ន្ធផ្សេងទៀត។

២. ភាគរយនៃភាគហ៊ុនដែលកាន់កាប់ និងភាគរយនៃសិទ្ធិបោះឆ្នោត ដោយរៀបរាប់លំអិតអំពីនីតិវិធីនៃការទិញភាគហ៊ុន។ ប្រសិនបើភាគទុនិកជាឯកត្តជន ត្រូវបញ្ជាក់ច្បាស់លាស់ពីប្រភពដើមនៃទុនវិនិយោគ។

៣. ការបញ្ជាក់ពីចំនួនភាគរយនៃភាគហ៊ុនដែលកាន់កាប់ដោយភាគទុនិកម្នាក់ៗ ក្នុងករណីចាំបាច់ភាគទុនិកត្រូវ :

ក. រៀបរាប់អំពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនហូលឌីង (Intermediate Holding Companies) ដោយផ្ដល់ជាភាគរយនៃភាគហ៊ុន និងសិទ្ធិបោះឆ្នោត

ខ. ផ្ញើបញ្ជីអ្នកគ្រប់គ្រងសំខាន់ៗដែលជាភាគទុនិក។

៤. ប្រសិនបើភាគទុនិកនោះជាផ្នែកនៃសម្ព័ន្ធមួយ ភាគទុនិកត្រូវ :

ក. រៀបរាប់អំពីក្រុមហ៊ុនសំខាន់ៗនៃសម្ព័ន្ធនោះ រួមជាមួយរង្គការលេខផង

ខ. បញ្ជាក់អំពីចំនួនភាគហ៊ុននៅក្នុងគ្រឹះស្ថានឥណទានផ្សេងទៀត ទាំងនៅក្នុងប្រទេស និងនៅបរទេស។

៥. ចំណងទាក់ទងរវាងភាគទុនិក និងក្រុមហ៊ុនដែលមានសកម្មភាពហិរញ្ញវត្ថុ ដូចជា ធនាគារ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

៦. នីតិវិធីសវនកម្មផ្ទៃក្នុង និងសវនកម្មខាងក្រៅរបស់ភាគទុនិក។

៧. សាវតារនៃអំពើល្មើសរបស់ភាគទុនិកក្នុងរយៈពេល១០ឆ្នាំ (ដប់ឆ្នាំ)កន្លងមក ប្រសិនបើមាន។

៨. គោលដៅរបស់ភាគទុនិកក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងក្រុមហ៊ុន ដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធ។

៩. ទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិក និងអ្នកដាក់ពាក្យស្នើសុំ។

១០.ទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងកតិសន្យាហិរញ្ញវត្ថុរបស់ភាគទុនិកនៅព្រះរាជាណាចក្រកម្ពុជា។

១១. គណនីរបស់ភាគទុនិក ឬក្រុមហ៊ុនមេរបស់ខ្លួន សំរាប់រយៈពេល៣ឆ្នាំ (បីឆ្នាំ) ចុងក្រោយព្រមទាំងព្យាករណ៍សំរាប់ឆ្នាំនេះ (រួមមានព័ត៌មានគួបសរុបផង ប្រសិនបើមាន)។ ក្នុងករណីភាគទុនិកជាគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវផ្តល់ព័ត៌មានពីអនុបាតប្រុងប្រយ័ត្នសំខាន់ៗ។

១២.អភិបាលកិច្ចក្រុមហ៊ុន (រចនាសម្ព័ន្ធចាត់តាំង សន្និបាតប្រចាំឆ្នាំរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាត្រួតពិនិត្យ និងនាយកជាន់ខ្ពស់) ដោយបែងចែកភារកិច្ចឲ្យបានច្បាស់លាស់ ធានាប្រតិបត្តិការដោយឯករាជ្យ និងប្រព័ន្ធត្រួតពិនិត្យមានតម្លាភាព ព្រមទាំងបង្កើតយន្តការគោលនយោបាយប្រកបដោយប្រសិទ្ធភាព យន្តការលើកទឹកចិត្ត និងរក្សាបុគ្គលិក។

១៣.គោលនយោបាយ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

## ប្រការ ១៤.- សមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាភិបាល និងនាយក

បុគ្គលណាក៏មិនអាចជាសមាជិកក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាត្រួតពិនិត្យ ឬនាយករបស់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ឬដឹកនាំ គ្រប់គ្រង ឬដំណើរការក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណដោយផ្ទាល់ ឬតាមរយៈអន្តរការីក្នុងទម្រង់ណាក៏ដោយ ឬត្រូវបានផ្តល់សិទ្ធិចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន ប្រសិនបើរូបវន្តបុគ្គលនោះ៖

១. ត្រូវបានផ្តន្ទាទោសពីបទៈ

- ឧក្រិដ្ឋកម្ម
- ចោរកម្ម ឆបោក ឬរំលោភលើការទុកចិត្ត
- គ្រប់គ្រងមិនបានត្រឹមត្រូវក្នុងតួនាទីខ្លួនជាអ្នករក្សាប្រាក់បញ្ញើ
- គេបន្លំមូលនិធិ ឬមូលបត្រ ឬក្ស័យធន
- ធ្វើព្រឹទ្ធិកម្ម
- ការសម្អាតប្រាក់
- ក្លែងបន្លំ/និងប្រើលិខិតឯកជន ឬសាធារណៈក្លែងក្លាយ។

២. ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទចេញមូលប្បទានបត្រគ្មានសាច់ប្រាក់។

៣. ត្រូវបានផ្តន្ទាទោសជាស្ថាពរនៅបរទេសពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលមានចែងនៅក្នុងចំណុច១ និង២ ខាងលើ។

៤. ត្រូវបានផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសពីបទក្ស័យធន ឬការជម្រះបំណុលតាមផ្លូវតុលាការ ឬការជម្រះទ្រព្យសម្បត្តិ។

៥. ត្រូវរងវិធានការតាមផ្លូវតុលាការ ដោយការគម្លោះបេសពីមុខងារសាធារណៈ។

៦. ត្រូវបានទទួលរងទណ្ឌកម្មខាងវិន័យក្នុងការគ្រប់គ្រងគ្រឹះស្ថានចំពោះច្បាប់នេះ ដែលអាជ្ញាប័ណ្ណត្រូវបានដកហូត។

សមាជិកក្រុមប្រឹក្សាភិបាល និងនាយកដែលត្រូវបានតែងតាំង ត្រូវផ្តល់ព័ត៌មានដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

## ជំពូកទី ៦
## វិធានការ និង ការពិន័យ

### ប្រការ ១៥ សិទ្ធិអំណាចរបស់អាជ្ញាធរត្រួតពិនិត្យ

១ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចក្នុងការផ្តល់ ព្យួរ ដកហូតអាជ្ញាប័ណ្ណ ដាក់បទប្បញ្ញត្តិ បទបញ្ជា និងការណែនាំសម្រាប់ត្រួតពិនិត្យ អាជីវកម្មរបស់ក្រុមហ៊ុន តាមការចាំបាច់។

២ ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាប័ណ្ណ ដោយផ្អែកលើមូលហេតុមួយ ឬច្រើន ដូចខាងក្រោម:

ក ក្រុមហ៊ុនមិនបានចាប់ផ្តើមអាជីវកម្មក្នុងកំឡុងពេលបីខែ បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណ

ខ. ក្រុមហ៊ុនបំពានច្បាប់ ឬបទប្បញ្ញត្តិ ដែលគ្រប់គ្រងលើប្រតិបត្តិការក្រុមហ៊ុន

គ ក្រុមហ៊ុនមិនអាចប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព

ឃ ក្រុមហ៊ុនផ្អាកអាជីវកម្មភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា

ង.ក្រុមហ៊ុនស្ម័គ្រចិត្តបញ្ឈប់ប្រតិបត្តិការ បន្ទាប់ពីទទួលបានការយល់ព្រមពីអាជ្ញាធរត្រួតពិនិត្យ

ច ក្រុមហ៊ុនអសាធនភាព ឬក្ស័យធន ឬស្ថិតក្នុងដំណើរការជម្រះបញ្ជី ឬក្នុងដំណាក់កាលតែងតាំងអភិបាលបណ្តោះអាសន្នតាមផ្លូវតុលាការ។

### ប្រការ ១៦ វិធានការចំពោះក្រុមហ៊ុន

១ ក្នុងករណីក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុបានប្រព្រឹត្តល្មើសនឹងច្បាប់ភតិសន្យាហិរញ្ញវត្ថុ ឬបទប្បញ្ញត្តិជាធរមាន ធនាគារជាតិនៃកម្ពុជានឹងដាក់ទណ្ឌកម្មខាងវិន័យចំពោះក្រុមហ៊ុននោះយោងតាមមាត្រា ៣៥ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ។

២ ប្រសិនបើក្រុមហ៊ុនបានប្រព្រឹត្តល្មើសនឹងខ្លឹមសារនៃប្រកាសនេះ ធនាគារជាតិនៃកម្ពុជា អាចចាត់វិធានការកែតម្រូវក្នុងរយៈពេលកំណត់មួយ។ ក្នុងករណីក្រុមហ៊ុនមិនអាចអនុវត្តបានតាមពេលកំណត់ ឬសកម្មភាពរបស់ក្រុមហ៊ុនអាចប៉ះពាល់ដល់ស្ថិរភាពប្រតិបត្តិការ ឬប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់អតិថិជន ធនាគារជាតិនៃកម្ពុជានឹងចាត់វិធានការ ដូចជា ផ្អាកដំណើរការអាជីវកម្ម និងកំណត់សិទ្ធិរបស់ភាគទុនិក ជាដើម ផ្អែកទៅលើស្ថានភាពជាក់ស្តែង និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ ១៧.- ពិន័យអន្តរការណ៍**

បន្ថែមលើទណ្ឌកម្មខាងវិន័យ ធនាគារជាតិនៃកម្ពុជានឹងដាក់ពិន័យអន្តរការណ៍ដូចខាងក្រោម៖

១. ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដែលមិនបានគោរពតាមកាលកំណត់នៃការបញ្ជូនរបាយការណ៍នឹងត្រូវពិន័យដូចខាងក្រោម៖

ក. ចំពោះរបាយការណ៍៖

| ចំនួនថ្ងៃដែលយឺតយ៉ាវ | ចំនួនទឹកប្រាក់ |
|---|---|
| ▪ ពី ១ទៅ ៥ ថ្ងៃ | ៥០.០០០ រៀល (ហាសិបពាន់រៀល) ក្នុងមួយថ្ងៃ |
| ▪ ពី ៦ទៅ ១០ ថ្ងៃ | ៣០០.០០០ រៀល (បីរយពាន់រៀល) ក្នុងមួយថ្ងៃ |
| ▪ ពី ១១ទៅ ១៥ ថ្ងៃ | ៧០០.០០០ រៀល (ប្រាំពីររយពាន់រៀល) ក្នុងមួយថ្ងៃ។ |

លើសពី១៦ថ្ងៃឡើងទៅ ក្រុមហ៊ុនត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងការផ្សព្វផ្សាយជាសាធារណៈ។

ខ.ចំពោះលិខិតឆ្លើយតប និងការផ្តល់ព័ត៌មានផ្សេងៗ ៖

| ចំនួនថ្ងៃដែលយឺតយ៉ាវ | ចំនួនទឹកប្រាក់ |
|---|---|
| ▪ ពី ១ទៅ ៥ ថ្ងៃ | ៥០.០០០ រៀល (ហាសិបពាន់រៀល) ក្នុងមួយថ្ងៃ |
| ▪ ពី ៦ទៅ ១០ ថ្ងៃ | ៣០០.០០០ រៀល (បីរយពាន់រៀល) ក្នុងមួយថ្ងៃ។ |

លើសពី១១ថ្ងៃឡើងទៅ ក្រុមហ៊ុនត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងការផ្សព្វផ្សាយជាសាធារណៈ។

២. ការល្មើសនឹងបទប្បញ្ញត្តិជាធរមាន ត្រូវពិន័យទឹកប្រាក់ ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃ គិតចាប់ពីថ្ងៃប្រសិទ្ធភាពដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ១៨.-**

បុគ្គល ឬក្រុមហ៊ុនដែលបាន និងកំពុងធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុដោយមិនមានអាជ្ញាបណ្ណ ត្រូវស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៦ខែ (ប្រាំមួយខែ) គិតចាប់ពីថ្ងៃដែលប្រកាសនេះចូលជាធរមាន។

**ប្រការ ១៩.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២០.-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០១១

**ទេសាភិបាល**

**ជា.ចាន់តូ**

**កន្លែងទទួល** :

- ដូចប្រការ១៩
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន** :

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**ឧបសម្ព័ន្ធទី ១**

## គំរូលិខិត
## សូមគោរពជូន ឯកឧត្តមទេសាភិបាល ធនាគារជាតិនៃកម្ពុជា

ឯកឧត្តមជាទីគោរព

យោងតាមការតែងតាំងនាយកក្រុមហ៊ុន (ឈ្មោះក្រុមហ៊ុន) ដែលខ្ញុំនឹងចូលកាន់តំណែងជា... ....... ខ្ញុំសូមជូនភ្ជាប់មកជាមួយនូវព័ត៌មាន (រួមមានប្រវត្តិសង្ខេប និងសំនួរដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២) តាមប្រការ ១៣ នៃប្រកាសនេះ។

ខ្ញុំសូមធានាថាព័ត៌មាននេះពិតជាត្រឹមត្រូវ និងពេញលេញ ឆ្លើយតបទៅនឹងតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា។ ជាពិសេស ខ្ញុំសូមធានាអះអាងថា ខ្ញុំពិតជាគ្មានជាប់ទាក់ទិនទៅនឹងការហាមឃាត់ណាមួយក្នុងប្រការ១៤ នៃប្រកាសនេះទេ។

ខ្ញុំសូមសន្យាថានឹងផ្តល់ព័ត៌មានស្តីពីការផ្លាស់ប្តូរណាមួយ ដែលទាក់ទងទៅនឹងព័ត៌មានខាងលើជូនធនាគារជាតិនៃកម្ពុជាភ្លាម។

បន្ថែមលើនេះទៀត ក្នុងនាមជានាយកក្រុមហ៊ុន ខ្ញុំសូមធានាថា នឹងផ្តល់ជូនធនាគារជាតិនៃកម្ពុជានូវរាល់ព័ត៌មានដែលទាក់ទងនឹងការចាត់តាំងរដ្ឋបាលនិងគណនេយ្យ ស្ថានភាពហិរញ្ញវត្ថុ ជាពិសេសចំពោះគុណភាពនៃទ្រព្យសម្បត្តិភតិសន្យា និងស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិកទាំងអស់។

សូម ឯកឧត្តម ទេសាភិបាល មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រអំពីខ្ញុំ៕

ហត្ថលេខា

**ឧបសម្ព័ន្ធទី ២**

# ជីវប្រវត្តិ និង ការសាកសួរនូវព័ត៌មាន អំពីឯកត្តជន ឬ ជនដែលបំរុងក្លាយទៅជា គណៈនាយក ភាគទុនិក នាយកចាត់ការ របស់អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ

១. គោត្តនាម

..............................................................................................................................

២. នាមខ្លួន

..............................................................................................................................

៣. ឈ្មោះហៅក្រៅ

..............................................................................................................................

៤.១ សូមរៀបរាប់បំពេញលើគំរូនេះនូវនីតិសម្បទារបស់លោក ឧទាហរណ៍ដូចជាៈ គណៈនាយកបច្ចុប្បន្ន ឬ ជាអនាគតគណៈនាយក ភាគទុនិក ឬ នាយកចាត់ការ ឬ បុគ្គលដែលមានលក្ខណៈប្រហាក់ប្រហែល។

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

៤.២ សូមរៀបរាប់រាំពីកាតព្វកិច្ច និងការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងឋានៈ តួនាទីទាំងនេះ

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

៤.៣ ក្នុងការអនុវត្តភារកិច្ចរបស់អ្នក តើអ្នកនឹងសហប្រតិបត្តិការជាមួយ ឬបើស្រេចតាមការបង្គាប់បង្ហាញ របស់រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ។ ក្នុងករណីណាមួយក៏ដោយសូមផ្តល់នូវ ព័ត៌មានដែលពាក់ព័ន្ធទាំងនេះ។

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..........................................................................................................................................

៤.៤ សូមរៀបរាប់បើសិនជាអ្នកជាអ្នកផ្តល់ទុនម្នាក់ទៅឲ្យអ្នកដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីកម្មមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការវិជ្ជាជីវៈជាមួយបេក្ខជនសុំនោះ។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៥. អាសយដ្ឋានផ្ទាល់ខ្លួន

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៦. អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីកំឡុង ៥ឆ្នាំមុនៈ

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៧. កាលបរិច្ឆេទ (ថ្ងៃ/ ខែ/ ឆ្នាំ) និងទីកន្លែងកំណើត (គិតទាំងស្រុកនិងក្រុង)

..........................................................................................................................................

..........................................................................................................................................

៨. សញ្ជាតិ ហើយតើសញ្ជាតិនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ សញ្ជាតូបនីយកម្ម ការរៀបអាពាហ៍ពិពាហ៍)

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៩. ឈ្មោះ និង អាសយដ្ឋាននៃធនាគារិករបស់លោក- លោកស្រី ក្នុងរយៈកាល៥ឆ្នាំកន្លងមក

..........................................................................................................................................

..........................................................................................................................................

..................................................................................................................................

..................................................................................................................................

១០. ចូរបញ្ជាក់ពី កំរិតចំណេះដឹង និង គុណវុឌ្ឍិវិជ្ជាជីវៈព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

១១.១ ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំកន្លងមក ដោយបញ្ជាក់ពី ឈ្មោះ អាសយដ្ឋាន របស់និយោជកក្នុងករណីនីមួយៗ ចរិតនៃមុខជំនួញ ស្ថានភាពដែលមាន និងកាលបរិច្ឆេទពាក់ព័ន្ធ។

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

១១.២ សូបរៀបរាប់កាលពី១០ឆ្នាំមុន បើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ១០ភាគរយយ៉ាងតិចនៃដើមទុន ឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមានសូមរៀបរាប់ឈ្មោះ និងសកម្មភាពក្រុមហ៊ុននេះ និងចំនួនភាគហ៊ុន ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ។

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

១១.៣ សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នក ចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវក្នុងតំណែងក្រុមហ៊ុនមួយឬជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ។

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

១២. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមប្រាស្រ័យក្នុងឋានៈជានាយក ជាភាគទុនិក ឬជាអ្នកចាត់ការ ធ្លាប់ទទួលឬធ្លាប់ស្នើសុំអាជ្ញាបណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញនៅក្នុងប្រទេសណាមួយដែរឬទេ បើមាន សូមបញ្ជាក់នូវចំណុចពិសេស ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបានដកហូតការអនុញ្ញាតក៏ត្រូវបញ្ជាក់ចំណុចពិសេសដែរ។

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

១៣. តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធជាមួយក្នុងការអនុវត្តកិច្ចការរបស់ខ្លួន ធ្លាប់ត្រូវបានអាជ្ញាធរអាណាព្យាបាល ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវគេធ្វើការស៊ើបអង្កេតដែរឬទេ បើមានសូមបញ្ជាក់។

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

១៤. តើខ្លួនលោក-លោកស្រី ធ្លាប់ត្រូវគេហាមមិនឲ្យចូលប្រកបវិជ្ជាជីវៈជំនាញ ឬបំរើការងារណាមួយដែរឬទេ បើមានសូមបញ្ជាក់។

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

១៥ តើធ្លាប់មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល និងប្រាក់ដែលត្រូវសងគេដែរឬទេ តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តដែរឬទេ នៅប្រទេសណា តើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗឲ្យបានច្បាស់លាស់។

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

១៦. តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើស នៅប្រទេសណា, តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះ ឬការប្រព្រឹត្តឆ្គាំឆ្គងផ្សេងៗ ដែលមានចំពោះអង្គភាពណាមួយ ឬសមាជិកណាម្នាក់ដែរឬទេ, តើធ្លាប់ត្រូវបានគេចោទប្រកាន់ ឬរកឃើញនូវកំហុសនៃការសម្អាតប្រាក់ដែរឬទេ, បើសិនជាមាន សូមបញ្ជាក់ករណីនីមួយៗឲ្យបានច្បាស់លាស់។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៧. បច្ចុប្បន្ននេះ ក្រៅពីសមត្ថភាពវិជ្ជាជីវៈ តើលោក-លោកស្រីមានការពាក់ព័ន្ធនឹងការប្តឹងផ្តល់នៅប្រទេសណាមួយទេ បើមានសូមបញ្ជាក់ឲ្យច្បាស់លាស់។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៨. សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យ ស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលំអិតស្តីពីទ្រព្យសកម្មនិងទ្រព្យអកម្ម។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៩. សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងតួនាទី ឬកិត្តិនាម របស់ឯកត្តជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អ ដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ)។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

២០. បើសិនជាមានព័ត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ-តួនាទីផ្ទាល់ខ្លួន ដូចមានបញ្ជាក់ក្នុងសំណួរ ៤.១ សាមីជនគួរតែបញ្ជាក់បន្ថែមឲ្យបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សំរាប់ការពិនិត្យ

ពិចារណាឲ្យត្រឹមត្រូវតាមទម្រង់គតិយុត្ត។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗ ដែលពាក់ព័ន្ធដោយបង្វែរព័ត៌មានពិត ឬផ្តល់ឲ្យនូវព័ត៌មានខុសពីការពិតនឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន (សូមអានសេចក្តីប្រកាសដូចខាងក្រោម)៖

**ចូរកត់សំគាល់ឲ្យបានច្បាស់ថា:** រាល់ព័ត៌មានដែលបានផ្តល់ឲ្យ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសម្ងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់ឲ្យស្របតាមទម្រង់គតិយុត្ត។

## សេចក្តីប្រកាស ឬកិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយ ឬខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាបណ្ណប្រកបអាជីវកម្ម។

ខ្ញុំសូមបញ្ជាក់ជូនជាឧឡារិកថា ព័ត៌មានដែលបានឲ្យជាចម្លើយចំពោះសំណួរខាងលើគឺពិតជាត្រឹមត្រូវ និងបានបំពេញបរិបូរណ៍ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ណាផ្សេងឬផ្ទុយពីសេចក្តីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (សមត្ថកិច្ច) ដើម្បីជ្រាបនោះឡើយ។

ខ្ញុំសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពីរឿងរ៉ាវ ឬហេតុការណ៍ ដែលត្រូវផ្លាស់ប្តូរណាមួយដែលកើតមាន នៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណា លើពាក្យស្នើសុំរបស់យើងខ្ញុំជ្រាបជាព័ត៌មាន។

ឈ្មោះ

..................................................................................................................................................

មុខងារ និងឋានៈដែលទទួលបន្ទុក

..................................................................................................................................................

ហត្ថលេខា.......................................................................ថ្ងៃទី..........ខែ................. ឆ្នាំ..................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០១១.២៤៣ ប្រ.ក

# ប្រកាស
## ស្តីពី
## តម្លាភាពក្នុងការផ្តល់សេវាឥណទាន របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រកបដោយតម្លាភាព យុត្តិធម៌ សមហេតុផល និងទទួលខុសត្រូវ។

**ប្រការ ២.-**

គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថាការផ្សព្វផ្សាយពាណិជ្ជកម្ម និងពាក្យពេចន៍ក្នុងការផ្សព្វផ្សាយមានលក្ខណៈយុត្តិធម៌ ច្បាស់លាស់ មិនធ្វើឲ្យភាន់ច្រឡំ និងត្រូវធានាថាអតិថិជនបានទទួលព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មទាំងឡាយ។

**ប្រការ ៣.-**

អតិថិជនត្រូវទទួលបានព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មទាំងឡាយ នៅមុនពេល ឬក្នុងពេល ឬបន្ទាប់ពីពេលទទួលសេវាឥណទាន ដោយរួមមានបែបបទដំណើរការនៃឥណទាន លក្ខខណ្ឌ អត្រាការប្រាក់ និងកម្រៃដែលជាបន្ទុករបស់អតិថិជន ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤.-**

អតិថិជនត្រូវទទួលបានព័ត៌មានជាមុន អំពីការប្រែប្រួលអត្រាការប្រាក់ កម្រៃ និងលក្ខខណ្ឌផ្សេងៗ។

**ប្រការ ៥.-**

ព័ត៌មានអតិថិជនត្រូវបានរក្សាទុកជាការសម្ងាត់ ហើយគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្តល់ជូនអតិថិជននូវប្រព័ន្ធធនាគារស្នួល និងប្រព័ន្ធទូទាត់ដែលមានសុវត្ថិភាព និងអាចជឿទុកចិត្តបាន។ ការរក្សាព័ត៌មានអតិថិជនជាសម្ងាត់មិនត្រូវអនុវត្តចំពោះការផ្តល់ព័ត៌មានអតិថិជនដល់ប្រព័ន្ធព័ត៌មានឥណទាននោះទេ។

**ប្រការ ៦.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

**ទេសាភិបាល**

**ជា.ចាន់តូ**

**កន្លែងទទួល** :

- ដូចប្រការ ៦
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន** :

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

*ឧបសម្ព័ន្ធ*

## តារាងព័ត៌មានសម្រាប់អតិថិជន

តារាងនេះសម្រាប់ផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ តារាងនេះកំណត់ចេញនូវថ្លៃដើមពេលបច្ចុប្បន្ន និងកម្រៃផ្សេងៗសម្រាប់ឥណទានដែលទទួលបាន ហើយធនាគារអាចកែប្រែថ្លៃដើម និងកម្រៃទាំងនេះ ក្នុងករណីចាំបាច់។ សូមមេត្តាកត់សំគាល់ថាការផ្តល់នូវតារាងនេះមិនត្រូវចាត់ទុកថាជាការផ្តល់ឥណទានដល់អតិថិជនដោយធនាគារនោះទេ។

ឈ្មោះធនាគារ/និមិត្តសញ្ញា

ឈ្មោះអ្នកសួរព័ត៌មាន ____________

១. សាខា ____________

ប្រភេទនៃខ្ចង់ឥណទាន ____________

**ចំនួនឥណទាន និងការប្រាក់/កម្រៃផ្សេងៗរបស់ធនាគារ**

(គិតជាប្រាក់រៀល)

២. ចំនួនស្នើសុំ(ចំនួនប្រាក់ដើម) ________

៣. (ដក: ចំនួនត្រូវទូទាត់ក្នុងគ្រាទី១/ការប្រាក់បានបង់មុន) ________

៤. ចំនួនសុទ្ធដែលអតិថិជនបានទទួល ________

៥. អត្រាដែលស្នើសុំ ________ %ក្នុង១ឆ្នាំ

៦. អត្រាការប្រាក់មានប្រសិទ្ធភាព ________ %ក្នុង១ឆ្នាំ

៧. ការទូទាត់ប្រចាំខែ ________

៨. ចំនួនដងដែលត្រូវទូទាត់សង ________

៩. ការប្រាក់សរុប ________

១០. កម្រៃធ្វើប្រតិបត្តិការ ________

១១. កម្រៃផ្សេងៗរបស់ធនាគារ (សូមបញ្ជាក់ ប្រសិនបើមាន)

____________________ ________

១២. កម្រៃផ្សេងៗសរុប (ជួរទី១០ + ជួរទី១១) ________

១៣. ការប្រាក់សរុបបូកកម្រៃផ្សេងៗសរុប (ជួរទី៩ + ជួរទី១២) ________

១៤. សរុបចំនួននៅជំពាក់ (ជួរទី២ + (៣) ឬជួរទី៤ + ជួរទី១៣) ________

១៥. កាលបរិច្ឆេទនៃការចាប់ផ្តើមទូទាត់សង ____________

## <u>កម្រៃបន្ថែម</u>

ធនាគារនឹងគិតកម្រៃសម្រាប់

| | ការទូទាត់សងដោយផ្នែក | ការទូទាត់សងពេញលេញ |
|---|---|---|
| **(ក) ការទូទាត់សងឥណទានមុនពេលកំនត់** | | |
| ១៦.ប្រសិនបើសងក្នុងកំឡុងពេល | ________ឆ្នាំ | ________ឆ្នាំ |
| ១៧.ចំនួននៃការទូទាត់សងអប្បបរមាគឺ | ________ | |
| ១៨.កម្រៃលើការទូទាត់សងមុនពេលកំណត់ | ________ | ________ |
| ១៩.កម្រៃធ្វើប្រតិបត្តិការ | ________ | ________ |
| ២០.កំឡុងពេលជូនដំណឹងដែលតម្រូវ | ________ | ________ |

**(ខ) ការទូទាត់យឺតយ៉ាវតាមគ្រានិមួយៗ**

| | |
|---|---|
| ២១.ការប្រាក់ដែលត្រូវគិតគឺ | ________ %ក្នុង១ឆ្នាំ (សម្រាប់ចំនួនដែលជំពាក់) |
| ២២.កម្រៃធ្វើប្រតិបត្តិការ | ________ |
| ២៣.កម្រៃផ្សេងៗ | ________________ |

## <u>កម្រៃសម្រាប់តតិយជន</u>

២៤. ព័ត៌មានខាងលើ មិនរាប់បញ្ចូលកម្រៃសម្រាប់តតិយជន មានដូចជាតែមប្រ៍ កម្រៃផ្នែកច្បាប់ កម្រៃលើការវាយតំលៃ បុព្វលាភធានារ៉ាប់រង។ល។ សូមមេត្តាត្រួតពិនិត្យជាមួយគូរភាគីខាងលើស្តីពីកម្រៃទាំងឡាយ។

**គោលនយោបាយធានារ៉ាប់រងដែលទាមទារឲ្យមាន**

---

មន្ត្រីដែលមានវត្តមាន ________________ ហត្ថលេខា ________________

កាលបរិច្ឆេទ ________________

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០១១-២៤១ ប្រ.ក

# ប្រកាស
## ស្ដីពី
## អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០៩/០០៨ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្ដីពីការតែងតាំង **ឯកឧត្ដម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាមានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

## សម្រេច

**ប្រការ ១**.-

ប្រកាសនេះ មានគោលបំណងបង្កើត លើកកម្ពស់ និងអភិវឌ្ឍវិស័យភតិសន្យាហិរញ្ញវត្ថុសំដៅផ្ដល់គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិករភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារ អាចធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដែលជាផ្នែកមួយនៃប្រតិបត្តិការរបស់ធនាគារដូចមានចែងក្នុងមាត្រា ២ ចំណុចទី១ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងមាត្រា៣៤ កថាខ័ណ្ឌទី១ នៃ

ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ។ គ្រឹះស្ថានធនាគាររួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គ្រឹះស្ថានធនាគារត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានធនាគារត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។

គ្រឹះស្ថានផ្សេងទៀតដែលមានបំណងផ្តល់ឬកំពុងផ្តល់ផលិតផលភតិសន្យាហិរញ្ញវត្ថុ ត្រូវសុំអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា។ លក្ខខណ្ឌសម្រាប់ស្នើសុំអាជ្ញាប័ណ្ណត្រូវបានកំណត់ដោយប្រកាសដោយឡែក។

**ប្រការ ៣.-**

ភតិសន្យាហិរញ្ញវត្ថុ សំដៅដល់ភតិសន្យាសម្រាប់រយៈពេលដំបូងមួយឆ្នាំ ឬច្រើនជាងដែលរយៈពេលនោះមិនអាចកែប្រែបាន ក្នុងនោះ៖

១.ភតិកៈបញ្ជាក់ច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ ដោយមិនផ្អែកសំខាន់លើជំនាញ និងការវិនិច្ឆ័យរបស់ភតិបតីឡើយ។

២.ភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុដើម្បីជួលឲ្យភតិកៈ។

ក៏ប៉ុន្តែ បើមានការជួលបន្តនូវចលនវត្ថុដែលបានជួលពីមុនពីភតិបតីដដែល ការជួលបន្តនោះអាចនៅតែជាភតិសន្យាហិរញ្ញវត្ថុដដែល។

ភតិសន្យាអាចជាភតិសន្យាហិរញ្ញវត្ថុ ដោយមិនគិតដល់៖

១. ការបង់ថ្លៃឈ្នួលភតិសន្យាត្រូវបានឬមិនត្រូវបានគណនាបញ្ចូលនូវការរំលស់ទាំងមូលឬការរំលស់មួយផ្នែកធំនៃតម្លៃចលនវត្ថុ ឬ

២.ភតិកៈមានឬពុំមានជម្រើសឬក្រោយមកទទួលយកជម្រើសថាទិញឬបន្តជួលចលនវត្ថុមួយរយៈពេលបន្ថែមទៀត។

**ប្រការ ៤.-**

ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានបំណងធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុត្រូវ៖

១. មានស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពប្រតិបត្តិការរឹងមាំ អនុបាតសាធនភាព និងអនុបាតផ្សេងៗទៀត ស្របតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

២. មានធនធានមនុស្ស និងសម្ភារៈគ្រប់គ្រាន់សម្រាប់ដំណើរការអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ។

៣. មានផែនការអាជីវកម្មច្បាស់លាស់ជាលាយលក្ខណ៍អក្សរសម្រាប់អាជីវកម្មភតិសន្យាហិរញ្ញវត្ថុដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាននោះ។ ផែនការនេះរួមបញ្ចូលនូវចំណុចសំខាន់ៗដូចខាងក្រោម៖

ក. គោលនយោបាយ និងនីតិវិធីសម្រាប់ប្រតិបត្តិការអាជីវកម្ម

ខ. សេចក្តីលម្អិតពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធរាយការណ៍សមស្រប។ សេចក្តីលម្អិតពីប្រព័ន្ធគ្រប់គ្រងហានិភ័យយ៉ាងហោចណាស់ត្រូវមាន៖

- ការវាយតម្លៃពីលំហូរសាច់ប្រាក់

- ប្រព័ន្ធវិភាគឥណទាន នីតិវិធីកំណត់កម្រិតឥណទានអតិថិជន និងនីតិវិធីកំណត់ប្រាក់កក់ និងកម្រៃផ្សេងៗ
- នីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ដូចជា ការទិញចលនវត្ថុ អ្នកផ្គត់ផ្គង់ ការគ្រប់គ្រងចលនវត្ថុដែលរឹបអូស ការតាមដាន និងត្រួតពិនិត្យចលនវត្ថុ ការវាយតម្លៃនៃតម្លៃសេសសល់របស់ចលនវត្ថុ និង
- ឯកទេសកម្ម និងការប្រមូលផ្តុំសមស្រប។

**ប្រការ ៥.-**

ចលនវត្ថុសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុសំដៅដល់ទ្រព្យសម្បត្តិគ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែ ដី និងអគារ។

លុះត្រាតែមានច្បាប់ ឬកិច្ចព្រមព្រៀងចែងផ្សេងពីនេះ ចលនវត្ថុដែលត្រូវបានភ្ជាប់ ឬត្រូវបានតម្លើងនៅក្នុងអគារ ឬលើដី ឬចលនវត្ថុដទៃទៀត ត្រូវរក្សាអត្តសញ្ញាណដាច់ដោយឡែករបស់ខ្លួន និងមិនក្លាយទៅជាចំណែកនៃដី ឬអគារ ឬចលនវត្ថុដទៃទៀតដែលត្រូវបានភ្ជាប់ជាមួយនោះទេ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨.-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

**ទេសាភិបាល**

**ជា.ចាន់តូ**

**កន្លែងទទួល** :

- ដូចប្រការ៧
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន** :

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

# Impact of the Eurozone Debt Crisis on Asia

## I. Introduction

Europe's sovereign debt crisis could have strong repercussions on developing Asia. Both the United Stated (US) and Eurozone are major markets for the region's exports and sources of financial capital and portfolio investments. Memories of the sharp slowdown from the 2008/09 "Great Recession" remains fresh. The region's financial sector and stock markets were battered as foreign investors fled to "safe havens" elsewhere. Many Asian economies suffered large declines in trade and output. Still, the region recovered quickly due to prompt and effective fiscal and monetary stimulus, fairly healthy financial systems, and stringent prudential regulations.

Thus far, the eurozone sovereign debt crisis has had limited impact on developing Asia's growth. While the region's economic expansion has moderated, it remains robust, roughly in line with recent historical trends. Financial systems have been little affected by global financial market volatility and have continued to channel funds to support economic activity. The economic resilience is partly due to the ongoing process of rebalancing sources of growth from external to domestic demand. For now, no large or mid-sized economies will likely experience a hard landing.

However, if conditions were to worsen in Europe, the impact on the region could be more severe and the crisis could last longer. With advanced economies' sovereign credit ratings under scrutiny, the scope for rescuing troubled financial institutions is limited. This may make it even harder to quickly resolve any new crisis.

Given Asia's diversity, different sub-regions face different priorities and challenges. One common priority is how to sustain economic growth and boost people's welfare. In East and Southeast Asia, the focus is likely to be on trade and financial integration. For South Asia, boosting productivity and moving to higher value production and services, while ensuring adequate employment opportunities, will be key challenges. In Central and West Asia, priorities include economic diversification and overcoming geographic constraints through greater and efficient connectivity.

For the most part, the region's financial systems show limited vulnerability and appear able to whether any impact from the euro zone crisis (barring a low probability "perfect storm" collapse—in which the euro tumbles sharply, yen borrowing rates rise, and growth falls sharply in the People's Republic of China (PRC), Japan, and other parts of Asia). Although Asia's exposure to euro zone and US banks is significant, external vulnerabilities for the region are lower than in 2007. In general, current account balances are healthy, and thus less susceptible to the impact of tightening liquidity, as they are less dependent on external borrowings. Also, the region's external debt exposure has improved from 2008. For the most part, foreign reserves are more than adequate and can comfortably cover imports and short-term external debt repayments. The region's banking systems also remain sound with sufficient capital adequacy ratios and—for now at least—low levels of nonperforming loans. During the global recession, the region's banking systems remained largely unaffected, and this overall soundness continues.

### 1. The impact on Financial Sector

With the global financial system closely intertwined, any financial system distress in Europe will have transmission effects on Asia. Over the past decade or so, the region's economies have liberalized their financial systems. While this has benefited economies, it has also made

the region more vulnerable to external shocks, given the effects of globalization and close integration with global financial markets. This became clear during the 2008/09 crisis when both Singapore and Hong Kong, China—the region's financial hubs—had the largest drop in output as measured against trend. In contrast, countries with smaller amounts of international financial assets saw far less disruption to output growth.

Failure to resolve the euro zone crisis would likely result in accelerated capital outflows similar to 2008, when, after Lehman Brothers collapsed, capital exited as a result of risk aversion and initial uncertainty over who held toxic sub-prime assets. Most capital outflows were in bank lending and portfolio investments, while foreign direct investment remained relatively stable. This suggests that, in the event of a deeper euro zone crisis, the channel of transmission to the region will likely be via a sudden drop in bank lending and portfolio investments.

Tighter global credit conditions would return should the euro zone crisis intensify, bringing a knock- on effect to the region's banking system liquidity. Politically, euro zone banks will find it easier to cut lending abroad rather than domestically; thus bank lending to the region would drop. Banks incorporated in the US and the United Kingdom with close ties to euro zone banks would likely be hurt as well.

A deeper or prolonged crisis in Europe would likely result in higher global risk aversion, drawing portfolio investors away from the region. Stock markets indexes in several of the region's economies could plummet once more, reducing investor confidence and hurt consumption through the wealth effect. It would also increase the cost of raising funds, thus depressing investment. It may also make raising capital in domestic financial markets more challenging. Co-movements between the region's stock markets and major global financial markets are increasing. Since the start of the euro zone sovereign debt crisis, Asian and euro zone stock markets have moved almost in lockstep. Apart from the stock market impact, bond markets will likely be affected. A crisis would likely push bond yields up in the region as foreign investors flee to "safe haven" assets. This could make it more difficult and expensive for companies to raise funds in bond markets, and firms could face liquidity crises should financing—including trade financing—become more difficult. Countries with more external bond holdings would likely be affected as fund outflows would have greater impact. Among the region's economies, Malaysia and Indonesia have large foreign holdings in government bonds.

In sum, the transmission of an exacerbated euro zone crisis to emerging Asia through the financial channel could be significant. Due to longer lags in data availability compared with trade flows for instance, a crisis impact may appear muted when in fact it is simply delayed. Therefore, providing liquidity support remains important, as does bolstering existing bilateral and other swap arrangements.

**2. The impact on Real Economy**

Ring-fencing the real sector against the impact of financial market contagion should the crisis escalate is critical.

The past four episodes of US or eurozone recessions show an increase in the impact of external shocks on Asia. As may be expected, the more export-oriented newly industrialized economies suffered more than the middle-income Association of Southeast Asian Nations (ASEAN) economies during these periods. Moreover, the PRC economy's sensitivity to recession in advanced economies has grown in consonance with its export growth.

A prolonged or deeper eurozone sovereign debt crisis will affect the region through the trade channel as demand from developed countries falls. During the 2008/09 global financial crisis, economic growth in the region collapsed as demand for Asian exports contracted due to weak global growth. This was exacerbated by the collapse of trade financing from tight global liquidity. As a consequence, economies with closer trade ties with the US and eurozone

were the most severely affected. Singapore, Hong Kong, China, Malaysia, and Thailand recorded larger declines in gross domestic product (GDP) growth in 2008 and 2009. In contrast, more domestic demand-oriented economies—the PRC, Indonesia, and India—remained resilient and had only minimal output contractions. This would likely repeat should the global economy slump in 2012.

Nonetheless, the trade impact would probably be less today compared with 2008/09, as Asia's export markets have diversified. For instance, the regions exports to the eurozone and US have declined from 33.8% of total exports in1999 to 24.5% in 2010. The contribution of domestic and regional demand to export growth has also increased. The share of intraregional exports to total exports in emerging East Asia, for example, rose from 36.9% to 44.2% during the same period. The region has also developed stronger trade ties with Latin America and Africa.

## II. Policy Challenges

As explained above, even in the extreme scenario where eurozone and United States (US) gross domestic product (GDP) fall to 2009 levels, the short-term impact on Asia would likely be muted compared with the 2008/09'Great Recession. Asia should be able to whether another crisis if the region's policymakers respond quickly, properly, and firmly by deploying financial, monetary, and fiscal policies to boost liquidity, restore confidence, ensure financial stability, and support growth.

To maintain long-term, sustainable, and increasingly inclusive growth, policymakers must avoid knee-jerk reactions that paper over structural issues. Regardless of whether a global crisis occurs, emerging Asia, however diverse, must stick to its tradition of medium-term national development plans and perspectives. It has the opportunity to focus on a structural transformation that can bolster macroeconomic and financial stability while boosting human capital, supporting needed capital investment, and addressing environmental risks. All this will require active governments, committed to good governance and pursuing regional or global cooperation in addressing common challenges.

### Safeguarding Growth in a Crisis

**Asia's most immediate challenge would be to contain risks emanating from financial channels should the eurozone plummet into a full-blown financial and economic crisis.** The most important of these are relieving pressure on foreign currency liquidity, managing large and destabilizing capital flows, and minimizing the risk of contagion. Asia must also prepare for a possible slowdown in domestic demand.

**Financial policy must buttress the foundations of financial stability and avoid deterioration in market confidence.** The region's policymakers will need to ensure adequate and timely provisioning for foreign and domestic liquidity. In emerging East Asia, substantial foreign reserves could cushion the impact of sudden capital outflows. East Asia also has the option of tapping the ChiangMai Initiative Multilateralization (CMIM), a reserve pool for emergency liquidity, which may double in size this year. Nonetheless, bilateral swap lines may prove the first line of liquidity insurance. Central banks have been active and several new lines have been arranged. In parallel, work is underway to design crisis prevention mechanisms. In this regard, to complement the International Monetary Fund's (IMF) *ex ante* financing mechanisms, the ASEAN+3 could explore the possibility of developing similar *ante* liquidity support facilities. In fact, ASEAN+3 finance ministers confirmed the desirability of pursuing this option at their 2011 Ha No meeting. For the option to be effective, several issues need to be examined: financing mechanisms for such a facility; conditions under which it would be triggered; stipulations over the amount of funding available to member countries, and; the nature of IMF cooperation.

**Monetary policy must remain flexible to respond to extreme exchange rate volatility.** Where excess volatility and overshooting undermine currency markets and severely disrupt

economic activity, there may be merit in foreign exchange market intervention and temporary capital controls. However, policy makers should be mindful that these measures are likely to force a more disruptive adjustment down the road, and should therefore only been seen as short-term remedies.

**Investment in financial instruments should not overshadow real investment.** In the short term, myriad problems with real investment—mostly investment climate related—has led to over-investment of Asia's savings into financial assets. The margin at which tighter credit (or more lax credit) affects investment must be the level of small- and medium-sized enterprises, as dominant corporations hold sufficient cash to avoid serious impact from tightening credit. This needs to be considered from a monetary standpoint.

**To restore the balance of investments, a financial tax may be appropriate on a case by case or country by country basis.** This would improve allocate efficiency in a second best world where incentives to invest in the real sector cannot be targeted directly, and raise additional revenue for fiscal targeting.

**Authorities need to be ready to use fiscal stimulus more effectively in supporting domestic demand.** If spillovers from the Eurozone and US hit East Asia once more, several economies should hold sufficient fiscal and external positions—though not as much as in 2008/09—to reintroduce stimulus to support growth. At the same time, authorities should carefully design targeted fiscal support to cushion the purchasing power of the most vulnerable from the immediate effects of a potential global downturn. Several countries have faced persistent food inflation, affecting the poor in particular. Central banks may want to pay greater attention to a consumer price index (CPI) subset— say, a "CPI for the Poor"—to keep the impact of macro policies on the poor in the forefront of policy makers' minds. Too much divergence could acts an early warning system against potential social or political tension. Safety net mechanisms will need to be strengthened, with targeted support where feasible.

****************************

Source: Document from Asian Development Bank 2012.

**បកប្រែក្រៅផ្លូវការ**

# ផលប៉ះពាល់នៃវិបត្តិបំណុលនៃតំបន់អឺរ៉ូមកលើអាស៊ី

## I. សេចក្តីផ្តើម

វិបត្តិបំណុលសាធារណៈអឺរ៉ុប អាចមានឥទ្ធិពលអាក្រក់មកលើប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ។ ទាំងសហរដ្ឋអាមេរិក និងតំបន់អឺរ៉ូ គឺជាទីផ្សារនាំចេញដ៏សំខាន់ និងជាប្រភពដើមទុនហិរញ្ញវត្ថុ និងការវិនិយោគផលបត្រ។ បទពិសោធន៍នៃការធ្លាក់ចុះយ៉ាងគំហុកកាលពីឆ្នាំ២០០៨/០៩ កន្លងទៅថ្មីៗនេះ បានធ្វើឲ្យវិស័យហិរញ្ញវត្ថុនិងទីផ្សារទុនក្នុងតំបន់បង្វែរទិសដៅវិនិយោគិនបរទេសទៅកាន់កន្លែងដែលមានស្ថិរភាព ។ ប្រទេសនៅអាស៊ីជាច្រើនបានរងនូវការធ្លាក់ចុះយ៉ាងខ្លាំងលើផ្នែកផលិតកម្មនិងពាណិជ្ជកម្ម ទោះជាយ៉ាងណាក៏ដោយសេដ្ឋកិច្ចតំបន់នេះនៅតែអាចងើបឡើងវិញយ៉ាងឆាប់រហ័ស ដោយសារការដាក់ចុះនយោបាយរូបិយវត្ថុនិងសារពើពន្ធទាន់ពេលវេលានិងមានប្រសិទ្ធភាព ប្រព័ន្ធហិរញ្ញវត្ថុដែលមានស្ថិរភាពល្អប្រសើរនិងបទប្បញ្ញត្តិប្រុងប្រយ័ត្នតឹងរ៉ឹង ។

កន្លងមក វិបត្តិបំណុលតំបន់អឺរ៉ូមានឥទ្ធិពលតិចតួចប៉ុណ្ណោះមកលើកំណើនសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ខណៈដែលសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់មានកម្រិតល្អបង្គួរ និងមានកំណើនរឹងមាំ ។ ប្រព័ន្ធហិរញ្ញវត្ថុបានទទួលផលប៉ះពាល់បន្តិចបន្តួចពីការផ្លាស់ប្តូររបស់ទីផ្សារហិរញ្ញវត្ថុសកល និងបានបន្តផ្តល់មូលនិធិគាំទ្រសកម្មភាពសេដ្ឋកិច្ច ។ ភាពរឹងមាំនៃសេដ្ឋកិច្ចគឺបណ្តាលមកពីដំណើរការជាបន្តបន្ទាប់នៃការធ្វើឲ្យមានតុល្យភាពឡើងវិញនូវប្រភពកំណើនសេដ្ឋកិច្ចពីតម្រូវការក្រៅប្រទេសមកតម្រូវការក្នុងស្រុកវិញ។ បច្ចុប្បន្នពុំទាន់មានប្រទេសសេដ្ឋកិច្ចធំឬមធ្យមមានកំណើនសេដ្ឋកិច្ចធ្លាក់ចុះធ្ងន់ធ្ងរនៅឡើយទេ ។

ទោះជាយ៉ាងណា ប្រសិនបើស្ថានភាពនៅតំបន់អឺរ៉ូកាន់តែធ្ងន់ធ្ងរ អាចជះឥទ្ធិពលអាក្រក់មកលើតំបន់អាស៊ី ហើយវិបត្តិនឹងកាន់តែអូសបន្លាយរយៈពេលយូរ ។ ដោយសារការផ្តល់ចំណាត់ថ្នាក់បំណុលរដ្ឋកំពុងស្ថិតក្រោមការពិនិត្យយ៉ាងល្អិតល្អន់ការស្តារឡើងវិញនូវគ្រឹះស្ថានហិរញ្ញវត្ថុដែលមានបញ្ហាក៏នៅមានកម្រិតដែរ។ ការណ៍នេះ អាចធ្វើឲ្យការដោះស្រាយបញ្ហាវិបត្តិថ្មីនឹងកាន់តែលំបាក ។

នៅក្នុងតំបន់អាស៊ី កិច្ចការជាអាទិភាពរួមគ្នាមួយគឺការរក្សាឲ្យបានចីរភាពកំណើននិងបង្កើនសុខុមាលភាពប្រជាជន ។ ចំពោះអាស៊ីខាងកើតនិងអាស៊ីអាគ្នេយ៍ ការផ្តោតចិត្តទុកដាក់សំខាន់គឺសមាហរណកម្មពាណិជ្ជកម្មនិងហិរញ្ញវត្ថុ។ សម្រាប់អាស៊ីខាងត្បូង ការបង្កើនផលិតភាពនិងការឈានទៅរកផលិតកម្មនិងសេវាកម្មដែលមានតម្លៃខ្ពស់ជាងមុន នឹងក្លាយជាបញ្ហាប្រឈមដ៏សំខាន់ ខណៈដែលឱកាសការងារមិនត្រូវបានធានាគ្រប់គ្រាន់ ។ នៅអាស៊ីកណ្តាលនិងអាស៊ីខាងលិច កិច្ចការជាអាទិភាពរួមគឺការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការដោះស្រាយឲ្យបាននូវកត្តាភូមិសាស្រ្តតាមរយៈការភ្ជាប់ទំនាក់ទំនងឲ្យបានខ្លាំងនិងល្អជាងមុន ។

ប្រព័ន្ធហិរញ្ញវត្ថុក្នុងតំបន់អាស៊ីភាគច្រើនបង្ហាញពីភាពងាយរងគ្រោះតិចតួច ហើយអាចទប់ទល់នឹងឥទ្ធិពលពីវិបត្តិនៅតំបន់អឺរ៉ូ (ប្រឈមតិចតួចនឹងឥទ្ធិពលពីការធ្លាក់ចុះថ្លៃប្រាក់អឺរ៉ូយ៉ាងគំហុក ការកើនឡើងអត្រាការប្រាក់កម្ចីជាយ៉េន និងការធ្លាក់ចុះកំណើនសេដ្ឋកិច្ចនៅប្រទេសចិន ជប៉ុន និងផ្នែកខ្លះទៀតនៅអាស៊ី) ។

ទោះបីជាប្រតិបត្តិការហិរញ្ញវត្ថុនៅអាស៊ីមានទំនាក់ទំនងខ្លាំងជាមួយធនាគារតំបន់អឺរ៉ូនិងអាមេរិកក៏ដោយ ភាពផុយស្រួយពីខាងក្រៅចំពោះតំបន់អាស៊ីនេះមានកម្រិតទាបជាងឆ្នាំ២០០៧នៅឡើយទេ។ជាទូទៅសមតុល្យគណនីចរន្តនៅមានភាពល្អប្រសើរ ដោយសារតែសេដ្ឋកិច្ចពឹងផ្អែកតិចតួចទៅលើកម្ចីពីខាងក្រៅ ដូចនេះហើយបានជាមានភាពអវិជ្ជមានតិចតួចពីការរឹតបន្តឹងសាច់ប្រាក់ងាយស្រួល។ សំពាធបំណុលតំបន់អាស៊ីក៏មានភាពធូរស្រាលចាប់តាំងពីឆ្នាំ២០០៨ ដែរ ។ នៅប្រទេសទាំងនេះ ភាគច្រើនទុនបម្រុងអន្តរជាតិមានកម្រិតខ្ពស់ជាងតម្រូវការ និងអាចធានាដល់ការនាំចូលនិងការទូទាត់បំណុលក្រៅប្រទេសរយៈពេលខ្លីបាន ។ ប្រព័ន្ធធនាគារក្នុងតំបន់នៅតែមានភាពរឹងមាំ ជាមួយនឹងអនុបាតភាពគ្រប់គ្រាន់នៃដើមទុនមានកម្រិតខ្ពស់ ហើយយ៉ាងហោចណាស់ក្នុងពេលបច្ចុប្បន្នឥណទានមិនដំណើរការមានកម្រិតទាបនៅឡើយ ។ ក្នុងអំឡុងវិបត្តិសេដ្ឋកិច្ចសកលប្រព័ន្ធធនាគារក្នុងតំបន់អាស៊ីនៅតែពុំបានរងគ្រោះធ្ងន់ធ្ងរ ហើយភាពរឹងមាំនេះនៅតែបន្ត។

**១. ឥទ្ធិពលលើវិស័យហិរញ្ញវត្ថុ**

ដោយសារប្រព័ន្ធហិរញ្ញវត្ថុពិភពលោកពាក់ព័ន្ធគ្នាយ៉ាងស្អិតរមួត រាល់បញ្ហាប្រព័ន្ធហិរញ្ញវត្ថុណាមួយកើនឡើងក្នុងតំបន់អឺរ៉ូនឹងមានឥទ្ធិពលមកលើអាស៊ី។ក្នុងទសវត្សរ៍កន្លងមកប្រទេសក្នុងតំបន់បានធ្វើសេរីភាវូបនីយកម្មប្រព័ន្ធហិរញ្ញវត្ថុ ។ ទន្ទឹមនឹងអត្ថប្រយោជន៍ជាច្រើនចំពោះសេដ្ឋកិច្ច ការធ្វើសេរីភាវូបនីយកម្មនេះក៏បានធ្វើឲ្យតំបន់អាស៊ីកាន់តែងាយរងគ្រោះ ដោយផលប៉ះពាល់ពីខាងក្រៅនិងសមាហរណកម្មរវាងទីផ្សារហិរញ្ញវត្ថុសកល ។ បញ្ហានេះ ស្តែងចេញយ៉ាងច្បាស់ក្នុងអំឡុងវិបត្តិឆ្នាំ២០០៨-២០០៩ នៅពេលដែលប្រទេសសិង្ហបុរីហុងកុងនិងចិនដែលជាមជ្ឈមណ្ឌលហិរញ្ញវត្ថុក្នុងតំបន់ជួបនឹងការធ្លាក់ចុះខ្លាំងក្នុងការផលិត បើធៀបនឹងរយៈពេលកន្លងមក ។ ផ្ទុយទៅវិញ ប្រទេសដែលមានទ្រព្យសកម្មហិរញ្ញវត្ថុអន្តរជាតិតិចតួចក៏បានជួបប្រទះការធ្លាក់ចុះតិចតួចផងដែរ ។

បរាជ័យក្នុងការដោះស្រាយវិបត្តិក្នុងតំបន់អឺរ៉ូអាចនឹងបង្កើនល្បឿនលំហូរមូលធនចេញដូចគ្នាទៅនឹងឆ្នាំ២០០៨ ក្រោយពីធនាគារ Lehman Brother ដួលរលំ មូលធនក៏បានហូរចេញដោយសារតែការព្រួយបារម្ភចំពោះហានិភ័យនិងភាពមិនប្រាកដប្រជាទៅលើអ្នកកាន់កាប់ទ្រព្យសកម្មអចលនទ្រព្យដែលមានបញ្ហា។លំហូរចេញនៃមូលធនភាគច្រើនកើតចេញពីឥណទានរបស់ធនាគារនិងការវិនិយោគផលប័ត្រ ខណៈដែលការវិនិយោគផ្ទាល់ពីបរទេសហាក់ដូចជាមានស្ថិរភាពនៅឡើយ ។ នេះបង្ហាញថា ក្នុងពេលដែលវិបត្តិតំបន់អឺរ៉ូកាន់តែធ្ងន់ធ្ងរបណ្តាញចម្លងទៅកាន់តំបន់អាស៊ីប្រហែលជាអាចឆ្លងតាមរយៈការធ្លាក់ចុះនៃការផ្តល់ឥណទានរបស់ធនាគារនិងការវិនិយោគផលប័ត្រ ។

ភាពរឹតត្បិតនៃស្ថានភាពឥណទានសកលអាចនឹងត្រលប់មកវិញ ប្រសិនបើវិបត្តិក្នុងតំបន់អឺរ៉ូកាន់តែធ្ងន់ធ្ងរដែលបណ្តាលឲ្យមានឥទ្ធិពលទៅលើសន្ទនីយភាពរបស់ប្រព័ន្ធធនាគារក្នុងតំបន់។ ជានយោបាយ ធនាគារនៅតំបន់អឺរ៉ូងាយស្រួលកាត់បន្ថយឥណទាននៅក្រៅប្រទេសជាងឥណទានក្នុងស្រុក។ ដូច្នេះ ការផ្តល់ឥណទានមកកាន់តំបន់អាស៊ីអាចនឹងធ្លាក់ចុះ ។ ធនាគារអាមេរិក និងចក្រភពអង់គ្លេស ដែលមានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយធនាគារក្នុងតំបន់អឺរ៉ូ អាចនឹងទទួលរងផលប៉ះពាល់ផងដែរ។

វិបត្តិក្នុងតំបន់អឺរ៉ូកាន់តែធ្ងន់ធ្ងរនិងអូសបន្លាយអាចនឹងបណ្តាលឲ្យមានការព្រួយបារម្ភខ្លាំងចំពោះហានិភ័យសកលនិងរុញច្រានអ្នកវិនិយោគផលប័ត្រចេញពីតំបន់អឺរ៉ូទៀតផង។ សន្ទស្សន៍ទីផ្សារហ៊ុននៃប្រទេសក្នុងតំបន់នោះជាច្រើនអាចនឹងធ្លាក់ចុះយ៉ាងខ្លាំងជាថ្មីម្តងទៀត ដែលនឹងកាត់បន្ថយទំនុក ចិត្តរបស់អ្នកវិនិយោគព្រមទាំងប៉ះពាល់ដល់ការប្រើប្រាស់ តាមរយៈផលប៉ះពាល់ទ្រព្យសម្បត្តិ (The wealth effect) ។ ការណ៍នេះក៏អាចបង្កើនការចំណាយលើការបង្កើនដើមទុន ដូចនេះ ធ្វើឲ្យការវិនិយោគធ្លាក់ចុះ ហើយក៏អាចធ្វើឲ្យដើមទុនក្នុងទីផ្សារហិរញ្ញវត្ថុក្នុងស្រុកកាន់តែមានបញ្ហាប្រឈម ។ ចលនារួមគ្នារវាងទីផ្សារហ៊ុនក្នុងតំបន់និងទីផ្សារហិរញ្ញវត្ថុពិភពលោកចម្បងៗនឹងកើនឡើង ។ ចាប់តាំងពីមានវិបត្តិបំណុលសាធារណៈនៅតំបន់អឺរ៉ូមក ទីផ្សារហ៊ុននៅតំបន់នេះនិងនៅតំបន់អាស៊ីកំពុងឈានទៅរកស្ថានភាពដែលមិនអាចគ្រប់គ្រងបាន ។ ក្រៅពីផលប៉ះពាល់លើទីផ្សារហ៊ុន ទីផ្សារសញ្ញាប័ណ្ណក៏ទទួលរងឥទ្ធិពលពីវិបត្តិនេះផងដែរ។ ជានិច្ចជាកាលវិបត្តិតែងតែធ្វើឲ្យទិន្នផលដែលទទួលបានពីការវិនិយោគលើសញ្ញាប័ណ្ណក្នុងតំបន់កើនឡើងដោយសារវិនិយោគិនបរទេសងាកទៅវិនិយោគលើទ្រព្យសកម្មដែលមានសុវត្ថិភាពជាង។ ការណ៍នេះនឹងធ្វើឲ្យក្រុមហ៊ុនមានភាពលំបាកនិងចំណាយខ្ពស់ក្នុងការប្រមូលទុននៅក្នុងទីផ្សារសញ្ញាប័ណ្ណ ហើយក្រុមហ៊ុនទាំងនោះអាចប្រឈមនឹងវិបត្តិសន្ទនីយភាព ប្រសិនបើការស្វែងរកហិរញ្ញប្បទានរួមមានហិរញ្ញប្បទានពាណិជ្ជកម្មមានការលំបាក ។ ប្រទេសដែលកាន់កាប់សញ្ញាប័ណ្ណបរទេសច្រើនអាចនឹងត្រូវទទួលរងឥទ្ធិពលពីវិបត្តិដោយមូលធនហូរចេញខ្លាំង។ ក្នុងចំណោមសេដ្ឋកិច្ចនៅក្នុងតំបន់ ប្រទេសម៉ាឡេស៊ីនិងឥណ្ឌូនេស៊ីបានកាន់កាប់សញ្ញាប័ណ្ណរដ្ឋាភិបាលបរទេសច្រើនជាងគេ។ ជារួមឥទ្ធិពលនៃវិបត្តិនៅតំបន់អឺរ៉ូទៅលើសេដ្ឋកិច្ចអាស៊ី ដែលកំពុងងើបឡើងតាមរយៈវិស័យហិរញ្ញវត្ថុមានលក្ខណៈគួរឲ្យកត់សម្គាល់ ។

**២. ឥទ្ធិពលទៅលើសេដ្ឋកិច្ចពិត**

វិស័យផលិតកម្មគប្បីត្រូវបានការពារពីឥទ្ធិពលនៃការរីករាលដាលវិបត្តិនៅក្នុងទីផ្សារហិរញ្ញវត្ថុ ប្រសិនបើវិបត្តិនេះកាន់តែធ្ងន់ធ្ងរឡើង ។ ការធ្លាក់ចុះ ៤ ដងនៃសេដ្ឋកិច្ចនៅតំបន់អឺរ៉ូ និងសហរដ្ឋអាមេរិក បង្ហាញឲ្យឃើញពីការកើនឡើងនៃឥទ្ធិពលវិបត្តិខាងក្រៅទៅលើតំបន់អាស៊ី។ តាមការប៉ាន់ស្មានសេដ្ឋកិច្ចដែលទើបតែលូតលាស់ខាងឧស្សាហកម្មនិងពឹងផ្អែកកាន់តែខ្លាំងទៅលើការនាំចេញ កាន់តែទទួលរងឥទ្ធិពលពីវិបត្តិជាងសេដ្ឋកិច្ចប្រទេសអាស៊ានដែលមានចំណូលមធ្យម ។ ជាងនេះទៅទៀត សេដ្ឋកិច្ចរបស់ប្រទេសចិនកាន់តែងាយរងនូវវិបត្តិនៃការធ្លាក់ចុះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ នៅពេលដែលកំណើននៃការនាំចេញរបស់ប្រទេសចិនកាន់តែខ្ពស់។ វិបត្តិបំណុលសាធារណៈនៅតំបន់អឺរ៉ូ ដែលមានរយៈពេលយូរនឹងកាន់តែធ្ងន់ធ្ងរនឹងមានផលប៉ះពាល់ទៅលើសេដ្ឋកិច្ចក្នុងតំបន់អាស៊ីតាមរយៈពាណិជ្ជកម្ម ដោយសារការធ្លាក់ចុះនៃតម្រូវការពី បណ្តាប្រទេសអភិវឌ្ឍន៍ ។ ក្នុងអំឡុងពេលវិបត្តិហិរញ្ញវត្ថុសកលនាឆ្នាំ២០០៨/២០០៩ កំណើនសេដ្ឋកិច្ចនៅក្នុងតំបន់បានធ្លាក់ចុះ ខណៈដែលតម្រូវការនាំចេញពីអាស៊ីថយចុះដោយសារតែកំណើនពិភពលោកទន់ខ្សោយ ។ ស្ថានភាពនេះកាន់តែអាក្រក់ឡើងដោយសារតែការធ្លាក់ចុះនៃហិរញ្ញប្បទានពាណិជ្ជកម្ម ដែលបណ្តាលមកពីកង្វះខាតសន្ទនីយភាពសកល ។ ជាលទ្ធផល សេដ្ឋកិច្ចដែលមានទំនាក់ទំនងពាណិជ្ជកម្មស្អិតរមួតជាមួយនឹងសហរដ្ឋអាមេរិកនិងតំបន់អឺរ៉ូទទួលរងឥទ្ធិពលយ៉ាងធ្ងន់ធ្ងរ ។

ផ.ស.ស. របស់ប្រទេសសិង្ហបុរី ហុងកុង ចិន ម៉ាឡេស៊ី និងថៃ បានថយចុះនៅក្នុងឆ្នាំ២០០៨ និង ២០០៩។ ផ្ទុយមកវិញ សេដ្ឋកិច្ចដែលពឹងផ្អែកលើតម្រូវការក្នុងស្រុក ដូចជា ប្រទេសចិន ឥណ្ឌូនេស៊ី និង ឥណ្ឌា នៅតែមានភាពរឹងមាំ ហើយផលិតផលមានការធ្លាក់ចុះតិចតួចបំផុត ។ ការណ៍នេះនឹងកើតឡើងម្តងទៀត ប្រសិនបើសេដ្ឋកិច្ចពិភពលោកធ្លាក់ចុះខ្លាំងក្នុងឆ្នាំ២០១២។ ទោះបីជាយ៉ាងណាក៏ដោយ ផលប៉ះពាល់លើវិស័យពាណិជ្ជកម្មនាពេលបច្ចុប្បន្នគឺមានតិចតួចធៀបនឹងឆ្នាំ២០០៨/២០០៩ ដោយសារតែទីផ្សារនាំចេញរបស់អាស៊ីមានមូលដ្ឋានរឹងមាំ។ ជាក់ស្តែង ការនាំចេញទៅតំបន់អឺរ៉ុបនិងអាមេរិកបានធ្លាក់ចុះពី ៣៣,៨% នៃការនាំចេញសរុបក្នុងឆ្នាំ១៩៩៩ទៅ២៤,៥%នៅក្នុងឆ្នាំ២០១០។ ការចូលរួមនៃតម្រូវការក្នុងស្រុកនិងតំបន់ ចំពោះកំណើននៃការនាំចេញក៏មានការកើនឡើងផងដែរ ។ ចំណែកឯ ការនាំចេញរវាងប្រទេសក្នុងតំបន់ ដូចជានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍អាស៊ីបូព៌ាបានកើនឡើងពី ៣៦,៩%ទៅ៤៤,២% ក្នុងអំឡុងពេលដូចគ្នា។ ទន្ទឹមនេះ តំបន់អាស៊ីក៏បានរីតចំណងពាណិជ្ជកម្មកាន់តែរឹងមាំជាមួយនឹងអាមេរិកឡាទីន និងអាហ្វ្រិក ។

## II. បញ្ហាប្រឈមគោលនយោបាយ ៖

ទោះបី ផ.ស.ស. របស់ប្រទេសក្នុងតំបន់អឺរ៉ូនិងសហរដ្ឋអាមេរិកធ្លាក់ចុះដល់កម្រិត កាលពីឆ្នាំ២០០៩ក៏ដោយក៏ឥទ្ធិពលរយៈពេលខ្លីទៅលើតំបន់អាស៊ីនៅមិនទាន់មានភាពធ្ងន់ធ្ងរដូចវិបត្តិសេដ្ឋកិច្ចកាលពីឆ្នាំ២០០៨/២០០៩នោះទេ ។ អាស៊ីគួរតែអាចដោះស្រាយបានដោយជោគជ័យនូវវិបត្តិផ្សេងទៀត ប្រសិនបើអ្នកសម្រេចចិត្តផ្នែកគោលនយោបាយនៅក្នុងតំបន់អាចឆ្លើយតបបានទាន់ពេលវេលា ដោយប្រើប្រាស់គោលនយោបាយសារពើពន្ធ រូបិយវត្ថុនិងហិរញ្ញវត្ថុ ដើម្បីបង្កើនសន្ទនីយភាព ស្តារជំនឿទុកចិត្ត ធានាឲ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ និងជំរុញកំណើនសេដ្ឋកិច្ច ។ ដើម្បីរក្សាកំណើនរយៈពេលវែងប្រកបដោយចីរភាព អ្នកសម្រេចចិត្តផ្នែកគោលនយោបាយត្រូវតែជៀសវាងការឆ្លើយតបទាំងឡាយណាដែលមិនបានពិចារណាឲ្យច្បាស់ជាមុននិងការបិទបាំងចំពោះបញ្ហាដែលកើតឡើងដោយគោលនយោបាយ។ ទោះបីជាវិបត្តិសកលកើតឡើងឬមិនកើតឡើងក៏ដោយក៏ប្រទេសកំពុងងើបឡើងវិញនៅក្នុងតំបន់អាស៊ីត្រូវតែប្រកាន់ខ្ជាប់នូវទស្សនៈនិងគម្រោងអភិវឌ្ឍន៍ថ្នាក់ជាតិរយៈពេលមធ្យមរបស់ខ្លួនដែរ។ ប្រទេសទាំងនេះមានឱកាសផ្តោតទៅលើកំណែទម្រង់រចនាសម្ព័ន្ធ ដែលអាចគាំទ្រស្ថិរភាពហិរញ្ញវត្ថុនិងម៉ាក្រូសេដ្ឋកិច្ចបង្កើនធនធានមនុស្ស និងវិនិយោគមូលធនចាំបាច់និងកាត់បន្ថយហានិភ័យនានា។ ទាំងនេះ តម្រូវឲ្យរដ្ឋាភិបាលសកម្មក្នុងការរក្សាឲ្យបាននូវអភិបាលកិច្ចល្អ និងបន្តរក្សាកិច្ចសហប្រតិបត្តិការសកល និងក្នុងតំបន់ដើម្បីដោះស្រាយបញ្ហាប្រឈមរួម ។

### ១-ការពារកំណើននៅក្នុងស្ថានភាពវិបត្តិ

បញ្ហាប្រឈមចាំបាច់បំផុតសម្រាប់អាស៊ីនាពេលបច្ចុប្បន្ន គឺការគ្រប់គ្រងហានិភ័យដែលកើតចេញពីវិស័យហិរញ្ញវត្ថុ ប្រសិនបើតំបន់អឺរ៉ូធ្លាក់ទៅក្នុងវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពេញលេញ។ អ្វីដែលសំខាន់បំផុតគឺការកាត់បន្ថយសំពាធទៅលើសន្ទនីយភាពរូបិយប័ណ្ណ គ្រប់គ្រងលំហូរមូលធននិងកាត់បន្ថយការរីករាលដាលនៃហានិភ័យ ។ មិនត្រឹមតែប៉ុណ្ណោះ អាស៊ីក៏ត្រូវតែរៀបចំខ្លួនចំពោះការថយចុះនៃតម្រូវការក្នុងស្រុកដែលអាចកើតមានឡើងផងដែរ ។

នយោបាយហិរញ្ញវត្ថុត្រូវធ្វើឡើងដើម្បីគាំទ្រមូលដ្ឋានគ្រឹះនៃស្ថិរភាពហិរញ្ញវត្ថុ និងជៀសវាងការបំផ្លាញជំនឿទុកចិត្តលើទីផ្សារ ។ អ្នកសម្រេចចិត្តផ្នែកគោលនយោបាយនៅក្នុងតំបន់ចាំបាច់ត្រូវធានានូវការផ្តល់សន្ទនីយភាពជារូបិយវត្ថុនិងរូបិយប័ណ្ណឲ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ។ នៅក្នុងប្រទេសកំពុងងើបឡើងវិញ

នៅអាស៊ីបូព៌ា ភាពគ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិអាចជួយកាត់បន្ថយឥទ្ធិពលនៃលំហូរទុនចេញភ្លាមៗ។អាស៊ីបូព៌ាក៏មានជម្រើសក្នុងការប្រើប្រាស់កិច្ចសន្យាឥណទានពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ដែលជាទុនបម្រុងរួមគ្នាសម្រាប់ប្រើប្រាស់ពេលសន្ទនីយភាពមានអាសន្នហើយទំហំមូលនិធិនេះកើនឡើងទ្វេដងក្នុងឆ្នាំនេះ។ ឥណទានស្វប់(Swap)ទ្វេភាគីនេះគឺជាការធានាទីមួយនៅពេលមានកង្វះខាតសន្ទនីយភាព។ធនាគារកណ្តាលកាន់តែមានភាពសកម្មហើយបន្ទាត់ឥណទានផ្សេងៗទៀតជាច្រើននិងយន្តការការពារវិបត្តិត្រូវបានរៀបចំឡើងផងដែរ ។ ក្នុងករណីនេះ ដើម្បីបំពេញបន្ថែមទៅលើយន្តការហិរញ្ញវត្ថុមុនពេលកើតមានវិបត្តិ (ex ante) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ប្រទេសអាស៊ាន+៣ អាចស្វែងរកលទ្ធភាពថ្មី ដើម្បីទទួលកម្មវិធីគាំទ្រសន្ទនីយភាពជាមុន ។ ជាក់ស្តែង រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន+៣ បានបញ្ជាក់ពីចំណុចក្នុងការសម្រេចឲ្យបាននូវជម្រើសនេះនៅក្នុងកិច្ចប្រជុំហាណូយ (Hanoi) នៅក្នុងឆ្នាំ២០១១ ។ ដើម្បីឲ្យជម្រើសនេះមានប្រសិទ្ធភាព បញ្ហាមួយចំនួនចាំបាច់ត្រូវលើកយកមកពិនិត្យ និងពិភាក្សាដូចជាយន្តការហិរញ្ញវត្ថុសម្រាប់ឧបករណ៍គាំទ្រនេះ ស្ថានភាពដែលអាចបង្កឲ្យមានហានិភ័យ លក្ខខណ្ឌនៃទំហំមូលនិធិដែលប្រទេសជាសមាជិកអាចប្រើប្រាស់បាន និងលក្ខណៈនៃកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌ IMF ។

គោលនយោបាយរូបិយវត្ថុត្រូវតែមានភាពទន់ភ្លន់ ដើម្បីឆ្លើយតបនឹងការប្រែប្រួលខ្លាំងនៃអត្រាប្តូរប្រាក់ ។ នៅពេលមានការប្រែប្រួលខ្លាំងដែលប៉ះពាល់ដល់ទីផ្សាររូបិយវត្ថុ និងជះឥទ្ធិពលខ្លាំងទៅលើសកម្មភាពសេដ្ឋកិច្ចចាំបាច់ទាមទារឲ្យមានអន្តរាគមន៍ទីផ្សារប្តូរប្រាក់ និងការគ្រប់គ្រងបណ្តោះអាសន្នទៅលើលំហូរមូលធន ។ យ៉ាងណាមិញអ្នកសម្រេចចិត្តផ្នែកគោលនយោបាយគប្បីចងចាំថា មធ្យោបាយទាំងនេះក៏អាចបង្កឲ្យមានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើង ដូច្នេះគួរតែត្រូវបានប្រើប្រាស់ជាវិធីសាស្ត្ររយៈពេលខ្លីប៉ុណ្ណោះ ។

ការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុ មិនត្រូវធ្វើឡើងដោយចៀសវាងផលប៉ះពាល់ជាអវិជ្ជមានលើការវិនិយោគរូបវន្ត។នៅក្នុងរយៈពេលខ្លីបញ្ហាជាច្រើនពាក់ព័ន្ធនឹងការវិនិយោគជារូបវន្តដែលភាគច្រើនអាស្រ័យលើស្ថានភាពវិនិយោគ បានបង្កឲ្យមានការវិនិយោគលើសលប់នៃប្រាក់សន្សំនៅតំបន់អាស៊ីទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ។ ការរឹតបន្តឹងការផ្តល់ឥណទាន (ឬភាពធូររលុងនៃការផ្តល់ឥណទាន) អាចប៉ះពាល់តែត្រឹមកម្រិតសហគ្រាសខ្នាតតូច និងមធ្យមប៉ុណ្ណោះ ដោយសារតែសាជីវកម្មធំៗមានសាច់ប្រាក់គ្រប់គ្រាន់ក្នុងការជៀសវាងឥទ្ធិពលធ្ងន់ធ្ងរដែលបណ្តាលមកពីការរឹតបន្តឹងឥណទាននេះ ការណ៍នេះគប្បីត្រូវពិចារណាតាមទស្សនៈរូបិយវត្ថុ។

ដើម្បីរក្សាតុល្យភាពក្នុងការវិនិយោគ ការយកពន្ធលើប្រតិបត្តិការហិរញ្ញវត្ថុគួរតែត្រូវអនុវត្តទៅតាមករណីជាក់ស្តែងឬទៅតាមប្រទេសនីមួយៗ។ ការយកពន្ធនេះនឹងបង្កើនប្រសិទ្ធភាពនៃការបែងចែក ហើយមិនប៉ះពាល់ដោយផ្ទាល់ទៅលើការលើកទឹកចិត្តក្នុងការវិនិយោគលើវិស័យរូបវន្តព្រមទាំងជួយបង្កើនប្រាក់ចំណូលបន្ថែមទៀតសម្រាប់គោលដៅសារពើពន្ធ ។

អាជ្ញាធរទាមទារឲ្យត្រៀមខ្លួនរួចជាស្រេច ក្នុងការប្រើប្រាស់នយោបាយសារពើពន្ធឲ្យកាន់តែមានប្រសិទ្ធិភាព ដើម្បីជំរុញតម្រូវការក្នុងស្រុក ។ ប្រសិនបើវិបត្តិនៅតំបន់អឺរ៉ូ និងសហរដ្ឋអាមេរិក ផ្តល់ផលប៉ះពាល់មកលើអាស៊ីបូព៌ាម្តងទៀត សេដ្ឋកិច្ចនៅក្នុងតំបន់នេះគួរតែមានស្ថានភាពសារពើពន្ធ និងជញ្ជីងទូទាត់គ្រប់គ្រាន់ទោះជាមិនមានទំហំច្រើនដូចក្នុងឆ្នាំ២០០៨/២០០៩ក្តី ដើម្បីអនុវត្តនយោបាយជំរុញ និងគាំទ្រកំណើន ។ ស្របពេលជាមួយគ្នានេះដែរ អាជ្ញាធរគួរតែរៀបចំដោយប្រុងប្រយ័ត្ននូវនយោបាយសារពើពន្ធ ដែលគាំទ្រនិងអាចជួយកាត់បន្ថយការធ្លាក់ចុះនៃអំណាចទិញដែលបណ្តាលមកពីឥទ្ធិពលនៃការធ្លាក់ចុះសេដ្ឋកិច្ចសកល ។ ប្រទេស

មួយចំនួនបានជួបប្រទះនឹងបញ្ហាអតិផរណាថ្លៃម្ហូបអាហារយូរអង្វែង ដែលប៉ះពាល់ដល់ប្រជាជនក្រីក្រ។ ធនាគារកណ្តាលគួរយកចិត្តទុកដាក់ឲ្យបានខ្ពស់ទៅលើធាតុនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ដូចជាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ចំពោះប្រជាជនក្រីក្រ ដើម្បីគ្រប់គ្រងជាចម្បងឥទ្ធិពលនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចទៅលើប្រជាជនក្រីក្រ ។ ការកើនឡើងវិសមភាពចំណូលបានដើរតួនាទីជាប្រព័ន្ធផ្តល់ព័ត៌មានជាមុនក្នុងការប្រឆាំងនឹងភាពតានតឹងផ្នែកនយោបាយ ឬ សង្គម ។ យន្តការបណ្តាញសុវត្ថិភាពចាំបាច់ត្រូវពង្រឹងដោយមាននយោបាយគាំទ្រចំគោលដៅ ។

**************************

ប្រភព៖ ដកស្រង់ចេញពីឯកសាររបស់ធនាគារអភិវឌ្ឍអាស៊ី (ADB) ឆ្នាំ២០១២

# តារាង: អត្រាប្តូរប្រាក់ប្រចាំខែ

| ចុងខែ | អត្រាទីផ្សារ | | | | | អត្រាផ្លូវការ | | | | | គម្លាតអត្រាមធ្យម (អត្រាផ្លូវការ-អត្រាទីផ្សារ) | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អត្រាទិញ | អត្រាលក់ | អត្រាមធ្យម | បម្រែបម្រួលប្រចាំខែ +/- | % | អត្រាទិញ | អត្រាលក់ | អត្រាមធ្យម | បម្រែបម្រួលប្រចាំខែ +/- | % | | |
| **2010** | | | | | | | | | | | | |
| Jan-មករា | 4,185 | 4,193 | 4,189 | -4 | -0.09 | 4,167 | 4,175 | 4,171 | -2 | -0.04 | -18 | -0.43 |
| Feb-កុម្ភៈ | 4,194 | 4,201 | 4,198 | -9 | -0.21 | 4,183 | 4,191 | 4,187 | -16 | -0.38 | -11 | -0.25 |
| Mar-មីនា | 4,189 | 4,195 | 4,192 | 5 | 0.11 | 4,182 | 4,190 | 4,186 | 1 | 0.02 | -6 | -0.14 |
| Apr-មេសា | 4,217 | 4,228 | 4,223 | 28 | 1.00 | 4,200 | 4,208 | 4,204 | 18 | 1.00 | -19 | -0.44 |
| May-ឧសភា | 4,248 | 4,259 | 4,254 | 31 | 0.70 | 4,215 | 4,223 | 4,219 | 15 | 0.300 | -35 | -0.81 |
| Jun-មិថុនា | 4,266 | 4,275 | 4,271 | 18 | 0.40 | 4,222 | 4,230 | 4,226 | 7 | 0.10 | -45 | -1.05 |
| Jul-កក្កដា | 4,260 | 4,273 | 4,267 | -6 | -0.20 | 4,237 | 4,245 | 4,241 | 15 | 0.30 | -26 | -0.60 |
| Aug-សីហា | 4,257 | 4,267 | 4,262 | -3 | -0.07 | 4,235 | 4,243 | 4,239 | -2 | -0.05 | -23 | -0.54 |
| Sep-កញ្ញា | 4,245 | 4,253 | 4,249 | -12 | -0..28 | 4,227 | 4,235 | 4,231 | -8 | -0.19 | -18 | -0.42 |
| Oct-តុលា | 4,216 | 4,224 | 4,220 | -29 | -0..68 | 4,222 | 4,230 | 4,226 | -5 | -0.12 | 6 | 0.14 |
| Nov-វិច្ឆិកា | 4,074 | 4,081 | 4,078 | -142 | -3.37 | 4,075 | 4,083 | 4,079 | -147 | -3.49 | -1 | -0.02 |
| Dec-ធ្នូ | 4,048 | 4,053 | 4,051 | -26 | -0.64 | 4,051 | 4,055 | 4,053 | -24 | -0.59 | -2 | -0.05 |
| **2011** | | | | | | | | | | | | |
| Jan-មករា | 4,052 | 4,059 | 4,056 | 4 | 0.10 | 4,050 | 4,054 | 4,052 | -1 | -0.02 | -4 | -0.09 |
| Feb-កុម្ភៈ | 4,034 | 4,038 | 4,036 | -18 | -0.44 | 4,036 | 4,042 | 4,039 | -14 | -0.35 | 3 | 0.07 |
| Mar-មីនា | 4,004 | 4,010 | 4,007 | -30 | -0.74 | 4,007 | 4,013 | 4,010 | -29 | -0.72 | 3 | 0.07 |
| Apr-មេសា | 4,060 | 4,069 | 4,065 | 56 | 1.40 | 4,020 | 4,028 | 4,024 | 13 | 0.32 | -41 | -1.00 |
| May-ឧសភា | 4,094 | 4,103 | 4,099 | 34 | 0.84 | 4,080 | 4,088 | 4,084 | 60 | 1.49 | -15 | -0.35 |
| Jun-មិថុនា | 4,122 | 4,127 | 4,125 | 28 | 0.68 | 4,115 | 4,123 | 4,119 | 35 | 0.86 | -6 | -0.13 |
| Jul-កក្កដា | 4,098 | 4,106 | 4,102 | -24 | -0.58 | 4,100 | 4,108 | 4,104 | -15 | -0.36 | 2 | 0.05 |
| Aug-សីហា | 4,096 | 4,103 | 4,100 | -2 | -0.05 | 4,093 | 4,101 | 4,097 | -7 | -0.17 | -3 | -0.07 |
| Sep-កញ្ញា | 4,084 | 4,098 | 4,091 | -12 | -0.29 | 4,080 | 4,088 | 4,084 | -13 | -0.32 | -7 | -0.17 |
| Oct-តុលា | 4,092 | 4,098 | 4,095 | 8 | 0.19 | 4,100 | 4,108 | 4,104 | 20 | 0.49 | 9 | 0.22 |
| Nov-វិច្ឆិកា | 4,030 | 4,037 | 4,034 | -62 | -1.52 | 4,031 | 4,039 | 4,035 | -69 | -1.68 | 5 | 0.12 |
| Dec-ធ្នូ | 4,057 | 4,066 | 4,062 | 27 | 0.67 | 4,039 | 4,039 | 4,039 | 8 | 8.20 | -23 | -0.57 |
| **2012** | | | | | | | | | | | | |
| Jan-មករា | 4073 | 4082 | 4078 | 16 | 0.39 | 4064 | 4064 | 4064 | 25 | 0.62 | -14 | -0.34 |
| Feb-កុម្ភៈ | 4013 | 4018 | 4016 | -60 | -1.47 | 4015 | 4015 | 4015 | -49 | -1.21 | -2 | -1.20 |
| Mar-មីនា | 3995 | 4005 | 4000 | -18 | -0.45 | 3995 | 3995 | 3995 | -20 | -0.50 | -5 | -0.50 |
| Apr-មេសា | 4042 | 4056 | 4049 | 47 | 1.18 | 4025 | 4025 | 4025 | 30 | 0.75 | -24 | -0.59 |
| May-ឧសភា | 4095 | 4105 | 4100 | 53 | 1.3 | 4065 | 4065 | 4065 | 40 | 1.00 | -35 | -0.85 |
| Jun-មិថុនា | 4100 | 4109 | 4105 | 5 | 0.12 | 4065 | 4065 | 4065 | 0 | 0 | -40 | -1.00 |
| Jul-កក្កដា | 4077 | 4084 | 4081 | -23 | -056 | 4070 | 4070 | 4070 | 5 | 0.12 | -11 | -0.27 |
| Aug-សីហា | 4053 | 4063 | 4058 | -24 | -059 | 4045 | 4045 | 4045 | -25 | -0.61 | -13 | -0.33 |
| Sep-កញ្ញា | 4055 | 4062 | 4059 | 2 | 0.05 | 4043 | 4043 | 4043 | -2 | -0.05 | -16 | -0.39 |
| Oct-តុលា | 4,025 | 4,033 | 4,029 | -30 | -0.74 | 4,030 | 4,030 | 4,030 | -13 | -0.32 | 5 | 0.12 |
| Nov-វិច្ឆិកា | 3,995 | 4,003 | 3,999 | -30 | -0.74 | 3,992 | 3,992 | 3,992 | -38 | -0.94 | -3 | -0.07 |

# តារាង: អត្រាការប្រាក់លើប្រាក់បញ្ញើ (ក្នុងខែតុលា ឆ្នាំ២០១២)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល (%) | | | | | ប្រាក់បញ្ញើជាដុល្លារអាមេរិក (%) | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ(%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | មានកាលកំណត់ | | | | | មានកាលកំណត់ | | | | | មានកាលកំណត់ | | | |
| | | សំចៃ | ១ខែ | ៣ ខែ | ៦ខែ | ១២ ខែ | សំចៃ | ១ខែ | ៣ ខែ | ៦ ខែ | ១២ ខែ | សំចៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារអេស៊ីលីដា | 1.25 | 3.00 | 5.00 | 6.00 | 7.00 | 0.50 | 1.50 | 2.50 | 3.75 | 5.00 | 0.50 | 2.00 | 2.50 | 3.25 | 4.25 |
| 2 | ធនាគារកម្ពុជាសាធារណៈ | 0.50 | | | | | 0.50 | 1.75 | 2.50 | 3.50 | 4.25 | 0.50 | | | | |
| 3 | ធនាគារកាណាឌីយ៉ាចំកាត់ | 2.00 | | 5.00 | 6.00 | 7.00 | 0.75 | 2.00 | 2.50 | 3.50 | 4.75 | 0.25 | 1.00 | 1.50 | 2.00 | 2.50 |
| 4 | ធនាគារអេអ៊ិនហ្សេតយ៉ាល់ | 0.50 | 3.25 | 3.50 | 4.00 | 5.50 | 0.25 | 1.05 | 1.45 | 2.75 | 3.75 | | | | | |
| 5 | ធនាគារពាណិជ្ជកម្មក្រៅប្រទេស | 1.50 | | 4.50 | 5.50 | 6.50 | 0.75 | 1.00 | 2.50 | 3.50 | 4.75 | | | | | |
| 6 | ធនាគារអភិវឌ្ឍន៍ និងវិនិយោគ | 2.00 | 3.55 | 4.60 | 5.55 | 6.50 | 0.50 | 2.50 | 3.00 | 4.50 | 5.50 | | 10.00 | 10.00 | 10.00 | 10.00 |
| 7 | ធនាគារ មេយប៊ែង | | | | | | 0.50 | 1.50 | 2.25 | 3.25 | 4.25 | | | | | |
| 8 | ធនាគារវឌ្ឍនៈ | 0.50 | 1.50 | 2.00 | 3.00 | 3.50 | 0.50 | 1.50 | 2.00 | 3.00 | 3.50 | | | | | |
| 9 | ធនាគារសហពាណិជ្ជ ក.អ | 0.75 | | | | | 1.00 | 2.50 | 3.50 | 4.50 | 5.50 | | | | | |
| 10 | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | 0.75 | | | | | 0.75 | 2.50 | 3.50 | 4.50 | 5.50 | | | | | |
| 11 | ធនាគារពាណិជ្ជ ចំកាត់ | 0.10 | | 1.00 | 1.00 | 1.00 | 0.10 | | 1.00 | 1.00 | 1.00 | 0.10 | | 1.00 | 1.00 | 1.00 |
| 12 | ធនាគារពាណិជ្ជកម្មទី១ | | | | | | 0.40 | 1.00 | 1.20 | 1.40 | 1.80 | | | | | |
| 13 | ធនាគារក្រុងថៃមហាជន | | | | | | 0.10 | | 0.50 | 0.75 | 1.00 | | | | | |
| 14 | ធនាគារកម្ពុជាអាស៊ី ចំកាត់ | | | | | | 2.00 | 2.50 | 3.50 | 4.50 | 5.50 | | | | | |
| 15 | ធនាគារមេគង្គកម្ពុជា | 3.50 | | | | | 2.00 | 2.25 | 2.75 | 3.25 | 3.50 | 2.00 | | | | |
| 16 | ធនាគារសាជីវកម្មសិង្គបុរី | | | | | | 0.50 | | 2.50 | 3.00 | 4.00 | | | | | |
| 17 | ធនាគារ ឥណ្ឌូ សាខាភ្នំពេញ | | | | | | 0.75 | 1.00 | 2.25 | 3.00 | 4.00 | | | | | |
| 18 | ម៉ារ៉ូហាន់ធនាគារជប៉ុន ភី អិល ស៊ី | 3.00 | 1.00 | 2.00 | 3.00 | 4.50 | 3.00 | 1.00 | 2.00 | 3.00 | 4.50 | | | | | |
| 19 | ធនាគារ ប៊ូយ៉ុងខ្មែរ | 1.00 | 3.00 | 4.00 | 5.00 | 6.00 | 0.50 | 1.50 | 2.50 | 3.00 | 3.50 | | | | | |
| 20 | ធនាគារ ស៊ីនហានខ្មែរ | | | | | | 0.25 | 1.25 | 1.25 | 1.50 | 1.75 | | | | | |
| 21 | ធនាគារ គូកមិន កម្ពុជា ភីអិលស៊ី | 0.70 | 1.70 | 2.50 | 3.20 | 3.60 | 0.50 | 1.20 | 2.00 | 2.70 | 3.10 | | | | | |
| 22 | ធនាគារ អ៊ូ អេស ខេ ឥណ្ឌូឆៃណា | 1.50 | 3.50 | 4.00 | 5.00 | 6.00 | 1.50 | 2.25 | 2.75 | 3.50 | 4.75 | | | | | |
| 23 | ធនាគារហុង ឡីប៊ីអេស | | | | | | 1.00 | 2.25 | 2.75 | 3.75 | 4.25 | | | | | |
| 24 | ធនាគារ ភ្នំពេញ ពាណិជ្ជ | | | | | | 1.20 | 2.50 | 4.20 | 5.20 | 6.20 | | | | | |
| 25 | ធនាគារ សាខម | 1.00 | 3.00 | 4.50 | 5.50 | 6.50 | 0.50 | 2.00 | 3.25 | 4.25 | 5.50 | | | | | |
| 26 | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | | | | | | 1.50 | 2.25 | 2.50 | 3.50 | 4.25 | | | | | |
| 27 | ធនាគារអាហ្វ្រីប៊ែង សាខាកម្ពុជា | 1.25 | 3.00 | 4.00 | 4.25 | 5.00 | 1.00 | 2.00 | 3.00 | 3.75 | 4.75 | | | | | |
| 28 | ធនាគារចិន សាខាភ្នំពេញ | 0.13 | 0.13 | 0.13 | 0.13 | 0.13 | 0.50 | 1.25 | 2.25 | 2.75 | 3.25 | 0.13 | 0.25 | 0.38 | 0.38 | 0.50 |
| 29 | ធនាគារអ៊ឹមប៊ី ភីអិលស៊ី | 0.75 | 3.50 | 4.50 | 5.00 | 6.00 | 0.50 | 2.75 | 3.20 | 4.20 | 5.00 | | | | | |
| 30 | ធនាគារអាយស៊ីប៊ីស៊ីចំកាត់ | 0.50 | | | | | 0.50 | 1.25 | 2.25 | 2.75 | 2.75 | | | | | |
| 31 | ធនាគារមេហ្គាអ៊ិនធើណេសិន ណលខមើសលសាខាភ្នំពេញ | 0.25 | | | | | 0.02 | 1.00 | 1.25 | 0.40 | 0.70 | | | | | |
| 32 | ធនាគារអេសហេជប៊ី ភីអិលស៊ី | | 2.55 | 3.50 | 5.00 | 5.50 | | 3.00 | 4.00 | 4.50 | 5.00 | | | | | |
| 33 | ធនាគារខេមខូ លីមីតធីត | | | | | | | | | | | | | | | |
| 34 | ធនាគារអភិវឌ្ឍន៍ជនបទ | 1.50 | 3.00 | 3.50 | 4.50 | 5.50 | 1.00 | 2.50 | 3.00 | 3.75 | 4.50 | | | | | |
| 35 | ធនាគារឯកទេស ភីអេចអេសអឹមអ៊ី | | | | | | | | | | | | | | | |
| 36 | ធនាគារឯកទេស វិនិយោគទីមួយ | | | | | | | | | | | | | | | |
| 37 | ធនាគារឯកទេស អានកូ | | | | | | | | | | | | | | | |
| 38 | ធនាគារឯកទេស បើស | | | | | | | | | | | | | | | |
| 39 | ធនាគារឯកទេស អង្គរ កាពីតាល | | | | | | | | | | | | | | | |
| | មធ្យមភាគ | 1.13 | 2.46 | 3.30 | 4.06 | 4.86 | 0.79 | 1.81 | 2.46 | 3.22 | 3.98 | 0.58 | 3.31 | 3.08 | 3.33 | 3.65 |

# Table: INTEREST RATE ON DEPOSITS ( in October 2012)

| No. | NAME OF BANKS | Deposit in Riel (%) | | | | | Deposit in USD (%) | | | | | Deposit in Other Foreign Currency (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | Saving | Fixed | | | | Saving | Fixed | | | | Saving | Fixed | | | |
| | | | 1M. | 3M. | 6M. | 12M. | | 1M. | 3M. | 6M. | 12M. | | 1M. | 3M. | 6M. | 12M. |
| 1 | ACLEDA Bank | 1.25 | 3.00 | 5.00 | 6.00 | 7.00 | 0.50 | 1.50 | 2.50 | 3.75 | 5.00 | 0.50 | 2.00 | 2.50 | 3.25 | 4.25 |
| 2 | Cambodian Public Bank | 0.50 | | | | | 0.50 | 1.75 | 2.50 | 3.50 | 4.25 | 0.50 | | | | |
| 3 | Canadia Bank Ltd. | 2.00 | | 5.00 | 6.00 | 7.00 | 0.75 | 2.00 | 2.50 | 3.50 | 4.75 | 0.25 | 1.00 | 1.50 | 2.00 | 2.50 |
| 4 | ANZ Royal Cambodia | 0.50 | 3.25 | 3.50 | 4.00 | 5.50 | 0.25 | 1.05 | 1.45 | 2.75 | 3.75 | | | | | |
| 5 | Foreign Trade Bank | 1.50 | | 4.50 | 5.50 | 6.50 | 0.75 | 1.00 | 2.50 | 3.50 | 4.75 | | | | | |
| 6 | Bank for Investment & Development | 2.00 | 3.55 | 4.60 | 5.55 | 6.50 | 0.50 | 2.50 | 3.00 | 4.50 | 5.50 | | 10.00 | 10.00 | 10.00 | 10.00 |
| 7 | May Bank | | | | | | 0.50 | 1.50 | 2.25 | 3.25 | 4.25 | | | | | |
| 8 | Vattanac Bank | 0.50 | 1.50 | 2.00 | 3.00 | 3.50 | 0.50 | 1.50 | 2.00 | 3.00 | 3.50 | | | | | |
| 9 | Union Commercial Bank | 0.75 | | | | | 1.00 | 2.50 | 3.50 | 4.50 | 5.50 | | | | | |
| 10 | Advanced Bank of Asia | 0.75 | | | | | 0.75 | 2.50 | 3.50 | 4.50 | 5.50 | | | | | |
| 11 | CambodianCommercialBank | 0.10 | | 1.00 | 1.00 | 1.00 | 0.10 | | 1.00 | 1.00 | 1.00 | 0.10 | | 1.00 | 1.00 | 1.00 |
| 12 | First Commercial Bank | | | | | | 0.40 | 1.00 | 1.20 | 1.40 | 1.80 | | | | | |
| 13 | Krung Thai Bank Public | | | | | | 0.10 | | 0.50 | 0.75 | 1.00 | | | | | |
| 14 | Cambodia Asia Bank | | | | | | 2.00 | 2.50 | 3.50 | 4.50 | 5.50 | | | | | |
| 15 | Cambodia Mekong Bank | 3.50 | | | | | 2.00 | 2.25 | 2.75 | 3.25 | 3.50 | 2.00 | | | | |
| 16 | Singapore Bank | | | | | | 0.50 | | 2.50 | 3.00 | 4.00 | | | | | |
| 17 | Bank of India | | | | | | 0.75 | 1.00 | 2.25 | 3.00 | 4.00 | | | | | |
| 18 | Maruhan Japan Bank | 3.00 | 1.00 | 2.00 | 3.00 | 4.50 | 3.00 | 1.00 | 2.00 | 3.00 | 4.50 | | | | | |
| 19 | Booyoung Khmer Bank | 1.00 | 3.00 | 4.00 | 5.00 | 6.00 | 0.50 | 1.50 | 2.50 | 3.00 | 3.50 | | | | | |
| 20 | Shinhan Khmer Bank | | 1.25 | 1.25 | 1.50 | 175 | 0.25 | 1.25 | 1.25 | 1.50 | 1.75 | | | | | |
| 21 | KOOKMIN Bank | 0.70 | 1.70 | 2.50 | 3.20 | 3.60 | 0.50 | 1.20 | 2.00 | 2.70 | 3.10 | | | | | |
| 22 | OSK Indochina Bank | 1.50 | 3.50 | 4.00 | 5.00 | 6.00 | 1.50 | 2.25 | 2.75 | 3.50 | 4.75 | | | | | |
| 23 | Hwang DBS | | | | | | 1.00 | 2.25 | 2.75 | 3.75 | 4.25 | | | | | |
| 24 | Phnom Penh | | | | | | 1.20 | 2.50 | 4.20 | 5.20 | 6.20 | | | | | |
| 25 | SACOMBANK | 1.00 | 3.00 | 4.50 | 5.50 | 6.50 | 0.50 | 2.00 | 3.25 | 4.25 | 5.50 | | | | | |
| 26 | CIMB Bank Plc | | | | | | 1.50 | 2.25 | 2.50 | 3.50 | 4.25 | | | | | |
| 27 | AGRI Bank | 1.25 | 3.00 | 4.00 | 4.25 | 5.00 | 1.00 | 2.00 | 3.00 | 3.75 | 4.75 | | | | | |
| 28 | Bank of China | 0.13 | 0.13 | 0.13 | 0.13 | 0.13 | 0.50 | 1.25 | 2.25 | 2.75 | 3.25 | 0.13 | 0.25 | 0.38 | 0.38 | 0.50 |
| 29 | MB Bank Plc. | 0.75 | 3.50 | 4.50 | 5.00 | 6.00 | 0.50 | 2.75 | 3.20 | 4.20 | 5.00 | | | | | |
| 30 | ICBC Limited | 0.50 | | | | | 0.50 | 1.25 | 2.25 | 2.75 | 2.75 | | | | | |
| 31 | MEGA International | 0.25 | | | | | 0.02 | 1.00 | 1.25 | 0.40 | 0.70 | | | | | |
| 32 | SHB Plc. | | 2.55 | 3.50 | 5.00 | 5.50 | | 3.00 | 4.00 | 4.50 | 5.00 | | | | | |
| 33 | Camko Bank Limited. | | | | | | | | | | | | | | | |
| 34 | Rural Development Bank | 1.50 | 3.00 | 3.50 | 4.50 | 5.50 | 1.00 | 2.50 | 3.00 | 3.75 | 4.50 | | | | | |
| 35 | PHSME Specialized Bank | | | | | | | | | | | | | | | |
| 36 | First Investment | | | | | | | | | | | | | | | |
| 37 | ANCO Specialized Bank | | | | | | | | | | | | | | | |
| 38 | Tomato Specialized Bank | | | | | | | | | | | | | | | |
| 39 | Angkor Capital | | | | | | | | | | | | | | | |
| | Average | 1.13 | 2.46 | 3.30 | 4.06 | 4.86 | 0.79 | 1.81 | 2.46 | 3.22 | 3.98 | 0.58 | 3.31 | 3.08 | 3.33 | 3.65 |

# តារាង: អត្រាការប្រាក់លើប្រាក់កម្ចី (ខែតុលា ឆ្នាំ២០១២)

| ល.រ | ឈ្មោះធនាគារ | ខ្ចីជារៀល (%) | | | | ខ្ចីជាដុល្លារអាមេរិក (%) | | | | ខ្ចីជារូបិយប័ណ្ណផ្សេងៗ (%) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ ខែ | ៣ ខែ | ៦ ខែ | ១២ខែ | ១ ខែ | ៣ ខែ | ៦ ខែ | ១២ខែ | ១ ខែ | ៣ខែ | ៦ ខែ | ១២ខែ |
| 1 | ធនាគារអេស៊ីលីដា | 10.00 | 10.00 | 10.00 | 10.50 | 10.00 | 10.00 | 10.00 | 10.50 | 10.00 | 10.00 | 10.00 | 10.50 |
| 2 | ធនាគារកម្ពុជាសាធារណៈ | | | | | 12.00 | 12.00 | 12.00 | 12.00 | | | | |
| 3 | ធនាគារកាណាឌីយ៉ា ចំកាត់ | | | | | | | | 13.20 | | | | |
| 4 | ធនាគារអេអ៊ិនហ្សេតរូយ៉ាល់ | | | | | | | | 8.12 | | | | |
| 5 | ធនាគារពាណិជ្ជកម្មក្រៅប្រទេស | 18.00 | 18.00 | 18.00 | 18.00 | 18.00 | 18.00 | 18.00 | 18.00 | | | | |
| 6 | ធនាគារអភិវឌ្ឍន៍ និងវិនិយោគ | | | | | | | | 10.00 | | | | |
| 7 | ធនាគារ មេយប៊ែង | | | | | | | | 11.00 | | | | |
| 8 | ធនាគារវឌ្ឍនៈ | | | | | 8.25 | 8.19 | 8.64 | 10.34 | | | | |
| 9 | ធនាគារសហពាណិជ្ជ ក.អ | | | | | | 15.00 | 15.00 | 15.00 | | | | |
| 10 | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | | | | | 14.00 | 15.00 | 16.00 | 18.00 | | | | |
| 11 | ធនាគារពាណិជ្ជ ចំកាត់ | | | | | | 7.64 | 7.64 | 7.64 | | 7.64 | 7.64 | 7.64 |
| 12 | ធនាគារពាណិជ្ជកម្មទី១ | | | | | 12.00 | 12.00 | 12.00 | 12.00 | | | | |
| 13 | ធនាគារក្រុងថៃមហាជន ចំកាត់ | | | | | | | | 13.00 | | | | 10.00 |
| 14 | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | | | | | | | | 12.00 | | | | |
| 15 | ធនាគារមេគង្គកម្ពុជា | | | | | | | | 14.40 | | | | |
| 16 | ធនាគារសាជីវកម្មសឹង្ហបូរី ចំកាត់ | | | | | | | 15.00 | 15.00 | | | | |
| 17 | ធនាគារ ឥណ្ឌា សាខាភ្នំពេញ | | | | | | | | 12.50 | | | | |
| 18 | ម៉ារ៉ូហាន់ ធនាគារជប៉ុន ភី អិល ស៊ី | | | | | | | | 15.00 | | | | |
| 19 | ធនាគារ ប៊ូយ៉ុងខ្មែរ | | | | | | | | 10.00 | | | | |
| 20 | ធនាគារ ស៊ីនហានខ្មែរ | | | | | 15.00 | 15.00 | 15.00 | 15.00 | | | | |
| 21 | ធនាគារ គូកមិន កម្ពុជា ភីអិលស៊ី | | | | | 14.00 | 14.00 | 14.00 | 14.00 | | | | |
| 22 | ធនាគារ អូ អេស ខេ ឥណ្ឌូឆៃណា | | | | | | | | 14.00 | | | | |
| 23 | ធនាគារហុង ឌីប៊ីអេស | | | | | | | | 12.00 | | | | |
| 24 | ធនាគារ ភ្នំពេញ ពាណិជ្ជ | | | | | | | | 19.00 | | | | |
| 25 | ធនាគារ សាខម | 11.00 | 11.00 | 11.00 | 11.00 | 11.00 | 11.00 | 11.00 | 11.00 | | | | |
| 26 | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | | | | | 12.00 | 12.00 | 12.00 | 12.00 | | | | |
| 27 | ធនាគារអាហ្វ្រីប៊ែង សាខាកម្ពុជា | 16,80 | 16,80 | 16,80 | 16,80 | 12.00 | 12.00 | 12.00 | 12.00 | | | | |
| 28 | ធនាគារចិន សាខាភ្នំពេញ | | | | | | | | 11.00 | | | | |
| 29 | ធនាគារអ៊ឹមប៊ី ភីអិលស៊ី | | | | | 9.75 | 9.75 | 9.75 | 9.75 | | | | |
| 30 | ធនាគារអាយស៊ីប៊ីស៊ី ចំកាត់ | | | | | | 2.25 | | 4.83 | | 3.75 | | |
| 31 | ធនាគារមេហ្គា អ៊ិនធើណេសិន ណលខមមើសល | | | | | | | | 10.00 | | | | |
| 32 | ធនាគារអេសហេជប៊ី ភីអិលស៊ី | | | | | | | 7.50 | 7.50 | | | | |
| 33 | ធនាគារខេមខូ លីមីតធីត | | | | | | | | 15.00 | | | | |
| 34 | ធនាគារអភិវឌ្ឍន៍ជនបទ | | | | 15.00 | | | | 15.00 | | | | |
| 35 | ធនាគារឯកទេស ភី អេច អែស អឹម អ៊ី | | | | | | | | 12.00 | | | | |
| 36 | ធនាគារឯកទេស វិនិយោគទីមួយ | | | | | | | | 18.00 | | | | |
| 37 | ធនាគារឯកទេស អានកូ | | | | | | | | 18.00 | | | | |
